ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ពិធីសម្ពោធ បណ្ណាល័យសម្តេចម៉ែ
- ព្រះរាជសំណេររបស់សម្តេចម៉ែព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៤៩ ខែកញ្ញា ឆ្នាំ២០២០

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៩ ខែកញ្ញា ឆ្នាំ២០២០

## មាតិកា

**សំបុត្រ**

◆ ពិធីសម្ពោធ បណ្ណាល័យសម្តេចម៉ែ ...........១
◆ ព្រះរាជសំណេររបស់សម្តេចម៉ែ ...............៩

**ផ្នែកឯកសារ**

◆ ជនជាតិចិន ជម្លៀសចេញពីទីក្រុងភ្នំពេញ ... ១០
◆ អ៊ូច ពេញ ៖ នយោបាយវិសេនា........... ១២

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ដើងមេឃពណ៌ក្រហម ...................... ១៤
◆ កាំង ហ្កេកអ៊ាវ ហៅ ឌុច ...................១៦
◆ នៅពេលនឹកឃើញរឿងរ៉ាវក្នុងរបបខ្មែរ .... ២២
◆ បូជាភ្លើង ....................................២៦
◆ រឿងរ៉ាវមិននឹកស្មានទៅក្នុងឆាកជីវិតខ្ញុំ .... ២៩

**ផ្នែកច្បាប់**

សាលក្រមសំណុំរឿង០០២/០២ ............... ៣៥

**ផ្នែកវេទិកាសាធារណៈ**

◆ រូបថតឯកសារនិងការចងចាំ................ ៤៥
◆ តើឌុចនៅតែមានកំហុសដែរឬទេ? ..........៤៨

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី
ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

◆ ទេព គីមទ្រី៖ គិលានុបដ្ឋាយិកា............. ៥១
◆ ទន់ ឈុំ ៖ វេជ្ជបណ្ឌិត....................... ៥៤
◆ ម៉ុង មួន ៖ គិលានុបដ្ឋាយិកា ................ ៥៦
◆ ឡាំ សុំ ៖ អធិការកិច្ច សាលារៀន.........៥៨



ពិព័រណ៍រូបថតនៅក្នុងបណ្ណាល័យសម្តេចម៉ែ។
(សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ឆាំង យុ, សន ប៊ុនស៊ីម, សួត វិចិត្រ, ហេឌី ហ្វ្រាយ, ប៊ាង ពីរ័ន្ត, វេនី ខកហ្កៀល, វ៉ាន់ថាន់ ពោវដារ៉ា និង ឡុង ដានី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ឋុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** ហួយ លីយាង
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ឋុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ពិធីសម្ពោធ បណ្ណាល័យសម្តេចម៉ែ

## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សព្វព្រះរាជហឫទ័យយាងសម្ពោធ បណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង៩ព្រឹក

*នៅក្នុងពិធីសម្ពោធដ៏ឧត្តុង្គឧត្តមនេះ មានការដាក់តាំងពិព័រណ៍ពិសេសចំនួនពីរ គឺ៖*

*១) ព្រះឆាយាលក្ខណ៍របស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ*

*២) ការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយស្ថាបត្យករលំដាប់ពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ*

**ឆាំង យុ**



*សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីសម្ពោធបណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានារាជធានីភ្នំពេញ វេលាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។ (ព្រះបរមរាជវាំង/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

## បណ្ណាល័យសម្តេចម៉ែ

បណ្ណាល័យសម្តេចម៉ែ បានបង្កើតឡើងជាផ្លូវការដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីថ្វាយព្រះរាជកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជូនសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ដែលបានខិតខំប្រឹងប្រែងដើម្បីសម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ប្រទេសជាតិកម្ពុជា និងប្រជាជនកម្ពុជា។

បណ្ណាល័យសម្តេចម៉ែ មានតម្កល់ទុកសមុច្ច័យជាសៀវភៅប្រមាណជាង ៣០០០ក្បាល និងឯកសារចំនួន ២៨០០ប្រអប់ ដែលប្រមែប្រមូលដោយលោកឯកអគ្គរាជទូតបណ្ឌិត ហ្ស៊ូលីយ៉ូ អេ. ដែលជ្រេស ក្នុងអំឡុងរយៈពេលជាច្រើនឆ្នាំនៃការងាររបស់ក្រុងកត់ត្រាឯកសាររបស់លោកស្តីពីរាជវង្សានុវង្ស និងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ លោកឯកអគ្គរាជទូតបណ្ឌិត ដែលជ្រេស បានបរិច្ចាគដោយសប្បុរសនូវសមុច្ច័យដ៏ធំធេងនេះដល់មជ្ឈមណ្ឌលឯកសារកម្ពុជា នាចុងឆ្នាំ២០១៩។ ឯកសារដែលតម្កល់នៅក្នុងបណ្ណាល័យសម្តេចម៉ែ រួមមានសៀវភៅជាច្រើនទៀតស្តីពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងឯកសារស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) យ៉ាងហោចណាស់ ១លាន៧សែនទំព័រ ដែលស្រាវជ្រាវដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេលប្រមាណជាង ២០ឆ្នាំ កន្លងមក។ ទន្ទឹមនឹងនេះ បណ្ណាល័យសម្តេចម៉ែ ថែមទាំងមានតម្កល់នូវឯកសារក្នុងទម្រង់ដទៃទៀតដូចជា រូបថត ភាពយន្ត និងខ្សែអាត់សំឡេងជាច្រើនម៉ឺននាទីរបស់ជនរងគ្រោះក្នុងសម័យប៉ុល ពត ដែលត្រូវបានធ្វើឲ្យទៅជាទម្រង់ឌីជីថលមានគុណភាពខ្ពស់ ដើម្បីធានាដល់ការអភិរក្សលើឯកសារឲ្យបានគង់វង្ស និងផ្តល់ភាពងាយស្រួលដល់សាធារណជនក្នុងការប្រើប្រាស់។

បណ្ណាល័យសម្តេចម៉ែ គឺមិនមែនគ្រាន់តែជាទីតាំងសម្រាប់សិក្សាអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា តែប៉ុណ្ណោះនោះទេ។ មជ្ឈមណ្ឌលឯកសារកម្ពុជា មានមោទកភាពក្នុងការថ្វាយ និងជូនបណ្ណាល័យនេះ ជាកេរដំណែលរបស់សម្តេចម៉ែ និងស្ត្រីកម្ពុជាគ្រប់រូប។ ស្ត្រីកម្ពុជាបានខិតខំប្រឹងប្រែងដោយមិនរួញរាក្នុង



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះអង្គសព្វព្រះរាជហឫទ័យ យាងថតរូបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (ព្រះបរមរាជវាំង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការស្តារ លើកស្ទួយ និងកសាងប្រទេសជាតិសាជាថ្មី តាមរយៈការចិញ្ចឹមបីបាច់គ្រួសារ ក្តាប់យកនិងពង្រីកឱកាសសេដ្ឋកិច្ច អភិរក្ស ការពារ និងពង្រឹងសហគមន៍ វប្បធម៌ និងប្រទេសជាតិរបស់ខ្លួន ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នេះសបញ្ជាក់ឲ្យឃើញថា ស្រ្តីកម្ពុជា គឺជានិមិត្តរូប នៃដួងព្រលឹងជាតិកម្ពុជា។ បណ្ណាល័យសម្តេចម៉ែ បង្កើតឡើងដើម្បីឧទ្ទិសដល់ស្រ្តីកម្ពុជា ទាំងនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

ក្នុងអំឡុងព្រះរាជដំណើរទស្សនកិច្ចរបស់ទ្រង់ សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យប្រោសប្រទានអំណោយដែលមិនអាចកាត់ថ្លៃបាន រួមមាន សៀវភៅ មេដាយ លិខិតសរសើរ គ្រឿងឥស្សរិយ-យស និងសម្បត្តិផ្ទាល់ព្រះកាយដ៏មានតម្លៃរបស់ទ្រង់ដល់បណ្ណាល័យ ដើម្បីឲ្យសាធារណជនបានទស្សនា សិក្សា និងយល់ដឹងអំពីតម្លៃ។ ដោយគ្មានមន្ទិលសង្ស័យ បណ្ណាល័យសម្តេចម៉ែ គឺជាធនធានជាតិដ៏មានសារសំខាន់ សម្រាប់ការអប់រំសាធារណជន និងយុវជននាពេលបច្ចុប្បន្ន និងជាច្រើនជំនាន់តទៅមុខទៀតនាពេលអនាគត។

មជ្ឈមណ្ឌលឯកសារកម្ពុជា ចាត់ទុកសុវត្ថិភាពសាធារណជាអាទិភាព។ ស្របពេលដែលពិភពលោកកំពុងប្រឈមនឹងវិបត្តិនៃជំងឺរាតត្បាតកូវីដ១៩ ឯសកម្មភាពអប់រំ សកម្មភាពវប្បធម៌ និងព្រឹត្តិការណ៍ជាតិផ្សេងៗនៅតែបន្ត មជ្ឈមណ្ឌលឯកសារកម្ពុជា ជឿជាក់ថាសកម្មភាពទាំងអស់នេះត្រូវតែប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងបានគិតគូរទុកជាមុនអំពីសុខភាព និងសុខមាលភាពរបស់មនុស្សគ្រប់រូប។ អាស្រ័យហេតុនេះហើយ នាខណៈពេលបច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជា សូមរក្សាសិទ្ធិអនុញ្ញាតឲ្យសាធារណជនចូលប្រើប្រាស់ បណ្ណាល័យសម្តេចម៉ែ តាមប្រព័ន្ធអនឡាញ។



























ពិព័រណ៍ព្រះឆាយាលក្ខណ៍របស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ កម្រងព្រះឆាយាលក្ខណ៍នេះបានសម្រិតសម្រាំងចេញពីសមុច្ច័យរបស់លោកឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ ដែលជ្រេស ដែលបានប្រមែប្រមូលនៅចន្លោះឆ្នាំ១៩៨១ និងឆ្នាំ២០១៩។ ព្រះឆាយាលក្ខណ៍ភាគច្រើនមានប្រភពមកពីសមុច្ច័យផ្ទាល់របស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ដែលត្រូវបានថតចម្លងទុកនៅឯទីក្រុងប៉េកាំង ក្នុងចន្លោះឆ្នាំ១៩៩៦និងឆ្នាំ២០០៨ មុនពេលព្រះឆាយាលក្ខណ៍ទាំងនោះត្រូវបានបញ្ជូនដើម្បីអភិរក្សនៅបណ្ណសារដ្ឋានក្នុងប្រទេសបារាំង។

ព្រះឆាយាលក្ខណ៍ភាគច្រើនរួមបញ្ចូលសម័យកាលស្ថិតនៅចន្លោះឆ្នាំ១៩៥០ និងឆ្នាំ១៩៩១ ដែលបង្ហាញអំពីព្រះរាជសកម្មភាពផ្សេងៗរបស់សម្តេច ព្រះបរមរតនកោដ្ឋ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ រួមមាន អំឡុងពេលដែលព្រះអង្គបានយាងព្រះរាជដំណើរនៅទូទាំងប្រទេសកម្ពុជាក្នុងបុព្វហេតុទាមទារឯករាជ្យ ដោយពេលខ្លះទ្រង់មានសេះជាព្រះទីនាំង ដើម្បីពន្យល់ប្រជាជនកម្ពុជា អំពីហេតុផលដែលប្រទេសកម្ពុជាត្រូវការឯករាជ្យភាពពីប្រទេសបារាំង។

ព្រះឆាយាលក្ខណ៍មួយចំនួន បង្ហាញអំពីរយៈកាលក្រោយពីប្រទេសកម្ពុជាទទួលបានឯករាជ្យ គឺជាខណៈពេលមួយដែលប្រទេសកម្ពុជាមានសុខសន្តិភាព និងព្រះរាជសកម្មភាពដឹកនាំរបស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ក្នុងការកសាងជាតិ តាមរយៈការស្ម័គ្រព្រះកាយចូលរួម និងសកម្មភាពដទៃទៀតជាមួយនឹងប្រជាជនកម្ពុជា។

ព្រះឆាយាលក្ខណ៍ដទៃទៀត បង្ហាញពីព្រះរាជសកម្មភាពការទូត របស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ នាគ្រាដ៏លំបាកលំបិន នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ បន្ទាប់ពីព្រះអង្គត្រូវបានបង្ខំឲ្យភៀសព្រះកាយទៅគង់នៅក្រៅប្រទេសកម្ពុជា។ រូបថតក្នុងបណ្តុំ



សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យ ព្រះរាជសំណេរលើសៀវភៅក្រាំងមាសរបស់បណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានារាជធានីភ្នំពេញ វេលាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។
(សន ប៊ុនស៊ុម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នេះរួមមាន ព្រះរាជទស្សនកិច្ចរបស់ព្រះអង្គទៅកាន់ប្រទេសស៊ូដង់ (ជាទីកន្លែងដែលព្រះអង្គបានគ្រងសម្លៀកបំពាក់ប្រពៃណីរបស់យុទ្ធជនស៊ូដង់), សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងតំបន់រំដោះក្នុងប្រទេសឡាវ ដែលជាព្រះរាជទស្សនកិច្ចមួយប្រកបដោយគ្រោះថ្នាក់ដោយសារមូលហេតុថា យន្តហោះទម្លាក់គ្រាប់បែក បានហោះហើរកាត់តំបន់នោះជាញឹកញាប់ក្នុងសម័យសង្គ្រាមវៀតណាម។

ព្រះឆាយាលក្ខណ៍ផ្សេងៗទៀត បង្ហាញអំពីការសម្រាកលំហែនៅទីក្រុងប៉េកាំងរបស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ, សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ និងព្រះរាជវង្សានុវង្សដទៃទៀត។ ព្រះឆាយាលក្ខណ៍ខ្លះបង្ហាញអំពីព្រះរាជសកម្មភាពទ្រង់កីឡាវាយសីរបស់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ នៅឯព្រះរាជដំណាក់នាទីក្រុងប៉េកាំង ដែលរដ្ឋាភិបាលចិនថ្វាយជូនទ្រង់។ ព្រះឆាយាលក្ខណ៍ដទៃទៀតបង្ហាញពីព្រះរាជសកម្មភាពនិពន្ធតន្ត្រី ដែលជាព្រះរាជកិច្ចមួយ ព្រះអង្គសព្វព្រះរាជហឫទ័យធ្វើនៅពេលទ្រង់សម្រាកព្រះកាយ។




## ពិព័រណ៍ការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយ ស្ថាបត្យករល្បីជាប់ពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ

នៅឆ្នាំ២០១៤ លោកស្រី ហ្សាហា ហាឌីដ នាយកស្ថាបត្យកម្ម ហ្សាហា ហាឌីដ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើសេចក្តីប្រកាសរួមអំពីកិច្ចសហប្រតិបត្តិការជាមួយស្ថាបត្យកម្មរបស់លោកស្រី ហាឌីដក្នុងការរចនាប្លង់អគារវិទ្យាស្ថានស្លឹករឹត ដែលគឺជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីរំពុក និងឧទ្ទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតប្រមាណ២លាននាក់ នាអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

ការជ្រើសរើសយកស្ថាបត្យកម្មរបស់លោកស្រី ហាឌីដ ដែលមានភាពល្បីល្បាញកម្រិតពិភពលោក លើផ្នែកស្ថាបត្យកម្មបែបបង្កើតថ្មីនិងទំនើប បង្ហាញអំពីការសម្រេចចិត្តរបស់លោក ឆាំង យុ ដើម្បីធ្វើឲ្យមានភាពខុសប្លែកពីគំរូបែបអភិរក្សនៃសំណង់ស្ថាបត្យកម្ម បម្រើនាទីជាបូជនីយដ្ឋានរំពុកពីអំពើប្រល័យពូជសាសន៍ ដែលធ្លាប់សាងសង់កាលពី៧០ឆ្នាំមុនមក។ ការរចនាប្លង់អគារបែបអភិរក្ស គឺសង្កត់ធ្ងន់លើផ្នែកខាងក្រៅដែលមានពណ៌ស្រអាប់ និងមានជ្រុងច្រើន ហើយសាងសង់ឡើងដោយប្រើប្រាស់ថ្ម ដែក និងកញ្ចក់ខ្វះ ដើម្បីរំលេចនិងបញ្ជាក់អំពីសណ្ឋាននៃភាពឃោរឃៅរបស់អំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មសង្គ្រាម។ ទស្សនវិស័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្តល់តម្លៃដល់អតីតកាល ដែលផ្តោតសំខាន់ក្នុងការធានាឲ្យអ្នកទស្សនាមានបទពិសោធន៍វិជ្ជមាន មានអារម្មណ៍ធូរស្រាល និងផ្តោតជាសំខាន់ទៅលើអនាគត។ ថ្វីត្បិតតែអ្នកទស្សនាអញ្ជើញមកកាន់វិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងក្នុងរាជធានីភ្នំពេញនេះនឹងបានឃើញកេរដំណែលពោរពេញទៅដោយសោកនាដកម្មនៃរបបខ្មែរក្រហម ចងចាំពីជនរងគ្រោះក្នុងនាមជាមនុស្សដែលបានធ្លាក់ចូលទៅក្នុងភក់ភ្លើងសង្គ្រាម មនោគមវិជ្ជាជ្រុលនិយម និងការគិតដោយមិនសមហេតុផលយ៉ាងណាក្តី វិទ្យាស្ថានស្លឹករឹតនឹងផ្តោតទៅលើអ្វីដែលត្រូវធ្វើដើម្បីបង្ការមិនឲ្យស្ថានការណ៍

ខាងលើកើតឡើងសាជាថ្មី ដោយប្រើប្រាស់កម្មវិធីអប់រំណែនាំជាច្រើនប្រភេទៗ អ្នកទស្សនានឹងបានយល់ដឹងថាតើ តម្លៃទាក់ទងទៅនឹងចំណេះដឹង ការអត់ឱនការផ្សះផ្សា និងការយោគយល់អធ្យាស្រ័យ នឹងផ្តល់ឲ្យមនុស្សនូវមធ្យោបាយឆ្ពោះទៅកាន់អនាគតមួយ ដែលពោរពេញទៅដោយភោគផល និងភាពវិជ្ជមានបានយ៉ាងដូចម្តេចៗ ទន្ទឹមនឹងនេះ អ្នកទស្សនាអាចយល់ដឹងបន្ថែមទៀតពីរបៀបដាក់បញ្ចូលព្រឹត្តិការណ៍ដែលនាំឲ្យឈានដល់របបខ្មែរក្រហម ទៅក្នុងបរិបទនៃប្រវត្តិសាស្ត្រយូរលង់របស់ប្រទេសកម្ពុជា និងអាចយល់ដឹងថា ហេតុអ្វីបានជាបរិបទនោះគួរតែលើកយកមករំឭកឡើងវិញជាសាធារណៈៗ

ស្ថាបត្យកម្មបែបពត់ពេន ប៉ុន្តែមានឥទ្ធិពលរបស់លោកស្រី ហ្សាហា ហាឌីដ ផ្តោតទៅលើរូបរាងបត់បែន ជាជាងរូបរាងមុត និងមានសណ្ឋានធរណីមាត្របង្ហាញពីជ្រុងជាក់លាក់ ដែលប្រៀបដូចទៅនឹងអគារ





ខុសរ្យាហកម្ម។ ស្នាដៃស្ថាបត្យកម្មរបស់លោកស្រី មានសក្តានុពលអាចកែប្រែគំនិតរចនានៃសំណង់ស្ថាបត្យកម្មបម្រើតួនាទីជាបូជនីយដ្ឋានរំឭកដល់ឧក្រិដ្ឋកម្មសង្គ្រាមឲ្យផ្លាស់មុខមាត់ថ្មី និងប្រសើរជាងមុន។ លើសពីនេះទៅទៀត ដោយសារតែជនរងគ្រោះស្ទួតត្រង់នៃឧក្រិដ្ឋកម្មសង្គ្រាមតែងតែរួមមាន ស្ត្រីនិងកុមារជាច្រើន នេះគឺជាពេលវេលាដ៏សក្តិសម ដែលស្ត្រីគួរតែដើរតួនាទីជាអ្នកដឹកនាំការងាររចនាបូជនីយដ្ឋាន ដើម្បីទទួលស្គាល់ និងរំលេចនូវការបាត់បង់ជារួមរបស់ជនរងគ្រោះទាំងនោះ។

បេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា រួមមានស្ថាបត្យកម្មអច្ឆរិយនៃចក្រភពអង្គរពីបុរាណ គឺជានិមិត្តរូបដែលទទួលស្គាល់ជាអន្តរជាតិ បង្ហាញអំពីកេរដំណែលដ៏សម្បូរបែបរបស់ប្រទេសកម្ពុជា។ ក្រុមការងាររចនាអគារវិទ្យាស្ថានស្លឹករឹតបានធ្វើការសម្រេចចិត្តជាយុទ្ធសាស្ត្រ ដោយផ្សារភ្ជាប់នឹងអតីតកាល ទៅនឹងប្រាសាទបន្ទាយស្រី ដែលជាប្រាសាទមួយដ៏ផ្ចិតផ្ចង់សាងសង់ឡើងក្នុងសម័យអង្គរ។ ដោយសារតែមូលហេតុថា កម្រិតល្អិតល្អន់នៃស្នាដៃសិល្បៈនៅលើប្រាសាទនេះ មានសភាពសព្វជ្រុងជ្រោយនិងស៊ីជម្រៅ និងជារឿយៗ ប្រាសាទបន្ទាយស្រីតែងតែត្រូវបានប្រៀបប្រដូចទៅនឹង «រតនវត្ថុនៃសិល្បៈខ្មែរ» នៅក្នុងអក្សរសិល្ប៍ខ្មែរ។ ប្រាសាទបន្ទាយស្រី មានទំហំតូចប៉ុន្តែជាប្រាសាទយ៉ាងសំខាន់និងប្រកបដោយសិល្បៈល្អឯក រំលេចនូវព្រេងនិទានជាគ្រឿងលម្អដ៏វិសេសវិសាលនៅតាមហោរជាងនិងផ្តែរនៃប្រាសាទ ដែលគឺជានិមិត្តរូបជំរុញចិត្តដ៏សមស្របបំផុតសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការចងចាំនិងការរចនាសារមន្ទីរ។

ស្ទើរតែគ្រប់សាសនាធំៗទាំងអស់ សុទ្ធសឹងតែមានក្រិត្យក្រមជាមូលដ្ឋាននៃជំនឿនិងរឿងព្រេង ស្តីអំពីវត្តមាននិងតួនាទីនៃឋានសួគ៌និងឋាននរក។ គ្មានសាសនាណាមួយដែលបកស្រាយអំពីរឿងព្រេងនិទាននិងទំនាក់ទំនងរបស់ ព្រះ ទេវតា នៅឋានសួគ៌ និងយាមានៅឋាននរក បានសព្វជ្រុងជ្រោយ និងស៊ីជម្រៅជាងព្រះពុទ្ធសាសនានិងសាសនាហិណ្ឌូនៅក្នុងទ្វីបអាស៊ី ដែលជាសាសនាចម្បងរបស់ប្រទេសកម្ពុជានោះទេ។ ភាពសម្បូរបែបនៃទំនៀមទម្លាប់ប្រពៃណីសាសនាទាំងពីរ គឺមិនអាចមាននៅលើតួអង្គល្អនិងតួអង្គអាក្រក់របស់លោកខាងលិច ឬសាសនាដែលកើតក្រោយដទៃទៀត ដូចជាសាសនាជ្វីហ្វ, គ្រិស្តសាសនា និងសាសនាឥស្លាមនោះឡើយ។ យោងតាមព្រេងនិទានរបស់ព្រះពុទ្ធសាសនានិងសាសនាហិណ្ឌូ ឋាននរកនិងឋានសួគ៌មានសារសំខាន់ក្រៃលែង ក្នុងការទទួលស្គាល់និងការយល់ដឹងថា តើមូលហេតុអ្វីបានជាប្រជាជនកម្ពុជា មានប្រតិកម្មចំពោះកេរដំណែលដ៏អសោចនៃរបបខ្មែរក្រហមខុសពីការយល់ឃើញរបស់លោកខាងលិច ដែលពោរពេញទៅដោយការចងកំហឹង ការដាក់ទោសទណ្ឌ និងការចងអាឃាត។

ស្ថាបត្យកម្មរបស់លោកស្រី ហាឌីដ និងលោក ឆាំងយុ បានរួមគ្នាបង្កើតជាអគារមួយនេះឡើង ដែលដើរតួនាទីពង្រីកនិងពង្រឹងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបង្កើនការទទួលជ្រាបនិងការយល់ដឹងជាសាធារណអំពីសោកនាដកម្មដែលបានកើតឡើង និងស្វះស្វែងរកផលប្រយោជន៍សង្គមចេញពីការផ្សះផ្សាតាមរយៈការអប់រំ ការបញ្ជ្រាបចំណេះដឹង និងការធ្វើឲ្យធូរស្បើយអារម្មណ៍ ដោយផ្អែកលើការចងចាំនិងការប្តេជ្ញាចិត្ត។ ការរចនាបូជនីយដ្ឋានរបស់លោកស្រី ហាឌីដ គឺជាស្នាដៃមួយប្រកបដោយសម្រស់ល្អឯកនិងជានិមិត្តរូបដ៏កម្រក្នុងសតវត្សរ៍ទី២១។



# ព្រះរាជសំណេររបស់សម្តេចម៉ែ

## ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
## ក្នុងឱកាសសម្ពោធបណ្ណាល័យសម្តេចម៉ែនៃវិទ្យាស្ថានស្លឹករឹត
## របស់មជ្ឈមណ្ឌលឯកសារកម្ពុជា





Je voudrais adresser mes plus chaleureuses
félicitations à Monsieur Youk Chhang et à son équipe
du Sleuk Rith Institute pour la création de la Queen
Mother Library. Je suis très touchée que le Sleuk Rith
Institute ait décidé de donner mon nom à cette magnifique
bibliothèque.

Je souhaite à Monsieur Youk Chhang et à son équipe
du Sleuk Rith un succès continu dans leur noble travail
visant à faire connaître et préserver l'histoire du Cambodge.

Monineath

*យើងសូមសម្តែងអំណរសាទរដ៏ជ្រាលជ្រៅបំផុតចំពោះលោក ឆាំង យុ និងក្រុមការងារ នៃវិទ្យាស្ថានស្លឹករឹត ចំពោះការបង្កើត បណ្ណាល័យសម្តេចម៉ែ។ យើងពិតជាមានការរំជួលព្រះហឫទ័យ យ៉ាងក្រៃលែង ដែលវិទ្យាស្ថានស្លឹករឹតបានសម្រេចកំណត់យកឈ្មោះរបស់បណ្ណាល័យដ៏បវរនេះ តាមព្រះនាមរបស់យើង។*

*យើងសូមជូនពរ លោក ឆាំង យុ និងក្រុមការងារនៃវិទ្យាស្ថានស្លឹករឹត បន្តបំពេញការងារដ៏ប្រពៃរបស់ខ្លួនប្រកបដោយជោគជ័យ ដើម្បីលើកស្ទួយ និងអភិរក្សប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។*

**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ**

# ជនជាតិចិន ជម្លៀសចេញពីទីក្រុងភ្នំពេញ

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ D0២៧0៤

**ដារ៉ារដ្ឋ មេត្តា**



រូបទីពីររាប់ពីស្តាំ នៅជួរខាងមុខ៖ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) កំពុងស្តាប់ទីប្រឹក្សាចិន រៀបរាប់ពីបច្ចេកទេសបាញ់កាំភ្លើងធំ នៅសមរភូមិមុខៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ មុយ គង់ ភេទប្រុស អាយុ២៦ឆ្នាំ ក្នុងឆ្នាំ១៩៧៥។ ខ្ញុំគឺជាជនជាតិចិនកន្តាំង។ ខ្ញុំមានស្រុកកំណើតនៅ សង្កាត់លេខ៣ ក្រុងភ្នំពេញ ហើយឆ្នាំ១៩៧៥ បានទៅរស់នៅក្រុម ទី៣ ភូមិលេខ២ ឃុំសំរោងធំ ស្រុក១៦ តំបន់២៥។ ខ្ញុំចេះអានអក្សរខ្មែរបន្តិចបន្តួច និងបានរៀនអក្សរចិនបានរយៈពេល៣ឆ្នាំ។

មុនកើតមានព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧0 ខ្ញុំមានមុខរបរជាកម្មករ នៅហាងលក់កញ្ចក់ និងលក់គ្រឿងអគ្គិសនីមានស្លាកយីហោឈ្មោះ លី ហុង ស្ថិតនៅលើមហាវិថី ហ្សង់ដឺហ្គោល រាជធានីភ្នំពេញ។ ក្រោយរដ្ឋប្រហារ ឆ្នាំ១៩៧0 ដដែល ខ្ញុំធ្វើជាកម្មករឲ្យក្រុមហ៊ុនឯកជននីហរ័ណ អាហរ័ណ នាំចេញនិងនាំចូលនូវផលិតផល

ក្នុងប្រទេស ទៅក្រៅប្រទេស មាន៖ ហុងកុង បាងកក ព្រៃនគរ និង តៃប៉ិ។ ខ្ញុំបានទៅប្រទេសទាំងនោះជារៀងរាល់ឆ្នាំ។ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ខ្ញុំទទួលបានប្រាក់ខែចំនួន ៩០០០រៀល និងអាចរកបានប្រាក់កម្រៃក្រៅជាច្រើនទៀតទៅតាមពេលវេលាបន្ថែមម៉ោងធ្វើការតិចឬច្រើន។

ឪពុកខ្ញុំឈ្មោះ មុយ ឡាយ អាយុ៥៧ឆ្នាំ ក្នុងឆ្នាំ១៩៧៥ និងម្ដាយឈ្មោះ នាង ចាបនួន អាយុ៥៣ឆ្នាំ ក្នុងឆ្នាំ១៩៧៥ គឺជាជនជាតិចិនកន្តាំងដូចគ្នា។ កាលពីឆ្នាំ១៩៧០ ឪពុកម្ដាយខ្ញុំ ធ្វើចម្ការនៅក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួនបីនាក់ ដោយឈ្មោះ មួយ យាង និង មួយ លី សុទ្ធតែស្ថិតនៅក្នុងបន្ទុក។

ខ្ញុំមានប្រពន្ធឈ្មោះ នាង អ៊ិត ហ្យាង អាយុ២៣ឆ្នាំ ជនជាតិ ចិនកន្តាំង។ ប្រពន្ធខ្ញុំមិនចេះនិយាយភាសាខ្មែរទេ។ ខ្ញុំមានកូនស្រីម្នាក់។ ឪពុកក្មេកខ្ញុំឈ្មោះ ចាន់ ឈុន និង ម្ដាយ នាង មុយគួ ពីមុនរកស៊ីលក់សាច់ជ្រូកនៅផ្សារថ្មី ហើយនៅឆ្នាំ១៩៧៥ ធ្វើជាម្ចាស់សណ្ឋាគារនៅហុងកុង។ បងប្អូនខាងប្រពន្ធខ្ញុំមានចំនួនប្រាំបួននាក់ រស់នៅហុងកុងទាំងអស់។

រយៈកាលដែលខ្ញុំជម្លៀសចេញពីទីក្រុងភ្នំពេញមករស់នៅក្នុងឃុំសំរោងធំ ខ្ញុំប្រាកដជាមានចិត្តស្អប់ខ្ពើមការងារពលកម្ម មិនព្រមចូលរួមប្រឡូកក្នុងការងារជីកប្រឡាយ ។ ការងារទាំងនេះ ខ្ញុំមិនធ្លាប់នឿយ មិនធ្លាប់លំបាក ឯជីវភាពទស្សនៈសតិអារម្មណ៍មានការផ្ទាំងផ្ទាក់ក្ដៅក្រហាយនឹងអង្គការបដិវត្តន៍។ កាលនៅភ្នំពេញខ្ញុំមាន ហូបចុកគ្រប់គ្រាន់ លុយចាយ សប្បាយហ៊ឺហា មើលកុនល្ខោន ស្រីស្រា សព្វមុខ ធ្លាប់មានសេរីភាពគ្រប់យ៉ាងទាំងការនិយាយស្ដី ទាំងការដើរលេង ចង់ទៅណាក៏បានតាមចិត្ត។ ពេលខ្ញុំមករស់នៅក្នុងសង្គមបដិវត្តន៍ ខ្ញុំជួយលើការងារពលកម្មជីកប្រឡាយ លើកភ្លឺ ហាលថ្ងៃក្ដៅរងា លំបាកវេទនាសព្វមុខ និងមានជីវភាពខ្វះខាតនៅក្នុងគ្រួសារ។ ខ្ញុំកំណត់ថា មិនអាចរស់នៅជាមួយអង្គការបដិវត្តន៍ជាដាច់ខាត ខ្ញុំនឹងធ្វើសកម្មភាពប្រឆាំងជាមួយបដិវត្តន៍ដរាបជីវិតចុងក្រោយ។ ខ្ញុំបានជេរប្រទេចអង្គការថា អង្គការខ្មែរខ្មៅ ជញ្ជក់ញើសឈាមប្រជាជនកៀបសង្កត់សិទ្ធិសេរីភាពប្រជាជន ឆក់ប្លន់ទ្រព្យសម្បត្តិប្រជាជន។ គោលបំណងនៃការជេរនេះ គឺធ្វើឡើងដើម្បីឲ្យប្រជាជនជិតខាងមានការយល់ឃើញ និងមានគោលជំហរ ក្ដៅក្រហាយចំពោះអង្គការដូចខ្ញុំដែរ។ នៅក្នុងផែនការធ្វើឲ្យប្រជាជនស្ពឹកស្រពន់លើការងារពលកម្មបង្កបង្កើនផល បាត់បង់ជំនឿទុកចិត្តលើអង្គការ។ ខ្ញុំបានជេរប្រពន្ធជាញឹកញាប់វាយហើមមុខមាត់បែកក្បាល ដោយប្រើពាក្យអាសអាភាស ជាភាសាចិន និងលាយភាសាខ្មែរ។ ខ្ញុំពុំសូវធ្វើពលកម្មបង្កបង្កើនផល ទោះបីជាមានការណែនាំញឹកញាប់ពីអង្គការយ៉ាងណាក្ដី ខ្ញុំនៅតែពុំស្ដាប់ដែរ។

ខ្ញុំបានធ្វើឲ្យមានបញ្ហាស្មុគស្មាញដល់អង្គការបដិវត្តន៍ភូមិ ដោយបានឈ្លោះប្រកែកទាស់ទែងគ្នាជាមួយនឹងអ្នកជិតខាងជាញឹកញាប់។ ខ្ញុំ មានទំនោរទៅរករបបសេរីនិយម ដូចនេះ សម្ភារ អង្ករ ត្រី សាច់ ផ្លាស់ប្ដូរជាមួយខោអាវ ថ្នាំពេទ្យ ដោយគ្មានការសុំអនុញ្ញាតពីអង្គការបដិវត្តន៍។ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៥ អង្គការបានចាប់ខ្លួនខ្ញុំ។

ខ្ញុំបានឆ្លើយចប់នៅម៉ោងបីកន្លះ នៅថ្ងៃខែឆ្នាំដដែល ហើយអ្នកសួរចម្លើយ បានអានឲ្យខ្ញុំស្ដាប់ឡើងវិញ ក្រែងមានកន្លែងណាមានភាពលើសលុស។

កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយរបស់ មុយ គង់ ពិត ឬយ៉ាងណានោះទេ។

# អ៊ូច ពេញ ៖ នយោបាយវរសេនាតូចលេខ៣២៣

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00៧៦៧

*ជាវ៉ារដ្ឋ មេត្តា*



*យោធាខ្មែរក្រហមកំពុងត្រៀមប្រយុទ្ធនៅលេណដ្ឋាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ជា ពេញ ឈ្មោះបដិវត្តន៍ ហៅ អ៊ូច ពេញ ភេទប្រុស អាយុ២២ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិបឹងខ្ពប ឃុំខ្ពប ស្រុកស្អាង ឬស្រុក២០ តំបន់២៥។

ឪពុកខ្ញុំឈ្មោះ ជា មានអាយុ៥៥ឆ្នាំ និងម្តាយឈ្មោះ អ៊ូច យុត។ ខ្ញុំមានបងប្អូនទាំងអស់ចំនួនបីនាក់ក្នុងនោះមានស្រីចំនួនមួយនាក់។ បងប្អូនខ្ញុំមិនចូលបដិវត្តន៍ទេ គឺមានតែខ្ញុំម្នាក់ប៉ុណ្ណោះ។ ខ្ញុំបានចូលបដិវត្តន៍នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧២ តាមរយៈឈ្មោះ ហេង មានតួនាទីជាមេភូមិបឹងខ្ពប។ មូលហេតុដែលនាំឲ្យខ្ញុំសម្រេចចិត្តចូលបដិវត្តន៍គឺដើម្បីរំដោះខ្លួន និងប្រទេសជាតិឲ្យរួចផុតពីវណ្ណៈជិះជាន់។

មុនដំបូងខ្ញុំនៅមន្ទីរឈ្លប១៦ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឈ្មោះ គង់ មានតួនាទីជាអនុនយោបាយកងធំ។ ខ្ញុំរស់នៅក្នុងមន្ទីរឈ្លប ១៦ អស់រយៈពេល ៤ខែ។ ក្រោយមកខ្ញុំបានផ្លាស់មកអង្គភាពវរសេនាតូច ១២៧ ប្រចាំតំបន់២៥ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ លាត គឺជាលេខាវរសេនាតូច១២៧។

ក្រោយមកនៅក្នុង ខែមីនា ឆ្នាំ១៩៧៣ អង្គភាពវរសេនាតូច ១២៧ ត្រូវអង្គការប្រកាសបញ្ចូលក្នុងកងភូមិភាគពិសេសគឺស្ថិតនៅក្នុងវរសេនាធំ ២៦៨ ដែលជាកងពល ១២ ចាស់ មាន ឈ្មោះ សុន គឺជាលេខាវរសេនាតូច១២៧។ ខ្ញុំបានរស់នៅក្នុងអង្គភាពនេះរហូតដល់ខែ សីហា ឆ្នាំ១៩៧៦។ សុន បានអូសទាញខ្ញុំ គឺដំបូងនៅពេលដែលខ្ញុំកំពុងតែនៅវាយខ្មាំងនៅក្នុងសមរភូមិព្រែកតាអេវ ខាងវត្តឫស្សីស្រុក។ ខ្ញុំមានជំងឺ

គ្រូនញាក់ ហើយបានមកសម្រាកព្យាបាលនៅពេទ្យប្រចាំវរសេនាតូច ១២៧ នៅម្តុំខាងក្រោមស្ពានថ្មត្រើយខាងកើត ស្ថិតនៅភូមិឈើទាល។ នៅពេលខ្ញុំដេកសម្រាកតែម្នាក់ឯង សុន បានដើរមកមើលមន្ទីរពេទ្យ ហើយក៏ចូលមកសួរសុខទុក្ខខ្ញុំ និងសួរខ្ញុំអំពីគ្រួសារ និងបងៗដែលរស់នៅភ្នំពេញ និងរស់នៅដីខ្មាំង។ គាត់សួរខ្ញុំថាប្រសិនបើធ្វើបដិវត្តន៍ឈ្នះ អង្គការនឹងកម្ទេចបងរបស់មិត្តហើយតើមិត្តគិតយ៉ាងណា? ខ្ញុំឆ្លើយថាប្រសិនបើបដិវត្តន៍ឈ្នះ ហើយកម្ទេចបងខ្ញុំក៏កម្ទេចចុះ។ គាត់សួរបញ្ឆេកខ្ញុំ មិត្តមិនអាណិតបងៗទេ? ខ្ញុំបានយកសម្តីគាត់មកគិតតែមិនដឹងថាគាត់ចង់និយាយពីអ្វី? ថ្ងៃបន្ទាប់ខ្ញុំបានជួបគាត់ទៀត នៅពេលដែលខ្ញុំកំពុងអង្គុយលេងនៅលើស្ពាន ហើយគាត់សួរខ្ញុំទៀតថា គិតឃើញឬនៅរឿងដែលគាត់បានសួរកាលពីថ្ងៃមុន? ខ្ញុំថាគិតមិនចេញទេ។ គាត់បាននិយាយពីអង្គការដែលមិនទុកចិត្តខ្ញុំ ព្រោះខ្ញុំមានបងប្អូនរស់នៅក្នុងដីខ្មាំង។ រហូតដល់ថ្ងៃមួយអង្គការបានចាត់តាំងខ្ញុំទៅសមរភូមិដែលមានគ្នា៥នាក់ដើម្បីទៅប្តូរអ្នកឈឺ នៅខ្សែត្រៀមខាងមុខ។ ខ្ញុំដើរក្រោយគេចម្ងាយ៥០ម៉ែត្រ ពេលដើរកាត់តាមមន្ទីរបស់ សុន ពេលនោះ សុនបានហៅខ្ញុំឲ្យឈប់ ហើយបានធ្វើការអប់រំខ្ញុំកុំឲ្យខំខិតខំវាយខ្មាំងពេកប្រយ័ត្នអង្គការឈ្នះកម្ទេចបងប្អូនខ្ញុំ។ សុន ថាខំធ្វើបដិវត្តន៍យូរហើយមិនបានអ្វីទេ ហើយតួនាទីខ្ញុំជាមេក្រុមនេះគឺគាត់ជាអ្នកប្រាប់មិត្ត គង់ឲ្យតម្លើងតួនាទីឲ្យខ្ញុំ។ បន្ទាប់ពីខ្ញុំទទួលបានការអប់រំខ្ញុំយល់ស្របតាម សុន ដោយបានអនុវត្ត ដូចជា៖ រត់ចោលខ្សែត្រៀមជាញឹកញាប់, មិនប្រយុទ្ធមិនវាយខ្មាំង ទុកឲ្យខ្មាំងវាយសង្កត់មកលើខ្សែត្រៀម, បំផ្លាញសម្ភារសឹក ដូចជា ចប ប៉ែល គ្រាប់ អង្រឹង ជាបន្តបន្ទាប់ និងបំផុសប្រជាជនឲ្យខ្លាចខ្មាំង និងមិនហានប្រយុទ្ធ។ សកម្មភាពបំផុសរបស់ខ្ញុំបានធ្វើឲ្យ សុន ពេញចិត្តយ៉ាងខ្លាំង រហូត សុន បញ្ចូលខ្ញុំក្នុងបក្សពលករនៅខែមិថុនា ឆ្នាំ១៩៧៤។

នៅក្នុងឆ្នាំ ១៩៧៤ សុន ប្រាប់ខ្ញុំថាគាត់កសាងកម្លាំងបាន៥នាក់ ហើយគាត់បានប្រាប់ខ្ញុំឲ្យទាក់ទងជាមួយអ្នកទាំង ៥នាក់ នោះមានឈ្មោះ សេង មាននាទីស្នងការកងតូច, អេង គឺជាបញ្ជាការកងតូច, វ៉ន គឺជាមេក្រុមកងតូចទី២ កងធំ៧/២ វរសេនាតូច១២៧, ពេជ គឺជាអនុកងតូច កងធំ៧/១ វរសេនាតូច១២៧ វរសេនាធំ២៦៨, ចយ គឺជាអនុក្រុម កងតូចទី២ កងធំ៧/២ វរសេនាធំ២៦៨។ ចាប់តាំងពីខ្ញុំនិងសុន ពិភាក្សាគ្នាពីកម្លាំងនេះមកមិនដែលបានជួបគ្នារហូតដល់វាយបែកទីក្រុងភ្នំពេញនិងទូទាំងប្រទេស។ ខ្ញុំបានទៅរៀនបច្ចេកទេសយោធានៅព្រែកជ្រៅអស់រយៈពេល៥ខែ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៥ ទើបខ្ញុំបានបញ្ចប់វគ្គ។ បន្ទាប់ពីខ្ញុំត្រឡប់មកវិញឈ្មោះ សុន ត្រូវអង្គការដកទៅកន្លែងផ្សេង ចំណែកបក្ខពួកបាត់អស់។ ខ្ញុំក៏ត្រឡប់មកក្នុងកងពលធំ ៧១ គឺមាន បងយ៉ឹម និង ឆាំ ជាអ្នកទទួលខុសត្រូវ។ ក្រោយមកអង្គការបានចាត់តាំងខ្ញុំឲ្យទៅនៅសមុទ្រ។ នៅពេលខ្ញុំទៅសមុទ្រ ខ្ញុំបានជួបពិភាក្សាជាមួយ ឈឺន គឺជាយោធាវរសេនាតូច៣២២។ នៅពេលជួប ឈឺន នៅរោងបាយស្ថិតនៅព្រែកត្រពាំងស្តៅ ឈឺន ប្រាប់ខ្ញុំថាពេលនេះ ប្រជាជនមកកន្លែងយើងច្រើនណាស់ ដូច្នេះមិត្តត្រូវធ្វើឲ្យខូចនយោបាយបដិវត្តន៍ និងប្រជាជន។ ប្រសិនបើប្រជាជនសួរមិត្តថា មកពីកងខាងណាត្រូវប្រាប់មកពីកងទ័ពរបស់មជ្ឈិមធ្វើឲ្យប្រជាជនខ្លាច ហើយនៅពេលគាត់ចង់រកត្រីដោយមកសុំមងឲ្យគាត់យកទៅរាយ ប៉ុន្តែនៅពេលគាត់ទៅមើលមងមិនត្រូវឲ្យគាត់ទៅជាដាច់ខាត ធ្វើយ៉ាងនេះទើបមានទំនាស់ជាមួយបដិវត្តន៍។ ខ្ញុំបានយកការពិភាក្សានេះទៅអនុវត្តជាបន្តបន្ទាប់រហូតដល់ ខែសីហា ឆ្នាំ១៩៧៦។ នៅឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំមកនៅក្នុងអង្គភាពវរសេនាតូច៣២៣ វរសេនាធំ៣២ កងពលថ្មី៧០៣ ដែលស្ថិតនៅក្រោមការដឹកនាំ របស់បង ចេវ។ ខ្ញុំបាននៅក្នុងអង្គភាពវរសេនាតូច៣២៣ វរសេនាធំ៣២ កងពលថ្មី ៧០៣ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៧។ អង្គការបានឲ្យខ្ញុំទៅនៅក្នុងអង្គភាពអនុសេនាធំ៤៧ថ្មី របស់កងពល៧០៣ ក្រោមការដឹកនាំរបស់ ឆាំ រហូតដល់អង្គការបានចាប់ខ្លួនខ្ញុំ។

*កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ជា ពេញ ហៅ អ៊ុច ពេញ ពិតប្រាកដយ៉ាងណានោះទេ។*

# ជើងមេឃពណ៌ក្រហម

សន ប៊ុនស៊ីម




លោកជំទាវ ទន់ សាអ៊ីម (ឆ្វេង), ឆាន់ វុត្ថា (កណ្ដាល), និង លោកស្រី សូ ហ្វារីណា (ស្ដាំ) នៅក្នុងពិធីប្រគល់រង្វាន់ជូនជ័យលាភីទាំង៩រូប នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០២០ (សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)។

ឆាន់ វុត្ថា គឺជាម្ចាស់ជ័យលាភីវ័យ២៧ឆ្នាំ មកពីខេត្តព្រៃវែង។ សាច់រឿងរបស់ វុត្ថា បានជាប់ចំណាត់ថ្នាក់លេខ៤ស្ថិតក្នុងចំណោមជ័យលាភីទាំង៩រូបផ្សេងទៀត នៅក្នុងកម្មវិធីអក្សរសិល្ប៍ស្ទឹករីតលើកទី១ ឆ្នាំ២០២០ រៀបចំដោយសមាគមអ្នកនិពន្ធខ្មែរ និងមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីខែកក្កដាកន្លងទៅ។

វុត្ថា បានរៀបរាប់ថា៖ «កត្តាដែលជំរុញឲ្យខ្ញុំសរសេររឿងនេះដល់ចប់ព្រោះខ្ញុំចង់បង្ហាញថា ជីវិតយើងរស់នៅមិនត្រូវអស់សង្ឃឹមឡើយ។ យើងត្រូវរស់នៅប្រឈមមុខចំពោះការពិត បើដួលយើងត្រូវហ៊ានក្រោកដើរបន្តទៀត។ ពេលខ្ញុំសរសេរសាច់រឿងនេះ ខ្ញុំបានស្វែងយល់អំពីជីវភាពរស់នៅប្រចាំថ្ងៃនៅក្នុងរបបខ្មែរក្រហម តាមរយៈការនិទានប្រាប់ពីលោកយាយ និងម្ដាយខ្ញុំ។ ឪពុកម្ដាយខ្ញុំ សុទ្ធតែធ្លាប់ឆ្លងកាត់របបនេះ។ គាត់ប្រាប់ថា ជីវិតរស់នៅប្រចាំថ្ងៃនៅពេលនោះលំបាកណាស់ ពោលគឺគ្មានអាហារហូបចុកគ្រប់គ្រាន់ និងត្រូវធ្វើការហួសកម្លាំងជាដើម។ ខ្ញុំយល់ថាការសរសេររឿងអំពីរបបខ្មែរក្រហម អាចចូលរួមចំណែកក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងជួយឲ្យអ្នកដែលបានរួចរស់ជីវិតពីរបបនេះធូរស្បើយក្នុងចិត្ត»។

ជើងមេឃពណ៌ក្រហម គឺជាកំណត់ត្រាដែលនិយាយអំពីមនោសញ្ចេតនាសោកសៅនៅអតីតកាល។ រស្មី គឺជានាមតួអង្គនៅក្នុងរឿង ដែលកាលនោះមានអាយុ ១០ឆ្នាំនៅឡើយ។ រស្មី និងគ្រួសារ ត្រូវបានជម្លៀសពីភ្នំពេញទៅខេត្តព្រៃវែង។ ការចងចាំរបស់តួអង្គគឺជាអារម្មណ៍ជ្រាលជ្រៅ និងភក្ដីភាព ចំពោះមនុស្សជាទីស្រលាញ់ដែលបានចែកឋានទៅ ដោយសង្ឃឹមថាពួកគាត់នឹងបានសេចក្ដីសុខជារៀងរហូត។ អ្នកនិពន្ធប្រើប្រាស់សោភ័ណ្ឌធម្មជាតិនាពេលសូរិយាអស្ដង្គត ដោយបន្សល់ទុកនូវពណ៌ក្រហមឆ្អិនឆ្អៅក្រាលគ្របជើងមេឃ ជាចំណងជើងរឿង។

ព្រះអាទិត្យលិច ប្រៀបបាននឹងមនុស្សជាទីស្រលាញ់ដែលបាត់បង់ទៅដោយអយុត្តិធម៌នៅក្នុងសម័យ ប៉ុល ពត។ ចំណែករស្មីពណ៌ក្រហម ប្រៀបបាននឹងអនុស្សាវរីយ៍ដែលហាក់ដូចជានៅថ្មីៗ ទោះជាពេលវេលាកន្លង

ផុតទៅជាង ៤០ឆ្នាំ ហើយក្តី។ អនុស្សាវរីយ៍ជាច្រើន មិនអាចលុបចេញពីជម្រៅដួងចិត្តរបស់ រស្មី។

ការហូបចុក ការរំពុកឈ្មោះឪពុកដែលស្លាប់ទៅ ការមើលថែកូនពេលឈឺ និងការបើកភ្លើងពេលយប់ជ្រៅជាដើម សុទ្ធសឹងជាអំពើឧក្រិដ្ឋកម្ម ដោយចោទថាខ្មាំងប្រឆាំងនឹងបដិវត្តន៍ ហើយសុទ្ធតែអាចបាត់បង់អាយុជីវិត។ មួយវិញទៀត អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម បានយកអ្នកដទៃធ្វើជាម្តាយ ជាឪពុក និងជាញាត្តិសណ្តាន នៅពេលសមាជិកគ្រួសារ និងបងប្អូនរបស់ពួកគេ បែកបាក់និងព្រាត់ប្រាស់គ្នា ដោយមិនដឹងថានៅរស់ ឬស្លាប់នោះទេ។

ប្រហែលជាអ្នកនិពន្ធយល់ថា ដើងមេឃពណ៌ក្រហមដ៏ស្រស់ស្អាតនាពេលសូរិយាអស្តង្គត អាចជួយព្យាបាលនិងផ្សះផ្សារបួសដួងចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឲ្យបានធូរស្រាលមួយកម្រិតពីសំណល់អតីតកាលដ៏សែនសោកសៅ។

គួររំពុកថា នៅក្រោមការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ប្រជាជនកម្ពុជាប្រមាណ ២លាននាក់ បានស្លាប់បាត់បង់ជីវិតដោយសារការបង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ ការធ្វើទារុណកម្ម និងការសម្លាប់។

ម្យ៉ាងទៀត បុគ្គលដែលមានការចេះដឹងទាំងឡាយ រួមទាំងអ្នកនិពន្ធផង សុទ្ធតែជាមុខសញ្ញាដែលអង្គការត្រូវកំទេចចោលដោយចោទថាជាខ្មាំង។ កវីនិពន្ធ អ្នកចម្រៀង តួសម្តែង និងសិល្បៈករជាច្រើននាក់បានបាត់បង់ជីវិតនៅសម័យនោះ។

## ចម្រៀង បដិវត្តន៍ខ្មែរក្រហម
## សូមជូនពរចំពោះបងប្អូនភូមិភាគពាយ័ព្យ

ភូមិភាគយ័ព្យជាប់ព្រំដែនថៃ
ពាយ័ព្យញញឹមប៉ប្រិមថ្ងាស្រស់
មើលន៍បាត់ដំបងដងស្ទឹងសង្កែ
ប្រព័ន្ធប្រឡាយកាត់វាលជាកង់
ពីក្រគរដល់មោងមង្គលបូរី
បងប្អូនកសិករជិហរសម្រុក
ទាំងលាចសំឡូតទាំងព្រះនេត្រព្រះ
ធម្មជាតិអនុគ្រោះទាំងគុណភាពដី
ពាយ័ព្យជាបង្អែកផលិតកម្ម
បងប្អូនពាយ័ព្យអាយុយឺនយូរ
បន្តសម្រុកលើកភ្លឺស្រែថ្មី
ខ្វាត់ខ្វែងពេញដីឈើត្រង់ក្រឡា
បងប្អូនប្រែក្លាយភូមិភាគបងប្អូន
សាងមាតុភូមិឲ្យស្រស់ប្រិមប្រិយ
ឲ្យសមតាមពាក្យស្លោកថ្មីផងយើង
ប្រឡាយខ្វាត់ខ្វែងដូចពាយ័ព្យផង

កម្ពុជាសម័យចម្រើនលោតផ្លោះ
មានភ្លឺស្រែខ្ពស់ក្រឡាឈើត្រង់ៗ
ពោធិ៍សាត់ផងដែរកាន់តែផូរផង់ៗ
ខ្ពស់មាំត្រង់ៗបីដូចបន្ទាត់ៗ
ស៊ីសូផុនថ្មីភ្នំស្រុកថ្មពួក
កែប្រែភូមិស្រុកជាជនបទថ្មីៗ
បងប្អូនជម្នះខបសត្រូយកជ័យ
ស្រែធំធេងក្រហុចផលស្រូវល្អ។
កម្ពុជាឧត្តមយើងខ្ញុំជូនពរ
សុខភាពបរិបូរណ៍កម្លាំងខ្លាំងក្លា។
សម្រុកប្រឡាយគំរូកម្ពុជា
រួមសាងកម្ពុជាប្រជាធិបតេយ្យ។
ទៅជាប្រព័ន្ធភ្លឺស្រែថ្មីៗ
ល្អលើសសម័យអង្គរច្រើនដង។
ភ្លឺស្រែរុងរឿងដូចបាត់ដំបង
កម្ពុជាបញ្ចាំងចម្រើនរៀងអើយ។

# កាំង ហ្កេកអ៊ាវ ហៅ ឌុច

## អតីតប្រធានមន្ទីរសន្តិសុខ ស-២១

ហូ ថុណា



រូបខាងឆ្វេង៖ កាំង ហ្កេចអ៊ាវ ហៅ ឌុច និងសមមិត្ត សុខ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កាំង ហ្កេចអ៊ាវ ហៅ ឌុច នៅសាលាក្តីខ្មែរក្រហម នៅឆ្នាំ២០០៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាំង ហ្កេកអ៊ាវ ហៅ ឌុច កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ ក្នុងភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ ឌុច កើតនៅក្នុងគ្រួសារមួយដែលមានសមាជិក៧នាក់ ហើយគាត់គឺជាកូនច្បង និងកូនប្រុសតែមួយគត់របស់គ្រួសារ។

## កុមារភាព និងប្រវត្តិសិក្សា

នៅក្នុងគ្រួសារ ឌុច គឺជាក្មេងស្មោះត្រង់ ស្លូតបូតម៉ឺងម៉ាត់នឹងការងារ ចេះយោគយល់គ្នា ចេះគោរពចាស់ទុំ មានចិត្តទូលាយ និងជាសិស្សពូកែនៅក្នុងថ្នាក់រៀន។ ឌុច ក៏មិនដែលចេះលាក់លៀម ឬបិទបាំងទាក់ទងនឹងចំណេះដឹងរបស់គាត់ដែរ ផ្ទុយទៅវិញ ប្រសិនបើមានមិត្តភក្តិ

រួមថ្នាក់សួរចង់ដឹងពីចម្ងល់អ្វីមួយគាត់តែងតែពន្យល់ប្រាប់ជានិច្ចៗ ឌុច មិនសូវមានមិត្តភក្តិច្រើនទេ ជាពិសេសគាត់មិនដែលខ្វាយខ្វល់ពីស្នេហាឡើយៗ ឌុច គឺជាសិស្សល្អម្នាក់នៅក្នុងថ្នាក់រៀន ព្រោះគាត់តែងតែមករៀនទៀងទាត់ពេលវេលាជានិច្ច ហើយក៏មិនដែលគេចម៉ោងសិក្សាដែរៗ មិនតែប៉ុណ្ណោះ ឌុច ក៏ជាក្មេងដែលងាយស្រួលក្នុងការហូបចុក ព្រោះគាត់មិនចេះរើសម្ហូបអាហារនិងមិនចេះត្អូញត្អែរៗ ឌុច គឺជាក្មេងដែលចេះជួយធ្វើការងារផ្ទះសម្បែង ព្រមទាំងស្រឡាញ់បងប្អូនឪពុកម្ដាយរបស់ខ្លួន និងមិនសូវចេះមាត់កប៉ុន្មានទេ ហើយនៅពេលទំនេរពីការសិក្សា គាត់តែងតែទៅសូត្រនៅមាត់ស្ទឹងៗ ឌុច គឺជាសិស្សពូកែផ្នែកគណិតវិទ្យា ដោយបានជាប់ចំណាត់ថ្នាក់លេខ ១ ប្រចាំឆ្នាំក្នុងអនុវិទ្យាល័យកំពង់ធំៗ រីឯសកម្មភាពនៅក្នុងថ្នាក់រៀនរបស់ ឌុច គាត់តែងតែព្យាយាមធ្វើលំហាត់គណិតវិទ្យាយ៉ាងស្ងៀមស្ងាត់ដោយមិនអើពើឬលេងសើចជាមួយនឹងមិត្តរួមថ្នាក់របស់គាត់ឡើយៗ ឌុច មិនត្រឹមតែជាសិស្សពូកែខាងគណិតវិទ្យាប៉ុណ្ណោះទេ គាត់ក៏ជាសិស្សដែលមានភាពវៃឆ្លាតក្នុងការរៀនភាសាអង់គ្លេស និងភាសាបារាំង ដោយសារតែការចងចាំដ៏ល្អរបស់គាត់ពីកំណើតៗ មិនតែប៉ុណ្ណោះ ឌុច ក៏ជាក្មេងស្លូតបូតមិនចេះខឹង ឬស្អប់ និងគុំគួននរណាទេ ប្រសិនបើមាននរណាម្នាក់ធ្វើឲ្យគាត់ខឹង ឬមិនសប្បាយចិត្ត គាត់ក៏មិនដែលបង្ហាញនូវអាកប្បកិរិយាមិនល្អចំពោះអ្នកទាំងនោះដែរ ផ្ទុយទៅវិញបែរជាគាត់បានផ្ដល់នូវស្នាមញញឹមរីតតែខ្លាំងឡើងៗ ឌុច បានបញ្ចប់ការសិក្សារបស់គាត់ជាបន្តបន្ទាប់នៅខេត្តកំពង់ធំ និងបន្ទាប់មកនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងរាជធានីភ្នំពេញៗ

## ប្រវត្តិសកម្មភាពពេលចូលបដិវត្តន៍

រហូតដល់ឆ្នាំ១៩៦២ ឌុច បានមកបន្តការសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងរាជធានីភ្នំពេញ ហើយក្រោយមកគាត់ក៏បានប្រឡងធ្លាក់មធ្យមសិក្សាទុតិយភូមិមួយឆ្នាំ ក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិនេះៗ ដោយសារនាពេលនោះ ឌុច មមាញឹកជាមួយនឹងការងារបដិវត្តន៍ទើបធ្វើឲ្យគាត់មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាៗ ប៉ុន្តែ ឌុច ក៏មិនបានបោះបង់ការសិក្សារបស់គាត់ដែរ បែរជាគាត់បានខំប្រឹងប្រែងរៀនសូត្ររហូតដល់ប្រឡងជាប់មធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ១៩៦៤ៗ ក្នុងឆ្នាំនោះដែរ ឌុច ក៏បានសម្រេចចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហមចាប់តាំងពីពេលនោះមកៗ ក្នុង



កាំង ហ្កេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ នៅសាលាក្ដីខ្មែរក្រហមៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការចូលបម្រើបដិវត្តន៍នេះ ឌុច បានទទួលមនោគមវិជ្ជា ក៏ដូចជាការអប់រំពីសំណាក់លោកគ្រូរបស់គាត់ ឈ្មោះ សុន សេន។ ក្រៅពីការងារក្នុងជួរបដិវត្តន៍ ឌុច ក៏បានចូលរៀនគរុកោសល្យអស់រយៈពេលមួយឆ្នាំថែមទៀត។ ដល់ឆ្នាំ១៩៦៥ ឌុច ត្រូវបានក្រសួងអប់រំចាត់តាំងឲ្យទៅបង្រៀននៅអនុវិទ្យាល័យស្គន់ផ្នែកគណិតវិទ្យា បន្ទាប់ពីគាត់ចេញពីវិទ្យាស្ថានគរុកោសល្យ។ ឌុច បានបញ្ជាក់ថា សម្រាប់ខ្លួនគាត់ពិតជាមានមនោសញ្ចេតនានឹងរបបកុម្មុយនីស្តខ្លាំងណាស់ ចាប់តាំងពីឆ្នាំ ១៩៥៥ មកម្ល៉េះ។ ដោយមូលហេតុនោះ គឺមានគ្រាមួយគាត់បានឮដំណឹងថា ម៉ៅ សេទុង ដែលបានផ្ដួលរំលំរបបរាជានិយមក្នុងឆ្នាំ១៩៤៩ បានដោះស្រាយជីវភាពប្រជាជនក្រីក្រនៅក្នុងប្រទេសចិន ឲ្យមានការហូបចុកគ្រប់គ្រាន់ និងមានជីវភាពធូរធារ។ ចំពោះដំណឹងដែលបានលេចឮខាងលើ គឺ ឌុច ឮតាមរយៈបងប្អូនជីទួតមួយរបស់គាត់ដែលរស់នៅស្រុកចិន ហើយវាក៏ជាការជំរុញទឹកចិត្តគាត់ឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៦៤។ ឌុច បានបន្តថា គាត់ពិតជាស្រឡាញ់ចូលចិត្តរាល់ស្នាដៃរបស់ ម៉ៅ សេទុង ណាស់ ហើយរាល់ការបោះពុម្ពផ្សាយសៀវភៅ ឬឯកសារផ្សេងៗដែលទាក់ទងនឹងនយោបាយ ឬទ្រឹស្តី គឺ ឌុច តែងតែទិញសៀវភៅទាំងនោះយកមកអានដើម្បីជាចំណេះដឹង។ តមកទៀត នៅក្នុងអំឡុងពេលដែល ឌុច ចូលបម្រើបដិវត្តន៍ គឺគាត់មានតួនាទីដើរផ្សព្វផ្សាយ និងចែកខិត្តប័ណ្ណ ដែលមានបក្ខពួកជាងដប់នាក់ ក្នុងគោលបំណងប្រកាសជាដំណឹងដល់ប្រជាជនកម្ពុជាទូទៅថា ឧត្តមសេនីយ៍ លន់ នល់ នឹងធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ចេញពីដំណែងនៅឆ្នាំ១៩៧០។


កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ នៅសាលាក្ដីខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រហូតដល់ខែកក្កដា ឆ្នាំ១៩៦៧ ឌុច បានទៅរៀនសូត្រវគ្គសម្ងាត់នៅផ្លូវលេខ ១៦៣ ម្ដុំផ្សារទួលទំពូង ដែលមានរយៈពេលប្រហែលជាពីរខែ ក្រោយមក ទើបបក្សកុម្មុយនីស្តបាន បញ្ចូល ឌុច ជាបក្សជនពេញសិទ្ធិ។ ក្នុងរយៈពេលជិតពីរខែ ឌុច ក៏បានរៀនពីលក្ខន្តិកៈបក្សក្នុងឆ្នាំ១៩៦០ រៀនពីមាគ៌ាជាយុទ្ធសាស្ត្រ ឬមាគ៌ាជាយុទ្ធវិធីប្រមូលផ្ដុំកម្លាំងរណសិរ្ស រៀនពីទស្សនវិជ្ជា និងការតស៊ូវណ្ណៈ និងរៀនអំពីឯកសារសម្ងាត់របស់បក្សផ្សេងៗទៀត។ ឌុច ក៏បានបន្តទៀតថា មានទ្រឹស្តីមួយចំនួនដែលសរសេរដោយមេដឹកនាំ ប៉ុល ពត គឺមានទ្រឹស្តី «យុទ្ធវិធីសង្គ្រាមឈ្លប» «សង្គ្រាមប្រជាជនរបស់បក្ស» «សីលធម៌បដិវត្តន៍» និង «គោលនយោបាយមួយចំនួនរបស់បក្ស»។ បន្ទាប់ពីរៀនចប់វគ្គសម្ងាត់រួចមក ឌុច ក៏ត្រូវបានថ្នាក់លើបញ្ជូនគាត់ឲ្យទៅធ្វើការនៅទីជនបទ ដោយថ្នាក់លើបានលើកនូវបញ្ហាពីរយ៉ាងក្នុងការពន្យល់ ឌុច គឺបញ្ហាទីមួយ បក្សត្រូវកសាងមូលដ្ឋានឈ្លបនៅជនបទ និងបញ្ហាទីពីរគឺពួកអនុជនដែលតស៊ូនៅទីក្រុងបានបែកការណ៍ហើយ។ ដូច្នេះទើបបក្សកុម្មុយនីស្តបានសម្រេចចិត្តជម្លៀស ឌុច ក៏ដូចជាអនុជនផ្សេងៗទៀតឲ្យទៅជនបទដើម្បីការពារសុវត្ថិភាព និងដើម្បីជួយកសាងមូលដ្ឋានឈ្លប។ បន្ទាប់មក ឌុច បានចាប់ផ្ដើមការងារដំបូងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦៧។ មួយរយៈក្រោយមក ឌុច ក៏ចាប់ផ្ដើមធ្វើសន្និបាតបង្កបង្កើតសាខាមួយនៅស្រុកចម្ការលើ ក្នុងខេត្តកំពង់ចាម។ នៅពេលដែល ឌុច បានធ្វើសន្និបាតចប់ គាត់ក៏ត្រូវបានកងកម្លាំងប៉ូលីសក្នុងរបបសង្គមរាស្ត្រនិយម ចាប់គាត់ដាក់ពន្ធនាគារនៅថ្ងៃទី ០៩ ខែមករា ឆ្នាំ១៩៦៨ ដោយបានចោទប្រកាន់គាត់ថា ជា «ខ្មែរក្រហម» ឬ «អ្នកចូលដៃដើងជាមួយនឹងបរទេសក្នុងគោលបំណងបំផ្លាញសេចក្ដីសុខសាន្តក្នុងព្រះនគរ» ។ ឌុច បានជាប់ពន្ធនាគារអស់រយៈពេល២៧ខែ។ រហូតដល់ថ្ងៃទី០៣ ខែមេសា ឆ្នាំ១៩៧០ ទើបប្រធានាធិបតី លន់ នល់ ដែលទើបតែឡើងកាន់កាប់អំណាចបានប្រហែលបីសប្ដាហ៍ បានសម្រេចចិត្តដោះលែង ឌុច ឲ្យមានសេរីភាពឡើងវិញ។

បន្ទាប់ពីចេញពីពន្ធនាគារមួយរយៈ ឌុច ក៏មកស្នាក់អាស្រ័យនៅវត្តខណ្ឌាលោម កុដិលេខ១៣ ស្ថិតនៅក្នុងរាជធានីភ្នំពេញ ដែលជាកន្លែងស្នាក់អាស្រ័យចាស់របស់គាត់។ ក្នុងរយៈពេលនោះ ឌុច នៅតែបន្តការចូលរួមធ្វើសកម្មភាពជាមួយបក្សកុម្មុយនីស្តដដែល ដោយបានដើរប្រមែប្រមូលបក្ខពួកដែលជាប់ក្នុងពន្ធនាគារទាំងប៉ុន្មានមកជួបជុំគ្នា ក្នុងគោលបំណងផ្សារភ្ជាប់ខ្សែរយៈឡើងវិញ។

## ប្រវត្តិសកម្មភាពចន្លោះពីឆ្នាំ១៩៧០-១៩៧៥

រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧០ ឌុច និងបក្ខពួកបានចាកចេញពីទីក្រុងភ្នំពេញ តាមផ្លូវព្រែកប្រា និងឆ្លងកាត់ចំពុះក្អែក រហូតដល់ភូមិថ្មដា (តំបន់រំដោះ) ទើបគាត់ឈប់សម្រាកនៅទីនោះ។ ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧១ ឌុច បានទៅដល់ភូមិភាគដែលទើបតែបែងចែកថ្មី គឺភូមិភាគពិសេស។ ពេលនោះ ឌុច ក៏ត្រូវបាន វន វ៉េត មាននាទីជាសមាជិកមជ្ឈិមបក្ស បានប្រគល់តួនាទីឲ្យធ្វើជាប្រធានមន្ទីរសន្តិសុខ ម-១៣ ឬក៏មន្ទីរនគរបាលភូមិភាគពិសេស។ ចំពោះតួនាទីជាប្រធានមន្ទីរសន្តិសុខ ឌុច មានភារកិច្ចចាំទទួលមនុស្សទាំងអស់ដែលយោធាខ្មែរក្រហមចាប់បាននៅសមរភូមិដោយចោទថា ជា «គិញ» ផ្ញើមកឲ្យសួរចម្លើយរួចហើយកម្ទេចចោល ប៉ុន្តែមុននឹងកម្ទេចគឺត្រូវធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃជាមុនសិន។ នៅអំឡុងពេលនោះ មនុស្សភាគច្រើនដែលចូលក្នុងតំបន់រំដោះ ត្រូវបានខ្មែរក្រហមចាត់ទុកថា ជា «ខ្មាំង» ឬជា «គិញ» សម្ងាត់។ ឌុច បានបញ្ជាក់ថា ចំពោះមន្ទីរសន្តិសុខ ម-១៣ គឺមានការផ្លាស់ប្តូរទីកន្លែងជាញឹកញាប់ ដោយដំបូងមានទីតាំងនៅម្តុំភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ក្រោយមកដោយសារនៅទីនោះខ្វះទឹកប្រើប្រាស់ ទើប ឌុច បានសម្រេចចិត្តផ្លាស់ប្តូរទីកន្លែងទៅជើងភ្នំពិស ត្រង់ម្តុំ ទួលស្វាយមាស និងតាលាវ។ នៅទីនោះហើយដែលមានអ្នកទោសលួចរត់ចេញពីគុកក្នុងឆ្នាំ១៩៧៣។ បន្ទាប់ពីហេតុការណ៍នោះ ឌុច ក៏បានស្នើសុំ វន វ៉េត ឲ្យដាក់ទោសខ្លួន ព្រោះ ឌុច គិតថាវាគឺជាកំហុសរបស់គាត់។ ប៉ុន្តែ វន វ៉េត ក៏មិនព្រមទទួលនូវសំណើរបស់ ឌុច ឡើយ។ ក្រោយមក ឌុច ក៏បានផ្លាស់ទៅរស់នៅក្នុងភូមិត្រពាំងច្រាប រហូតដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។

## ប្រវត្តិសកម្មភាពចន្លោះពីឆ្នាំ១៩៧៥-១៩៧៩

នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង លើកងកម្លាំងរបស់រដ្ឋាភិបាល លន់ នល់។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាចបានបីថ្ងៃ ឌុច ក៏ត្រូវបាន សុន សេន មាននាទីជាអនុលេខាភូមិភាគ បានកោះហៅឲ្យមកចូលរៀនវគ្គសិក្សាថ្មីមួយនៅទីក្រុងភ្នំពេញ ហើយគាត់ក៏បានស្នាក់នៅមន្ទីរនីសាររបស់ សុន សេន ដែលស្ថិតនៅស្ថានីយរថភ្លើងក្រុងភ្នំពេញ។ បន្ទាប់ពីបញ្ចប់វគ្គសិក្សារួចមក ឌុច ត្រូវបាន សុន សេន បញ្ជូនឲ្យទៅនៅជាមួយនឹង ណាត។ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ សុន សេន បានហៅ ឌុច និង ណាត ឲ្យមកជួបនៅស្ថានីយរថភ្លើង នៅជាន់ខាងលើ ដើម្បីខ្ទេសនាមក្នុងការបង្កើតមន្ទីរសន្តិបាល ឬមន្ទីរសន្តិសុខ ស-២១ នាពេលខាងមុខ។ រហូតដល់ពាក់កណ្តាលខែតុលា ឆ្នាំ១៩៧៥ ឌុច បានក្លាយជាអនុលេខាមន្ទីរស-២១ ឬហៅថា អនុប្រធានមន្ទីរសន្តិសុខ ស-២១ ដោយមាន ណាត ជាប្រធាន។ ដល់ខែមីនា ឆ្នាំ១៩៧៦ សុន សេន បានដក ណាត ចេញពីប្រធានសន្តិសុខ ស-២១ ហើយ ឌុច ក៏បានឡើងដំណែងជាប្រធានមន្ទីរសន្តិសុខ ស-២១ រហូតមក។ ឌុច បានបញ្ជាក់ថា ចំពោះតួនាទីនៅក្នុងមន្ទីរសន្តិសុខ ស-២១ ដំបូងឡើយគឺប្រមែប្រមូល សាស្ត្រាចារ្យ បញ្ញវន្ត វិជ្ជបណ្ឌិត គ្រូបង្រៀន ឬអ្នកដែលមានចំណេះដឹងផ្សេងទៀត ដើម្បីចាប់បញ្ចូលមកក្នុងមន្ទីរសន្តិសុខ ស-២១ នេះ។ ដល់ក្រោយមក មន្ទីរសន្តិសុខ ស-២១ ក៏បានចាប់បញ្ចូលរួមទាំង កម្មករ កម្មកររោងចក្រក្រដាស អ្នកនេសាទថៃ ជនជាតិចាម ជនបរទេស ឈ្លើយសឹកវៀតណាម កម្មាភិបាល និងយោធាខ្មែរក្រហម ដែលត្រូវបានចោទថាក្បត់។ អ្នកទោសដែលត្រូវបញ្ចូលនៅក្នុងមន្ទីរសន្តិសុខ ស-២១ គឺជៀសមិនផុតពីការធ្វើទារុណកម្មសួរចម្លើយ និងកម្ទេចចោលទេ ពីព្រោះនេះគឺជាគោលបំណងរបស់មន្ទីរសន្តិសុខ ស-២១ ដែលចាំបាច់ត្រូវមានចម្លើយសារភាពរបស់អ្នកទោស ដើម្បីជូនទៅ

អង្គការថ្នាក់លើក្នុងការត្រិះរិះពិចារណា និងសម្រេចៗ អ្នកទោសប្រមាណជាង ១៨,០០០ នាក់ ដែលត្រូវបានឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ស-២១។ ចំពោះការធ្វើទារុណកម្មសួរចម្លើយរបស់មន្ទីរសន្តិសុខ ស-២១ ត្រូវបានបែងចែកជាបីក្រុម រួមមាន ៖ ក្រុមត្រជាក់ ក្រុមក្ដៅ និងក្រុមអង្កៀម។ មិនតែប៉ុណ្ណោះ រាល់អ្នកទោសទាំងអស់ដែលឃុំខ្លួនក្នុងមន្ទីរសន្តិសុខ ស-២១ គឺត្រូវបានថតរូបទុកដើម្បីការពារភាពចន្លោះប្រហោង ព្រោះប្រសិនបើមានអ្នកទោសណាម្នាក់លួចរត់ គឺត្រូវយករូបថតអ្នកទោសនោះ ទៅផ្ដិតជូនអង្គភាពនៅទូទាំងប្រទេសដើម្បីងាយស្រួលតាមរក។ ប៉ុន្តែក៏មានអ្នកទោសមួយចំនួនដែលថ្នាក់លើចាត់ទុកថាជាអ្នកទោសពិសេស ក៏មិនត្រូវបានអនុញ្ញាតឲ្យថតរូបអ្នកទោសនោះដែរ ព្រោះខ្លាចបែកការណ៍។ ឧទាហរណ៍ ដូចជា អ្នកទោសឈ្មោះ កុយ ធួន ដែលមាននាទីជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម (មជ្ឈិមបក្ស)។ ចំពោះអ្នកទោសដែលថ្នាក់លើចាត់ទុកថា ជាអ្នកទោសពិសេសនោះ គឺត្រូវមានចំណាររពីកម្មាភិបាលថ្នាក់លើគឺ សុន សេន។ ឌុច បានបន្ថែមថា ចំពោះខ្លួនគាត់ផ្ទាល់គឺមានតួនាទីអាន និងសង្ខេបចម្លើយសារភាពរបស់អ្នកទោសដែលបានសួរចម្លើយរួច បន្ទាប់មកគាត់នៅមានភារកិច្ចរាយការណ៍អំពីចម្លើយសារភាពជាប់ជាប្រចាំទៅថ្នាក់លើ នឹងត្រូវត្រួតពិនិត្យមើលអ្នកទោសដែលសួរចម្លើយរួច ដើម្បីបញ្ជូនទៅជើងឯក។ មិនតែប៉ុណ្ណោះ ឌុច ក៏នៅមានភារកិច្ចរៀបចំទទួលអ្នកទោសដែលគេបញ្ជូនមកថ្មីៗ ថាត្រូវចាត់ចែងដូចម្ដេចទៀត។ ក្រៅពីការងារទាំងនេះ ឌុច នៅមានតួនាទីបង្រៀនដល់កម្មាភិបាលថ្នាក់ក្រោម អំពីគោលនយោបាយរបស់បក្ស អំពីរបៀបសួរចម្លើយ អំពីស្មារតីប្រុងប្រយ័ត្នក្នុងរឿងសួរកុំឲ្យសួរពាសវាលពាសកាល។ ឌុច បានធ្វើជាប្រធានមន្ទីរសន្តិសុខ ស-២១ និងធ្វើសកម្មភាពទាំងអស់នេះ រហូតដល់ខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។

## ប្រវត្តិសកម្មភាពចន្លោះពីឆ្នាំ១៩៧៩ ដល់បច្ចុប្បន្ន

បន្ទាប់ពីខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ឌុច ក៏បានរត់ទៅជ្រកកោនជាមួយនឹងឈ្មោះ ប៉ាល់ ហៅ ហួត ហេង នាទីអនុលេខាភូមិភាគបស្ចិម។ ដល់ក្រោយមក



មន្ទីរសន្តិសុខស-២១។ (ហូ វ៉ាន់តី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឌុច ក៏កៀសខ្លួនបន្តទៀតដោយសុំស្នាក់អាស្រ័យជាមួយនឹងឈ្មោះ សារុន នាទីអនុលេខាភូមិភាគពាយ័ព្យ។ រហូតដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៦ សុន សេន បានហៅ ឌុច ឲ្យទៅធ្វើការជាមួយ រួចហើយបានបញ្ជូន ឌុច ឲ្យទៅបង្រៀនភាសាខ្មែរដល់និស្សិតចិននៅទីក្រុងប៉េកាំង។ ឌុច បានទៅបង្រៀននៅប៉េកាំងអស់រយៈពេលពីរឆ្នាំ ហើយគាត់ក៏វិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងឆ្នាំ១៩៨៨។ បន្ទាប់មក ឌុច ក៏បានចូលធ្វើការនៅក្នុងមន្ទីរក-១៨ ដែលនៅក្រោមការគ្រប់គ្រងរបស់ អាំត និង សុន សេន។ ដល់ឆ្នាំ១៩៩២ ឌុច បានផ្លាស់ទីលំនៅទៅរស់នៅក្នុងភូមិផ្កាំ ឃុំផ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ រហូតដល់ឆ្នាំ១៩៩៦ ឌុច លែងនៅក្នុងចលនាខ្មែរក្រហមទៀតហើយ។ ក្រោយមក ឌុច ក៏បានជួបជាមួយនឹងក្រុមផ្សព្វផ្សាយសាសនាគ្រិស្តជនជាតិអាមេរិកនៅភាគពាយ័ព្យប្រទេសកម្ពុជា ហើយក៏បានក្លាយខ្លួនជាអ្នកប្រតិបត្តិសាសនាគ្រិស្តម្នាក់។ ក្នុងឆ្នាំ១៩៩៧ ទើបគាត់បានសម្រេចចិត្តទៅរស់នៅក្នុងស្រុកសំឡូត ខេត្តបាត់ដំបង វិញ។ ដោយសារនាពេលនោះមានការចាប់ផ្ដើមជាថ្មីក្នុងការប្រយុទ្ធគ្នារវាងកងកម្លាំងខ្មែរក្រហម ជាមួយនឹងកងកម្លាំងខាងរដ្ឋាភិបាល ទើបគេជម្លៀស ប្រជាជនចេញពីក្នុងឃុំនោះ។ ក្នុងអំឡុងពេលដែល ឌុច មករស់នៅក្នុងស្រុកសំឡូត គាត់ក៏បានប្រកបរបរចញ្ចឹមជីវិតដោយធ្វើជាគ្រូបង្រៀន និងមាននាទីជាប្រធានការិយាល័យអប់រំស្រុក។ រហូតដល់ឆ្នាំ១៩៩៩ ឌុច ត្រូវបានអ្នកសារព័ត៌មានប្រទះឃើញនៅក្នុងស្រុកសំឡូត ហើយក៏ត្រូវបានអាជ្ញាធរកម្ពុជាចាប់ខ្លួនចាប់តាំង

ពីពេលនោះមក។ ឌុច ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់តុលាការយោធាចាប់តាំងពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៩ រហូតដល់គាត់ត្រូវបានផ្ទេរពីតុលាការយោធាមកមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ.វ.ត.ក. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ដើម្បីបើកការជំនុំជម្រះទៅលើបទឧក្រិដ្ឋកម្មរបស់គាត់ដែលបានប្រព្រឹត្តមកលើអ្នកទោសនៅមន្ទីរសន្តិសុខស-២១។

រហូតដល់ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឌុច ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញថាមានទោសដោយយោងទៅលើមាត្រា ៥, ៦ និង២៩ (ថ្មី) នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅទីក្រុងភ្នំពេញក្នុងទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដូចខាងក្រោម ៖

**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖**

- ការរើសអើងដោយសារហេតុផលនយោបាយ
- ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត)
- ការធ្វើឲ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម និង
- អំពើអមនុស្សធម៌ផ្សេងៗទៀត

**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ៖**

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់
- និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

តាមបទឧក្រិដ្ឋកម្មដូចដែលបានរៀបរាប់ខាងលើ



កាំង ហ្គេចអ៊ាវ ហៅ ឌុច នៅស្រុកសំឡូត ខេត្តបាត់ដំបង នៅមុនពេលអាជ្ញាធរចាប់ខ្លួន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គជំនុំជម្រះតុលាការកំពូលបានផ្តន្ទាទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច កាលពីថ្ងៃសុក្រ ទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

រហូតដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ឌុច ត្រូវបានផ្ទេរពីពន្ធនាគាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា (អ.វ.ត.ក) ទៅកាន់ពន្ធនាគារខេត្តកណ្តាល ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២។

ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៨ ឌុច មានអាការៈហេវហត់ ថប់ដង្ហើម ហើយក្រោយមកពេទ្យប្រចាំការរបស់គាត់ ក៏បានស្នើសុំឲ្យបញ្ជូនគាត់ទៅព្យាបាលនៅពេទ្យជ័យជម្នះ ក្នុងរាជធានីភ្នំពេញ។ នៅថ្ងៃទី២១ ក្នុងខែឆ្នាំដដែល មន្ទីរពេទ្យជ័យជម្នះបានសម្រេចបញ្ជូន ឌុច ឲ្យទៅសម្រាកព្យាបាលបន្តនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

នៅយប់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ ឌុច បានធ្លាក់ខ្លួនឈឺធ្ងន់ ហើយត្រូវបានបញ្ជូនមកសង្គ្រោះបន្ទាន់ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ម្តងទៀត។

ពីថ្ងៃក្រោយមក គឺនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ ឌុច បានស្លាប់នៅមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ដោយសារជំងឺរលាកសួតធ្ងន់ធ្ងរ បន្ទាប់ពីគាត់មានជំងឺសួតរ៉ុាំរ៉ៃពីមុនមកដោយសារតែការជក់បារី និងជំងឺហឺត។

សពរបស់ ឌុច នឹងត្រូវបានគណៈកម្មការពិសេស នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ ធ្វើកោសល្យវិច្ច័យ បន្ទាប់មកនឹងប្រគល់ជូនទៅក្រុមគ្រួសារដើម្បីយកទៅធ្វើបុណ្យ។

# នៅពេលនឹកឃើញរឿងរ៉ាវក្នុងរបបខ្មែរក្រហមខ្ញុំស្រក់ទឹកភ្នែក

*សោម ប៊ុនថន*



*ហោ ខេង ពេលផ្តល់បទសម្ភាសន៍ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅផ្ទះរបស់គាត់ស្ថិតនៅឃុំគរគីសោម ស្រុករំដួល ខេត្តស្វាយរៀង កាលពីឆ្នាំ២០១៥។ (សោម ប៊ុនថន/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ហោ ខេង កើតឆ្នាំ១៩២៨ អំឡុងពេលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមនិយមបារាំង។ នៅសម័យនោះ ខ្ញុំបានចូលរៀនភាសាបារាំងដំបូងនៅថ្នាក់កុមារដ្ឋាន ហើយតមកក៏ចូលរៀនដល់ថ្នាក់បឋមសិក្សា ដូច្នេះខ្ញុំអាចនិយាយភាសាបារាំងបានខ្លះៗ។ ក្រៅពីរៀនអក្សរបារាំង ខ្ញុំត្រូវបានគ្រូជនជាតិបារាំងឲ្យទន្ទេញ និងសូត្រមេលេខពីលេខ២ ដល់លេខ៩ ត្រឡប់ចុះឡើងរៀងរាល់ម៉ោងសិក្សានៅក្នុងថ្នាក់។ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ ១៩៥៣ ខ្ញុំបានប្រកបរបរជួញដូរ ហើយខ្ញុំក៏មិនបានស្នាក់នៅផ្ទះជាប់លាប់ដែរ។ នៅឆ្នាំ១៩៦៧ ខ្ញុំបានសម្រេចចិត្តចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម។ និយាយដល់រឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ខ្ញុំស្រក់ទឹកភ្នែក ព្រោះខ្ញុំនឹកស្រណោះដល់សាច់ញាតិរបស់ខ្ញុំ និងប្រជាជនដែលធ្លាប់រស់នៅក្នុងភូមិជាមួយគ្នា ដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលទាំងក្រុមគ្រួសារ។

ខ្ញុំកើតនៅភូមិចិន ឃុំគរគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង។ នៅសង្គមចាស់ ប្រជាជនហៅថា ភូមិចិន ព្រោះភូមិនេះមានជនជាតិចិន និងយួន ចូលមករស់នៅច្រើន ហើយក្រោយមកភូមិនេះក៏ត្រូវបានប្តូរឈ្មោះមកភូមិសង្គមវិញ។ ជីតាខាងម្តាយរបស់ខ្ញុំគឺជាជនជាតិចិនឆៅដែលមករស់នៅភូមិចិននេះ ចំណែកឯយាយរបស់ខ្ញុំគឺជនជាតិខ្មែរ។ ឪពុកម្តាយរបស់ខ្ញុំគឺជាកសិករ។ រាល់ពេលរដូវប្រមូលផលកាត់មកដល់ ឪពុករបស់ខ្ញុំតែងតែប្រើខ្ញុំទៅសុំកូនកណ្តៀវពី សោ ភឹម ដែលកំពុងតែបួសជានេន គង់នៅក្នុងវត្តឈើទាល ហៅវត្តចាស់ស្ថិតនៅក្នុងឃុំគរគីសោម។ សោ ភឹម អាចឆ្លាក់រូបនាគ និងរូបផ្សេងៗទៀតនៅលើដងកណ្តៀវ បានយ៉ាងស្អាត។ ប្រជាជនក្នុងភូមិ និយាយសរសើរស្នាដៃចម្លាក់របស់គាត់គ្រប់ៗគ្នា។ សោ ភឹម ពេលនោះមានអាយុបងខ្ញុំប្រហែលជា៣ឆ្នាំ។ គាត់តែងផ្តាំប្រជាជននៅក្នុងភូមិដែលបានយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្តឈើ ទាល ឬនៅពេលដែលគាត់និមន្តទៅចូលរួមពិធីបុណ្យនៅផ្ទះប្រជាជនតាមភូមិថា ឲ្យខ្ញុំទៅលេងគាត់។ ពេលទំនេរពីការរៀនសូត្រខ្ញុំតែងតែទៅជួបគាត់ និងស្នាក់នៅក្នុងវត្តជាមួយគាត់។ សោ ភឹម ពេលនោះមានចិត្តល្អណាស់ និងតែងតែផ្តល់នំ

ចំណីឲ្យខ្ញុំហូបឆ្អែតៗ។ សោ គីម មានបងប្រុសម្នាក់ឈ្មោះ តាជុំ ត្រូវជាគ្រូសូត្រស្តាំនៅវត្តឈើទាលដែរ។ សោ គីម បួសបានរយៈពេល៣ព្រះវស្សាក៏សឹក រួចហើយបានចូលរួមជាមួយចលនាខ្មែរឥស្សរៈនៅអំឡុងឆ្នាំ ១៩៤៨ ជាមួយ សឺន ស៊ីចាន់ នៅព្រៃលើភ្នំប្រម៉ា ស្ថិតនៅខាងជើងស្រុករមាសហែក ខេត្តស្វាយរៀង។ បន្ទាប់មក សោ គីម បានរៀបការប្រពន្ធឈ្មោះ ប្រែង និងបានរស់នៅម្តុំផ្សារកំពង់ត្រាច ក្នុងស្រុករមាសហែកខេត្តស្វាយរៀង ជាប់ព្រំប្រទល់ស្រុកកំចាយមារ ខេត្តព្រៃវែង។ តាំងពីពេលនោះមក ខ្ញុំបានទៅលេង សោ គីម ម្តងម្កាលព្រោះយើងរស់នៅស្រុកឆ្ងាយពីគ្នា។

ក្រៅពី សោ គីម ដែលបានចូលរួមជាមួយឥស្សរៈ ពេលនោះក៏មានស្មៀនឃុំឈ្មោះ ម៉ែន សាន ហៅ យ៉ា ប៊ុស៊ាំ រស់នៅភូមិសង្គម ឃុំគរគីសោម ស្រុកស្វាយទាប ខេត្តស្វាយរៀងជាមួយខ្ញុំបានចូលរួមជាមួយចលនានេះដែរ។ ម៉ែន សាន គឺជាជីដូនមួយរបស់ខ្ញុំ។ ឪពុករបស់គាត់ និងឪពុកខ្ញុំ គឺជាបងប្អូននឹងគ្នា។ ឪពុករបស់ ម៉ែន សាន ឈ្មោះ តាំង ហេង គឺជាជនជាតិចិនឆៅ (ចិនទាជីវ) ដែលភៀសខ្លួនមករស់នៅស្រុកខ្មែរដូចជីតារបស់ខ្ញុំដែរ។ ចំណែកឯម្តាយរបស់គាត់ឈ្មោះយាយហ៊ី គឺជាជនជាតិខ្មែរ។ ម៉ែន សាន មានប្រពន្ធចំនួន ២នាក់។ ប្រពន្ធទី ១ របស់គាត់ឈ្មោះ សែន រស់ក្នុងភូមិឃុំជាមួយគ្នា និងបានចូលខ្មែរឥស្សរៈដូចគាត់ដែរ។ ប្រពន្ធទី ២ រស់នៅឃុំតាសួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ នៅឆ្នាំ១៩៥៣ ម៉ែន សាន និងប្រពន្ធទី ១ របស់គាត់បានចេញទៅរៀននៅទីក្រុងហាណូយ ប្រទេសវៀតណាម រហូតដល់ឆ្នាំ១៩៦៣ ទើបគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ។ ពេលនោះគាត់បានចូលធ្វើការផ្នែកមេការ ឬ កាប៉ូរ៉ាល់ ឲ្យក្រុមហ៊ុនបារាំង នៅគីឡូម៉ែត្រលេខ៦។ គាត់មានផ្ទះនៅជិតវត្តឬស្សីកែវមួយ និងមានផ្ទះដែលសង់ពីឈើមួយកន្លែងទៀតនៅម្តុំបឹងទំពុន ខាងត្បូងទីក្រុងភ្នំពេញ។ នៅពេលនោះគាត់រស់នៅជាមួយប្រពន្ធទី២ ចំណែកប្រពន្ធដើមរបស់គាត់បានយកប្តីថ្មីដែលធ្វើជាគ្រូពេទ្យនៅស្រុករមាសហែក ខេត្តស្វាយរៀង។ ពេលប្អូនស្រីរបស់ខ្ញុំឈឺ ម៉ែន សាន បានជួយរត់ការធ្វើសំបុត្របញ្ជាក់ជីវភាពក្រីក្រឲ្យ ទើបប្អូនស្រីរបស់ខ្ញុំត្រូវបានអនុញ្ញាតឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យរុស្ស៊ីរយៈពេលជាងមួយខែ រហូតបានធូរស្បើយ។ អំឡុងពេលនោះ ម៉ែន សាន ក៏បានចូលរួមសម្ងាត់ជាមួយចលនាខ្មែរក្រហមដែរ។ ដូច្នេះ ម៉ែន សាន មិនហ៊ានស្នាក់នៅផ្ទះជាប់លាប់ទេ។ គាត់ជារឿយៗចេញទៅស្នាក់នៅលាក់ខ្លួនក្នុងផ្ទះជួលវិញ ព្រោះប៉ូលីសបានតាមដានគាត់។ ថ្ងៃមួយខ្ញុំបានទទួលដំណឹងតាមរយៈមិត្តភក្តិរបស់ ម៉ែន សាន ថា ម៉ែន សាន បានមកស្នាក់នៅផ្ទះវិញ ហើយខ្ញុំក៏នាំបងប្អូនពីស្រុកកំណើតទៅសួរសុខទុក្ខគាត់។ ម៉ែន សាន បានខឹងសម្បារនឹងខ្ញុំយ៉ាងខ្លាំង និងស្តីបន្ទោសឲ្យខ្ញុំថា «អញកំពុងតែលាក់មុខ នាំគ្នាមកឈូឆរធ្វើអី»។ គាត់បានណែនាំខ្ញុំថា ថ្ងៃក្រោយកុំនាំបងប្អូនមកជួបគាត់ទៀត ព្រោះខ្លាចបែកការណ៍។ ម៉ែន សាន ស្នាក់នៅភ្នំពេញបានរយៈពេលប្រហែល ១ ឆ្នាំ គាត់ក៏ចេញទៅតស៊ូនៅក្នុងព្រៃ។ គាត់បានធ្វើដំណើរចេញទៅព្រៃតាមស្រុកកំណើតរបស់គាត់ត្រង់ចំណុចព្រៃត្រពាំងឬស្សី ដែលមានចម្ងាយប្រមាណ៣គីឡូម៉ែត្រ ពីឃុំគរគីសោម ដោយមានកងទ័ពវៀតណាមខាងជើងប្រមាណ ៦០នាក់ នៅរង់ចាំទទួលគាត់។ ពេលនោះខ្ញុំបានយំសុំទៅតាមគាត់។ ឃើញដូច្នោះគាត់ក៏តបមកខ្ញុំវិញថា «ឯងមិនទាន់មានសមត្ថភាពតាមអញទេ» រួចហើយបានណែនាំខ្ញុំថា «ឯងកុំដើរលេង កុំដើរចោលផ្ទះ និងកុំចាយវាយផ្តេសផ្តាស» ព្រោះគាត់ដឹងថា ខ្ញុំពីដើមមានប្រាក់ និងឧស្សាហ៍ដើរលេងច្រើន។

ក្រោយមក ខ្ញុំបានរៀបការប្រពន្ធឈ្មោះ គង់ សាលីន កើតនៅឆ្នាំ១៩៣៨ ត្រូវជាកូនរបស់អតីតមេឃុំកាលពីសង្គមចាស់។ ពូរបស់ខ្ញុំ គឺជាអ្នកជម្រុញឲ្យយើងបានរៀបការនឹងគ្នា។ ប្រពន្ធរបស់ខ្ញុំគឺជាជីដូនមួយរបស់ សោ គីម។ ឪពុករបស់ប្រពន្ធខ្ញុំនិងឪពុករបស់ សោ គីម ត្រូវជាបងប្អូនបង្កើត។ នៅពេលរៀបការរួចហើយ ខ្ញុំបានប្រកបរបររកស៊ីជួញស្រូវ គោ និង ក្របី ហើយខ្ញុំក៏បានចូលរួមជាសម្ងាត់ជាមួយចលនាបដិវត្តន៍ខ្មែរក្រហមដែរ។ ខ្ញុំតែងតែដកលុយពីមុខរបរជំនួញរបស់ខ្ញុំម្តងបួនទៅប្រាំម៉ឺនរៀលផ្ញើទៅឧត្ថម្ភដល់ សោ គីម ដើម្បីឃោសនា។ ក្រោយមក ប៉ូលីសបានតាមដាន និងបានតាមចាប់ខ្លួនខ្ញុំយកទៅសួរចម្លើយដោយបានចោទប្រកាន់ខ្ញុំថា «បានលួចលាក់



*សោ ភីម និងប្រពន្ធឈ្មោះ ប្រែង ហៅ យាយ ការ៉ូ ថតនៅខាងមុខប្រាសាទអង្គរវត្ត។ ប្រែង មានស្រុកកំណើតនៅភូមិជ្រៅ ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។ ប្រែង បានរៀបការជាមួយ សោ ភីម នៅក្នុងឆ្នាំ១៩៥០ និងមានកូនប្រុសស្រីចំនួន ៤នាក់គឺ ស៊ី (ស្រី), ណាត (ប្រុស), កាដេវ (ស្រី) និង យុច (ប្រុស)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ចិញ្ចឹមខ្មែរក្រហម» ព្រោះពេលនោះចលនាបដិវត្តន៍ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យសរសេរសំបុត្រជាសម្ងាត់ ស្នើសុំ សៀង អង្គរ និង បារី ពីប្រជាជនដែលរស់នៅក្នុងភូមិ។ ខ្ញុំបានបែកពីប្រពន្ធកូន និងរត់គេចខ្លួនអស់រយៈពេល៦ខែ រហូតដល់បងប្អូននៅក្នុងភូមិទៅឆានា ទើបប៉ូលីសឈប់តាមចាប់ខ្លួនរបស់ខ្ញុំ។*

*នៅអំឡុងពេលរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុមចលនាបដិវត្តន៍ខ្មែរក៏បានចោទប្រកាន់ លន់ នល់ ថាជាជនក្បត់ជាតិ រួចហើយបានប្រមូល និងចាត់តាំងកម្លាំងឲ្យយកគ្រាប់មីនទៅដាក់កម្ទេចផ្ទះកំណើតរបស់ លន់ នល់ នៅភូមិប្រាំង ក្នុងខេត្តព្រៃវែង។ ចំណែកខ្ញុំត្រូវបានខ្មែរក្រហមបំពាក់អាវុធអាកាឲ្យមួយដើម ប៉ុន្តែដោយសារកាំភ្លើងអាកាធ្ងន់ពេកខ្ញុំក៏ស្នើសុំប្តូរយកកាំភ្លើងកាវ៉ាប៊ីន និងម៉ូតូម៉ូប៊ីឡែតមួយគ្រឿងវិញ។ ខ្ញុំក៏បានទៅមើលការកម្ទេចផ្ទះរបស់ លន់ នល់ ដែរ។*

*ចាប់តាំងពីពេលនោះមក ខ្ញុំមិនហ៊ានរស់នៅជុំប្រពន្ធកូននៅស្រុកទៀតទេ។ ខ្ញុំបានទៅរស់នៅលាក់ខ្លួន និងធ្វើនីរសារសម្ងាត់ឲ្យ ម៉ែន សាន នៅក្រុងភ្នំពេញវិញ។ នៅឆ្នាំ១៩៧២ ចលនាបដិវត្តន៍ខ្មែរក្រហមរំដោះបានដីភូស្ថិតនៅទីប្រជុំជនតាមបណ្តោយផ្លូវជាតិលេខ១ ក្នុងខេត្តស្វាយរៀង។ ដូច្នេះ ខ្ញុំរួមទាំងសមាជិកខ្មែរក្រហម៣នាក់ទៀតត្រូវបានចលនាបដិវត្តន៍ខ្មែរក្រហមបញ្ជូនឲ្យទៅប្រចាំការនៅដីភូវិញ។ ខ្ញុំមានភារកិច្ចទទួលប្រាក់ពីចលនាបដិវត្តន៍ខ្មែរក្រហមយកទៅទិញថ្នាំពេទ្យពីឈ្មួញជនជាតិវៀតណាមដែលដឹកមកពីក្រុងព្រៃនគរ វៀតណាមខាងត្បូង។ រៀងរាល់ម៉ោង៧ព្រឹក សាវ៉ាត នៅក្នុងអង្គភាពជាមួយខ្ញុំ បានបើកម៉ូតូដឹកខ្ញុំទៅបាវិតដើម្បីរង់ចាំទិញថ្នាំពេទ្យ។ មុននឹងចេញទៅយើងបានរាប់លុយចងមួយដុំ ១០ម៉ឺនរៀល ច្រកចូលក្នុងសាក់កាដូចំនួន ២ ដើម្បីទុកប្រគល់ទៅឲ្យឈ្មួញវៀតណាម។ បន្ទាប់ពីយើងប្រមូលទិញថ្នាំពេទ្យបានចំនួន ៣ ទៅ៤ កេសហើយ យើងក៏ដឹកមកទុកនៅដីភូវិញ។ នៅពេលយប់គណៈកម្មាធិការខាងទទួលទិញថ្នាំពេទ្យរបស់ចលនាបដិវត្តន៍ខ្មែរក្រហម ដែលមានសមាជិកចំនួន៦នាក់ បានបើកម៉ូតូចំនួន៣គ្រឿងមកដឹកថ្នាំពេទ្យយកទៅប្រគល់ឲ្យថ្នាក់លើបន្តទៀត។ គណៈកម្មាធិការខាងទទួលទិញថ្នាំពេទ្យនោះបានមកដឹកថ្នាំពេទ្យពីខ្ញុំក្នុងមួយអាទិត្យចំនួន ២ដង។ នៅពេលនោះក៏មានការទម្លាក់គ្រាប់បែកខ្លាំងដែរ រហូតបណ្តាលឲ្យដាច់ស្ពានដើមពោធិ ស្ថិតនៅខាងជើងដីភូ។ ខ្ញុំធ្វើការខាងផ្នែកទិញថ្នាំពេទ្យរហូតដល់កងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលជ័យជម្នះបានមួយរយៈ សោ ភីម បានធ្វើដំណើរមកខេត្តស្វាយរៀង ដើម្បីយកខ្ញុំទៅធ្វើជាកងការពាររបស់គាត់ ព្រោះខ្ញុំស្គាល់ផ្លូវច្រើន។ សោ ភីម បានប្រាប់ខ្ញុំថា ទៅថ្ងៃខាងមុខប្រសិនបើខ្ញុំរស់នៅសហករណ៍នឹងជួបការលំបាក ព្រោះត្រូវហូបរួមគ្នា។ សោ ភីម បានបន្តថា គាត់បានចូលរួមប្រជុំជាមួយថ្នាក់លើ និងបានស្នើទៅអង្គប្រជុំឲ្យប្រជាជនហូបបាយនៅតាមផ្ទះរៀងខ្លួន ប៉ុន្តែថ្នាក់លើលើកឡើងថា ប្រសិនបើហូបឯកជននឹងធ្វើឲ្យខ្វះខ្នាយអាហារ។ ដូច្នេះ គាត់មិនដឹងថាថ្នាក់លើសម្រេចយ៉ាងណានោះទេ។ ទោះបីយ៉ាងណា*

ពេលនោះខ្ញុំបានបដិសេធមិនទៅនៅជាមួយគាត់ឡើយ ព្រោះខ្ញុំមានប្រពន្ធកូនរស់នៅក្នុងភូមិ។ មួយរយៈក្រោយមក សោ ភឹម បានមកខេត្តស្វាយរៀងម្តងទៀតដោយមានឡានចំនួន ២គ្រឿងអមមកជាមួយ។ គាត់បានទៅពិនិត្យមើលស្ថានការណ៍នៅបាវិត និងបានហៅខ្ញុំទៅនៅជាមួយទៀត ប៉ុន្តែបងស្រីរបស់ សោ ភឹម ឈ្មោះយ៉ាយ ឈុន ដែលធ្វើជាប្រធានសហករណ៍នៅភូមិសង្គម ឃុំគរគីសោម បានប្រាប់ទៅ សោ ភឹម វិញថា «កុំយកខ្ញុំចេញពីស្រុកកំណើតអី ព្រោះខ្ញុំបានជួយបដិវត្តន៍យូរហើយ ដូច្នេះឲ្យខ្ញុំរស់នៅស្រុកភូមិជុំគ្រួសារចុះ»។

ចំណែក ម៉ែន សាន ក៏បានមកលេងស្រុកកំណើតម្តងដែរ ដោយគាត់ជិះឡានមួយគ្រឿងជាមួយនីរសាររបស់គាត់ចំនួន ៣នាក់ទៀត។ ម៉ែន សាន បានជួបខ្ញុំ និងបាននិយាយប្រាប់ខ្ញុំថា «អញបានណែនាំឯងកាលពីមុនអញចេញទៅតស៊ូក្នុងព្រៃ ហើយឯងអាចស៊ូទ្រាំ និងប្រឹងប្រែងធ្វើការជាមួយខ្មែរក្រហមបាន គឺល្អហើយ។ រង់ចាំអង្គការរៀបចំស្រួលបួល អញនឹងមកលេងឯងម្តងទៀត»។ បន្ទាប់ពីស្តាប់គាត់និយាយហើយ ខ្ញុំក៏មិនហ៊ានសួរដេញដោលពីការងាររបស់គាត់ទៀតដែរ ព្រោះគាត់មិនសូវនិយាយស្តីច្រើនទេ។ ចាប់តាំងពីពេលនោះមក គាត់បាត់ខ្លួនរហូត។



រូប សោម ភឹម ពាក់អាវខ្មៅឈរនៅកណ្តាល ថតជាមួយកងកម្លាំងប្រយុទ្ធស្ម័គ្រចិត្តរបស់វៀតណាមខាងជើងក្នុងឆ្នាំ១៩៧៣។ រូបនេះថតភ្លាមៗបន្ទាប់ពីកងទ័ពសម្ព័ន្ធមិត្តចាប់ផ្តើមធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ព ឃុំក្រចៅ ក្នុងខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរដឹកនាំដោយសេនាប្រមុខ លន់ នល់។ ក្រោយមក សោ ភឹម បានធ្វើជាលេខាភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)

ម៉ែន សាន និង សោ ភឹម មានវ័យស្របាលគ្នា និងរស់នៅក្នុងភូមិជាមួយគ្នា ប៉ុន្តែ ម៉ែន សាន បានរៀនថ្នាក់ខ្ពស់ជាង សោ ភឹម។ អ្នកទាំងពីរគឺជាមិត្តភក្តិជិតស្និទ្ធ និងរាប់អានគ្នាដូចជាសាច់ញាតិ។ សោ ភឹម និង ម៉ែន សាន ក៏ស្រឡាញ់រាប់អានខ្ញុំណាស់ដែរ។

រហូតដល់ឆ្នាំ១៩៧៨ ខ្ញុំបាននៅធ្វើការងារនៅសហករណ៍ក្នុងឃុំគរគីសោម ក៏កម្មាភិបាល និងយោធាខ្មែរក្រហមនៅភូមិភាគនិរតីចូលមកគ្រប់គ្រង។ កម្មាភិបាល និងយោធាខ្មែរក្រហមទាំងនោះ បានកៀរខ្ញុំចេញពីភូមិសង្គម ឃុំគគីរសោម ឲ្យទៅរស់នៅឃុំចក ស្រុករំដួល ខេត្តស្វាយរៀងវិញ។ ខ្មែរក្រហមបានចោទប្រជាជនក្នុងភូមិរបស់ខ្ញុំថា «ក្បាលយួនខ្លួនខ្មែរ»។ ខ្ញុំរស់នៅឃុំចកបានរយៈពេល៨ថ្ងៃ ខ្មែរក្រហមបានជម្លៀសខ្ញុំបន្តទៅនៅអ្នកលឿងរយៈពេល៣ថ្ងៃទៀត។ នៅទីនោះ យោធាខ្មែរក្រហមបានស៊ើបសួរប្រជាជនដែលជម្លៀសមកដល់អ្នកលឿងដើម្បីតាមរកកូនរបស់ សោ ភឹម ដែលបានរត់គេចខ្លួនឆ្លងទន្លេមកនៅម្តុំអ្នកលឿងដែរ។ កងទ័ពខ្មែរក្រហមចាប់បានកូនរបស់ សោ ភឹម ម្នាក់ឈ្មោះ ណាត និងបងប្អូនជីដូនមួយរបស់ ណាត ចំនួន ២នាក់ទៀតយកទៅសម្លាប់ចោល។ ហេតុការណ៍តាមចាប់ និងសម្លាប់នេះបានធ្វើឲ្យខ្ញុំភ័យរន្ធត់យ៉ាងខ្លាំង។ ក្រោយមកយោធាខ្មែរក្រហមបានយកឡានមកដឹកខ្ញុំទៅដាក់នៅឃុំស្វាយរលំ ក្នុងខេត្តកណ្តាល។ នៅទីនោះប្រធានសហករណ៍បានសួរខ្ញុំថា ចេះធ្វើការងារអ្វីខ្លះ? ខ្ញុំបានតបទៅវិញថា ការងារអ្វីក៏ខ្ញុំចេះដែរ ព្រោះខ្ញុំគឺជាកសិករ។ ប្រធានសហករណ៍ចាត់តាំងខ្ញុំឲ្យទៅព្រោះស្រូវ និង ស្ទូង បន្ទាប់មកទៅភ្ជួររាស់។ ខ្ញុំធ្វើការនៅស្វាយរលំបានមួយរយៈខ្លីប៉ុណ្ណោះ ក៏កងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា។ ខ្ញុំបានត្រឡប់ទៅស្រុកកំណើតវិញ ប៉ុន្តែខ្ញុំមិនបានជួបបងប្អូន និងសាច់ញាតិរបស់ខ្ញុំទេ ព្រោះអ្នកទាំងនោះត្រូវបានខ្មែរក្រហមចោទប្រកាន់ និងបានយកទៅសម្លាប់ចោលស្ទើរគ្មានសល់ឡើយ។

# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

រេហឌី ប្រ៊ាយ

(តចប់)



អ្នកទោសស្ត្រីជនជាតិជ្វីហ្វកំពុងសាងសង់ជំរំ។ រូបភាពដកស្រង់មកពីការតាំងពិព័រណ៍រូបថតនៅក្នុងសារមន្ទីរស្តុតថូហ្វ។ (សូវិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រ៉ូម គឺជាជនជាតិដែលអន់ជាងយើង។ ខ្ញុំបានចំណាយពេលអស់ជាច្រើនដើម្បីយល់ដឹងអំពីការរើសអើងរបស់ខ្លួន។ នៅពេលនោះ ខ្ញុំបានរស់នៅក្នុងប្រទេសស៊ុយអែត នៅទីក្រុងដាឡាណា ហើយមានកូនតូចចំនួន ៣នាក់រួចទៅហើយ។ ថ្ងៃមួយកូនប្រុសអាយុ២ឆ្នាំរបស់ខ្ញុំបានបាត់ខ្លួន ហើយទោះបីជាខ្ញុំខំប្រឹងរកយ៉ាងណាខ្ញុំនៅតែមិនអាចរកគេឃើញឡើយ។ ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ហើយបានទៅរកអ្នកជិតខាងម្នាក់ដែលបាននិយាយប្រាប់ខ្ញុំថា «មានក្រុមជីបហ្ស៊ីបានឆ្លងកាត់ប្រហែលជាពួកគេចាប់យកកូនអ្នកទៅ»។ ខ្ញុំបានជឿនាង។ តែនៅពេលដែលកូនរបស់ខ្ញុំបង្ហាញខ្លួនចេញពីគុម្ពផ្លៃប្លែកបឺរី ខ្ញុំភ្ញាក់ខ្លួនថាខ្ញុំគឺកំពុងតែរើសអើងជាតិសាសន៍ដែលបង្កឲ្យមានបញ្ហានៅពេលដែលខ្ញុំជឿពាក្យអ្នកជិតខាងពេក។

វាគឺមានសារសំខាន់ណាស់ក្នុងការទទួលស្គាល់ភាពលម្អៀងរបស់មនុស្សម្នាក់ៗ។ វិធីមួយគឺនៅពេលដែលអ្នកមានអារម្មណ៍មិនពេញចិត្តចំពោះនរណាម្នាក់ សូម

សួរខ្លួនឯងជាមុនសិនថាព្រោះតែហេតុអ្វី? ដើម្បីពិនិត្យពិច័យខ្លួនឯង និងតាមដានពីប្រភពដើមនៃអារម្មណ៍នោះៗ ការប្រកាន់ពូជសាសន៍ គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីស្អប់ខ្ពើម ការប្រកាន់ជាតិសាសន៍ ការប្រឆាំងនឹងជនជាតិជ្វីហ្វ ការប្រឆាំងនឹងជនជាតិរ៉ូម និងការប្រឆាំងនឹងជនជាតិឥស្លាមចេញមកពីអារម្មណ៍ដែលជួនកាលអាចកើតឡើងបន្ទាប់ពីមាននរណាម្នាក់នៅក្នុងក្រុមនោះធ្លាប់បង្កឲ្យមានគ្រោះថ្នាក់ដល់យើងកាលពីអតីតកាលៗ ប៉ុន្តែយើងត្រូវតែស្គាល់មនុស្សម្នាក់ឲ្យបានច្បាស់ជាមុនសិន ដើម្បីអាចវិនិច្ឆ័យបុគ្គលនោះបានៗ យើងដោយសភាវគតិភ័យខ្លាចចំពោះភាពមិនច្បាស់លាស់ ហើយនោះគឺជាអារម្មណ៍កើតឡើងដំបូងរបស់មនុស្សៗ នៅយុគសម័យដើមដំបូងមនុស្សរស់នៅក្នុងក្រុមសហគមន៍កសិកម្មតូចៗ ហើយនេះគឺជារបៀបនៃការចិញ្ចឹមជីវិតរបស់មនុស្សនៅសម័យនោះ សម្រាប់ពួកគេអ្វីដែលមិនច្បាស់លាស់អាចធ្វើឲ្យមានគ្រោះថ្នាក់ៗ ប៉ុន្តែនាពេលបច្ចុប្បន្ននេះគឺបានក្លាយទៅជាផលវិបាកៗ

យើងទាំងអស់គ្នាមានការទទួលខុសត្រូវចំពោះសង្គមដែលយើងរស់នៅនិងចំពោះខ្លួនយើងផ្ទាល់ៗ មិនមានភាពខុសប្លែកគ្នាទេរវាងមនុស្សនៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ ឬឆ្នាំ១៩៤០ និងមនុស្សសព្វថ្ងៃនេះៗ នេះគឺត្រូវបានគេសង្កេតឃើញយ៉ាងល្អបំផុតនៅតាមសាលារៀនៗ មានអ្នកប្រព្រឹត្តិបទល្មើសដែលជាអ្នកចូលចិត្តសម្លុតគេវាយគេ និងជនរងគ្រោះ និងអ្នកដែលគ្រាន់តែឈរមើលដោយមិនបានចូលហាមឃាត់ដោយសង្ឃឹមថានឹងមានអ្នកផ្សេងទៀតចូលមកជួយជនរងគ្រោះៗ អ្នកមិនគួរធ្វើខ្លួនជាជនល្មើស ប៉ុន្តែអ្នកក៏មិនគួរបានត្រឹមតែឈរមើលបំណាំដែរ ពីព្រោះនេះក៏ធ្វើឲ្យអ្នកមានកំហុសដែរៗ សព្វថ្ងៃនេះយើងរស់នៅក្នុងលទ្ធិប្រជាធិបតេយ្យមួយៗ ទោះបីជាមិនល្អឥតខ្ចោះ ប៉ុន្តែក៏គ្មានរដ្ឋាភិបាលណាផ្សេងទៀតដែលប្រសើរជាងនេះដែរៗ យើងត្រូវតែតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យរបស់យើង ប្រសិនបើយើងចង់រក្សាឲ្យបានល្អគង់វង្សៗ បើមិនដូច្នេះទេវាអាចនឹងងាយស្រួលដែលការមិនសប្បាយចិត្តជាមួយនឹងភាពអវិជ្ជមានរបស់លទ្ធិប្រជាធិបតេយ្យសព្វថ្ងៃនេះ នឹងបង្កឲ្យអ្នកដឹកនាំអង់អាចម្នាក់ទៀតធ្វើឲ្យអឺរ៉ុបធ្លាក់ក្នុងគ្រោះថ្នាក់ម្តងទៀតៗ យើងមិនត្រូវលិចលង់ចូលទៅក្នុងភាពបរាជ័យទេយើងត្រូវតែបន្តប្រយុទ្ធទោះបីជាមួយនឹងរូបភាពអវិជ្ជមានដែលពិភពលោកកំពុងតែបង្ហាញសព្វថ្ងៃនេះក៏ដោយៗ

## “តើអ្វីៗអាចនឹងកើតឡើងម្តងទៀតដែរឬទេ?”

អ្វីដែលបានកើតឡើងម្តងហើយ អាចនឹងកើតឡើងម្តងទៀត ទោះបីជាមិនទៅតាមរបៀបដូចគ្នាក៏ដោយ ប៉ុន្តែលទ្ធផលគឺដូចគ្នាជានិច្ចៗ

ប្រសិនបើយើងក្រឡេកមើលទៅដំណើរប្រវត្តិសាស្ត្រ យើងអាចសន្និដ្ឋានបានថា ត្រឹមតែមួយជំនាន់គឺគ្រប់គ្រាន់ដើម្បីបំភ្លេចបទពិសោធន៍ពីអតីតកាលបានៗ យើងដឹងថា ហូឡូខសត៍ មិនមែនជាការសម្លាប់រង្គាលលើកដំបូងទៅលើ «មនុស្សដែលអន់ជាង» នោះទេៗ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នោះគឺជាលើកដំបូងដែលត្រូវបានគេដាក់ឈ្មោះឲ្យថា «អំពើប្រល័យពូជសាសន៍» ហើយឃើញអ្នកដែលបានផ្តួចផ្តើមគំនិតត្រូវបានផ្តន្ទាទោសៗ នៅក្រោមអាណានិគមនិយម ការជឿទៅលើឧត្តមភាពនៃជនជាតិស្បែកសបានរីករាលដាល ហើយការសម្លាប់ជនជាតិដើមភាគតិចដោយមិនបានថ្កោលទោសជាមុនសិន គឺជាច្បាប់ជាជាងករណីលើកលែងៗ ការសម្លាប់រង្គាលពិតប្រាកដបានកើតឡើងនៅអាហ្វ្រិកខាងត្បូង-អាហ្វ្រិកខាងលិច (បច្ចុប្បន្នជាណាមីប៊ី) នៅសតវត្សរ៍ទី ២០ៗ នៅពេលដែលជនជាតិអាល្លឺម៉ង់បានធ្វើអំពើយ៉ាងសាហាវឃោរឃៅដើម្បីកម្ចាត់មនុស្សជាង ៨០% នៃជនជាតិហឺរ៉ូ ៗ អ្នកវិទ្យាសាស្ត្រជាច្រើនបានអះអាងថាហ៊ីត្លែរ ក្រោយមកបានចាត់ទុកថាការសម្លាប់នេះគឺជាគំរូមួយសម្រាប់ការសម្លាប់ដ៏ទៃទៀតៗ មនុស្សជាច្រើនត្រូវបានធ្វើបាបយាយីនិងសម្លាប់ដោយមិនមានការថ្កោលទោសជាមុនសិន រហូតដល់ដើមសតវត្សរ៍ទី ២០ ទើបមាននិស្សិតផ្នែកច្បាប់ជនជាតិប៉ូឡូញវ័យក្មេងម្នាក់ឈ្មោះ រ៉ាហ្វាអែល ឡេមគីម បានគិតថាអំពើប្រល័យពូជសាសន៍គឺគួរតែមានច្បាប់សម្រាប់កាត់ទោសៗ

ប៉ុន្តែដំបូងគឺត្រូវតែមានឈ្មោះសម្រាប់ហៅជាមុនសិន គាត់បានបង្កើតពាក្យ «អំពើប្រល័យពូជសាសន៍» ពីភាសាក្រិចហៅថា «ឃាតកម្មមនុស្ស» ដែល “genos” មានន័យថាមនុស្សនិងឡាតាំង “cide” មានន័យថា

ឃាតកម្ម។ គាត់បានតស៊ូពេញមួយជីវិតរបស់គាត់ ដើម្បីឲ្យសហគមន៍អន្តរជាតិទទួលស្គាល់ថា អំពើប្រល័យពូជសាសន៍ គឺជាអំពើឧក្រិដ្ឋកម្ម។ បន្ទាប់ពីហូឡូខសត៍ នៅក្នុងឆ្នាំ ១៩៤៨ ទើបទស្សនៈមួយនេះត្រូវបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដែលសព្វថ្ងៃនេះប្រទេសចំនួន ១៤៩ ជាសមាជិកអនុសញ្ញា។ ទោះបីជាយ៉ាងនេះក្តី មិនយូរប៉ុន្មានអំពើប្រល័យពូជសាសន៍ថ្មីមួយទៀតបានកើតឡើងនៅក្នុងប្រទេសរវ៉ាន់ដា និងប៉ុន្មានឆ្នាំក្រោយមកទៀតនៅក្នុងប្រទេសស៊ែប៊ី។ នេះបានបង្ហាញយ៉ាងច្បាស់ថា ការគំរាមកំហែងអំពីការដាក់ទណ្ឌកម្ម គឺមិនគ្រប់គ្រាន់ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតឡើងម្តងទៀតនោះទេ។ សព្វថ្ងៃនេះយើងដឹងថាមានអ្វីផ្សេងទៀត ដែលមានតម្រូវការចាំបាច់ ហើយនោះគឺជាការផ្លាស់ប្តូរអំពីរបៀបដែលយើងចិញ្ចឹមកូនៗរបស់យើង។ យុវវ័យជំនាន់ថ្មីត្រូវតែបន្តរំឭកអំពីឧក្រិដ្ឋកម្មដែលបានកើតឡើង។ អ្នកទាំងឡាយណាដែលចិញ្ចឹមក្មេងៗ ជំនាន់ក្រោយ ឪពុកម្តាយនិងគ្រូបង្រៀន ត្រូវតែផ្តល់ចំណេះដឹងនេះដល់កូនៗ និងសិស្សរបស់ខ្លួនដោយមានជំនួយពីសៀវភៅប្រវត្តិសាស្ត្រ បូជនីយដ្ឋាននិងសារមន្ទីរ។ ប៉ុន្តែវិធីដែលត្រូវបានអនុវត្តក៏មានសារសំខាន់ខ្លាំងណាស់ដែរ ពីព្រោះប្រសិនបើចំណេះដឹងជ្រាបទៅដល់ត្រឹមតែគំនិតស្មារតីនោះនឹងអាចត្រូវបានបំភ្លេចចោលបានយ៉ាងងាយស្រួល។

ការបង្រៀន គឺត្រូវតែជ្រាបឲ្យដល់បេះដូងដើម្បីធ្វើឲ្យក្មេងជំនាន់ក្រោយមានអារម្មណ៍ចង់រៀនសូត្រអំពីព្រឹត្តិការណ៍ទាំងនោះ។ មានសាក្សីជាច្រើនដែលអាចនិយាយអំពីបទពិសោធន៍របស់ខ្លួនផ្ទាល់។ យើងយល់អំពីពិភពលោកដោយប្រើសតិអារម្មណ៍និងដួងចិត្ត។ ការសិក្សាស្រាវជ្រាវថ្មីៗកន្លងមកនេះក៏បានរាប់បញ្ចូលបេះដូងជាមួយនឹងប្រាជ្ញាដែលអាចទទួលបានការបណ្តុះបណ្តាលដូចគ្នាទៅនឹងបញ្ញាខួរក្បាលដែរ។

នេះគឺជាគំរូដ៏ល្អមួយដែលឪពុកម្តាយនិងគ្រូបង្រៀនអាចប្រៀនប្រដៅក្មេងជំនាន់ថ្មីឲ្យឱបក្រសោបសេចក្តីអាណិតអាសូរ សេចក្តីស្រឡាញ់ដោយគ្មានលក្ខខណ្ឌ និងពិភពលោកដែលគ្មានភាពស្អប់ខ្ពើម។

មិនយូរប៉ុន្មាននឹងគ្មានសាក្សីរស់នៅសេសសល់ទៀតទេ ហើយដើម្បីព្យាយាមរារាំងអំពើអាក្រក់ទាំងនេះកុំឲ្យកើតមានម្តងទៀតនោះ គឺរឿងរ៉ាវរបស់យើងត្រូវតែបន្តចែករំលែក។ រឿងរបស់យើងអាចបង្ហាញតាមរយៈដូចគ្នាទៅនឹងរឿងអំពីការចាកចេញរបស់ប្រជាជនពីប្រទេសអេហ្ស៊ីប ក្នុងអំឡុងពេលបុណ្យជៀល (បុណ្យចម្លង) របស់ជនជាតិជ្វីហ្វ។ អ្នកអានគួរតែអានរឿងនោះប្រៀបបានដូចជាខ្លួនឯងគឺជាតួអង្គនៅក្នុងរឿង។ ខ្ញុំគិតថាវិធីនេះក៏ល្អសម្រាប់ការប្រាប់រឿងរ៉ាវរបស់ហូឡូខសត៍ដែរ។ ឥឡូវនេះយើងមានថ្ងៃនៃការចងចាំគឺថ្ងៃទី ២៧ ខែមករា។ ខ្ញុំសង្ឃឹមថារឿងនេះនឹងវិវឌ្ឍទៅជាប្រពៃណីដ៏យូរអង្វែងមួយដែលក្មេងជំនាន់ក្រោយ អាចចែករំលែករឿងរ៉ាវហើយប្រាប់តាមរបៀបដែលអាចជ្រាបដល់ដួងចិត្តរបស់អ្នកស្តាប់បាន។





ទាហានណាហ្ស៊ីបាញ់សម្លាប់ជនរងគ្រោះដែលជាជនជាតិជ្វីហ្វ។ រូបភាពដកស្រង់ចេញពីរូបថតនៅក្នុងសារមន្ទីរស្តុតថូហ្វ។ (សូវិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវស្ពានមិនដល់នៅក្នុងឆាកជីវិតខ្ញុំ

**ដារ៉ារដ្ឋ មេត្តា**



រូបខាងឆ្វេង៖ ចិន បឿន និង មិត្តភក្តិ នៅសមរភូមិត្រង់ចំណុចបង្គោល ឡាក់លេខ៨០ នៅក្នុងអំឡុងឆ្នាំ១៩៩០។
(ដារ៉ារដ្ឋ មេត្តា/មណ្ឌសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចិន បឿន គឺជាគ្រូដំបូងបង្អស់ដែលបានកៀងគរប្រជាជនរស់នៅក្នុងភូមិ រួមគ្នាសាងសង់សាលារៀន និងធ្លាប់ជាគ្រូបង្រៀននៅសាលាស្ទឹងថ្មី ទួលគ្រួស និងដូនទាគ ក្រោយសមាហរណកម្មនៅក្នុងឆ្នាំ១៩៩៨។ ចិន បឿន យល់ឃើញថា មានតែការអប់រំប៉ុណ្ណោះ ទើបអាចជួយកូនៗ អតីតកម្មាភិបាលខ្មែរក្រហមជៀសផុតពីអតីតកាលរបស់ខ្លួន និងចូលរួមរស់នៅក្នុងសង្គមថ្មីបាន។ ចិន បឿន គឺជាអតីតនាយកសាលាបឋមសិក្សា ហ៊ុនសែនប្រមោយ មានទីតាំងស្ថិតនៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ សាលាបឋមសិក្សានេះធ្លាប់ជាអតីតទីតាំងសមរភូមិប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាមនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។

ខ្ញុំឈ្មោះ ចិន បឿន អាយុ៦៥ឆ្នាំ មានឪពុកឈ្មោះ ប៉ម ចិន និងម្ដាយឈ្មោះ ពែក ព្រិន។ ខ្ញុំមានស្រុកកំណើតនៅឃុំល្វាក្រាំង ស្រុកវ៉ារិន ខេត្តសៀមរាប។ ខ្ញុំគឺជាកូន

ពៅនៅក្នុងគ្រួសារដែលមានបងប្អូនចំនួនប្រាំបីនាក់ ក្នុងនោះបងប្អូនខ្ញុំចំនួនបីនាក់ បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំរៀនដល់ថ្នាក់ទី៨ នៅសាលាបឋមសិក្សា គោកចាន់ ហើយនៅឆ្នាំ១៩៧០ ខ្ញុំបានឈប់រៀន។

## រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០

នៅពេលដែលកើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែង នៅក្នុងភូមិរបស់ខ្ញុំមានសភាពច្របូកច្របល់យ៉ាងខ្លាំង។ ខ្ញុំឃើញមានក្រុមប្រឆាំងជាមួយ លន់ នល់ ជាច្រើនក្រុមបានចូលមកក្នុងភូមិខ្ញុំ។ បន្ទាប់មក ខ្ញុំឃើញកងទ័ពវៀតណាមខាងជើង និងក្រុមខ្មែរក្រហមបានចូលមកក្នុងភូមិម្តងម្កាល់នៅពេលយប់ស្ងាត់។ ក្រុមខ្មែរក្រហមចូលមកក្នុងគោលបំណងធ្វើការឃោសនាដល់ប្រជាជនឲ្យគាំទ្រចលនារបស់ខ្លួន។ កាលនោះខ្ញុំនៅជាយុវជននៅក្នុងភូមិត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើបាតុកម្មនៅជិតតំបន់អង្គរវត្ត ដើម្បីទាមទារអំណាចថ្វាយសម្តេចតា ដូចក្រុមប្រឆាំងជា មួយ លន់ នល់ ផ្សេងទៀតដែរ។

នៅឆ្នាំ១៩៧១ ចលនាបដិវត្តន៍ខ្មែរក្រហមបានចូលមកក្នុងភូមិខ្ញុំ ពួកគេស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ និងស្ពាយកាំភ្លើងកាប៊ីន។ ខ្មែរក្រហមលបលួចចូលក្នុងភូមិរបស់ខ្ញុំនៅពេលយប់ ហើយបានគេចខ្លួននៅពេលដែលមានទាហាន លន់ លន់ ឬកងទ័ពវៀតណាមខាងត្បូងចូលមកដើម្បីជៀសវាងការផ្ទុះអាវុធ។ នៅពេលខ្មែរក្រហមចូលមកឃោសនា និងអប់រំប្រជាជនម្តងៗ ខ្ញុំតែងតែស្តាប់ឮខ្មែរក្រហមនិយាយថា «ឥឡូវយើងបង្កើតរណសិរ្សរំដោះជាតិ និងបង្កើតកងទ័ពរបស់សម្តេចឪ ដែលមាន ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ដឹកនាំ ចំណែកយើងជាកសិករត្រូវក្រោកឈរឡើងកុំឲ្យរបបសក្តិភូមិជិះជាន់តទៅទៀត»។

## ថ្វាយបង្គំម៉ែ ចូលបដិវត្តន៍

នៅក្នុងឆ្នាំ១៩៧២ ខ្ញុំបានចូលធ្វើបដិវត្តន៍ជាមួយខ្មែរក្រហម បន្ទាប់ពីបានស្តាប់ការឃោសនារបស់ខ្មែរក្រហមជាញឹកញាប់។ ម្យ៉ាង ខ្ញុំក៏ខ្លាចការគំរាមកំហែងដោយប្រយោលពីសំណាក់ខ្មែរក្រហមចំពោះអ្នកដែលមិនចូលរួមជាមួយបដិវត្តន៍។ អ្នកទាំងនោះត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅសមរភូមិ ដោយមិនឲ្យរស់នៅក្នុងភូមិទៀតទេ។ ខ្ញុំគិតក្នុងចិត្តថា ខ្មាស់អ្នកនៅក្នុងភូមិ ប្រសិនបើខ្មែរក្រហមចាប់បញ្ជូនទៅ ដូច្នេះសម្រេចចិត្តស្ម័គ្រចិត្តចូលជាមួយខ្មែរក្រហមដោយខ្លួនឯងទើបមោទកភាពជាង។ ខ្ញុំបានទៅថ្វាយបង្គំលាម្តាយខ្ញុំបីដង។ ម្តាយខ្ញុំបានយំនៅពេលនោះ។



ចិន ភឿន ថតនៅទីស្នាក់ការយោធា។ 
(ដារ៉ាវឌ្ឍ មេត្តា/មណ្ឌសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ចិន បឿន ថតជាមួយបងប្អូននៅឆ្នេរសមុទ្រកំពង់សោម នៅអំឡុងឆ្នាំ២០០៥។
(ដារ៉ារដ្ឋ មេត្តា/មណ្ឌសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ចិន បឿន នៅថ្ងៃរៀបមង្គលការ។
(ដារ៉ារដ្ឋ មេត្តា/មណ្ឌសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## សម្តែងសិល្បៈ រឿង«ដាំដេង»

ខ្ញុំចូលបដិវត្តន៍ដំបូង គឺនៅអង្គភាពសិល្បៈ និងត្រូវដើរសម្តែងឲ្យប្រជាជនទស្សនានៅតាមភូមិ។ ក្រុមសិល្បៈរបស់ខ្ញុំ គឺប្រចាំនៅក្នុងស្រុកវ៉ារិន ខេត្តសៀមរាប។ ការសម្តែងសិល្បៈនោះ គឺយើងសម្តែងនៅពេលធ្វើមិទ្ទីញម្តងៗ។ រឿងដែលក្រុមខ្ញុំខស្សរាហ៍សម្តែងឲ្យប្រជាជនទស្សនាញឹកញាប់ជាង់គេគឺរឿង «ដាំដេង» ដែលជាវីរជន។ រឿង «ដាំដេង» នេះ ខ្ញុំបានរៀនតាមឯកសារដែលខ្មែរក្រហមបានសរសេរ។ នៅក្នុងរឿងនេះ វីរជនដាំដេង បានតស៊ូវាយជាមួយទាហាន លន់ នល់។ ដាំដេងមានតែកាំភ្លើងមួយដើម និងមានតែម្នាក់ឯងវាយជាមួយខ្មាំងប្រមាណជា ២០នាក់។ ដាំដេង ក្លែងបន្លំខ្លួនរត់ទៅបាញ់នៅត្រង់នេះ នៅត្រង់នោះជាមួយខ្មាំង ហើយនៅពេលខ្មាំចាប់បាន សុខចិត្តស្លាប់ក៏មិនព្រមនិយាយសារភាព។ ចំណែកកាំភ្លើងសម្រាប់តួអង្គ ដាំដេង ធ្វើអំពីដើមគលាបថ្នាំដែលមើលទៅហាក់ដូចកាំភ្លើងពិតៗ។ ក្នុងការសម្តែងនោះ មានសកម្មភាពប្រជាជនបិតចម្រូង និងច្រៀងចម្រៀងបដិវត្តន៍បំផុសស្មារតីប្រជាជនឲ្យមានកំហឹងឈឺចាប់។

បន្ទាប់ពីសម្តែងរឿង ដាំដេង ចប់កម្មាភិបាលខ្មែរក្រហមនៅអង្គភាពរបស់ខ្ញុំបានបើកវគ្គសិក្ខាសាលាបន្តទៀត។ ឯកសារបង្រៀនក្នុងវគ្គសិក្ខាសាលានោះបានលើកឡើងអំពីកសិករដែលឡើងកាន់អំណាច, អំពីពួកសក្តិភូមិកៀបសង្កត់ជិះជាន់កសិករក្រីក្រ និងការលក់ផលិតផលដែលជាកម្លាំងញើសឈាមប្រជាជនមិនបានថ្លៃ។ ខ្ញុំបានធ្វើការនៅអង្គភាពសិល្បៈបានរយៈពេល ៤ខែ គឺនៅចុងឆ្នាំ ១៩៧២ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជានីរសារប្រចាំនៅក្នុងឃុំបុស្សី ស្រុកវ៉ារិន ខេត្តសៀមរាបវិញ។ ប្រធានរបស់ខ្ញុំមានឈ្មោះ សាមឿន គាត់គឺជាអតីតគ្រូបង្រៀនរបស់ខ្ញុំ។ សាមឿន មានស្រុកកំណើតនៅខេត្តកំពង់ធំ និងមានប្រពន្ធអ្នកស្រុកជាមួយខ្ញុំ។ ខ្ញុំបានឲ្យមាន់ទៅគាត់ធ្វើម្ហូបនៅថ្ងៃដែលគាត់រៀបការ។ ឈ្មោះ ចាន់ ថុល គឺជាអនុប្រធាន និង ប៊ុនថន សមាជិក។ ចំណែកខ្ញុំពេលនោះ គឺមានភារកិច្ចមួយទៀតគឺបង្រៀនក្មេងតូចៗនៅក្នុងភូមិឲ្យចេះអានអក្សរ។ ខ្ញុំបង្រៀនក្មេងៗទាំងនោះអានតាមឯកសារដែលមានស្រាប់។ មួយរយៈ

ក្រោយមក ខ្ញុំបានចេញពីអង្គភាពនីរសារចូលធ្វើទ័ព ព្រោះមិនចង់ធ្វើការងាររដដែលៗ នៅឆ្នាំ១៩៧៣ មានការទម្លាក់គ្រាប់បែកបេ-៥២ យ៉ាងច្រើននៅក្នុងតំបន់របស់ខ្ញុំរស់នៅ។

## ចូលធ្វើកងទ័ព និងវាយចូលទីក្រុងភ្នំពេញ

នៅពេលខ្ញុំទៅដល់តំបន់អង្គរ ទើបដឹងថានៅកងពលវរសេនាធំលេខ ៣។ ខ្ញុំបានហាត់រៀនយុទ្ធសាស្ត្រយោធារយៈពេល ៥ ខែ៖ យុទ្ធសាស្ត្រទី១) ហាត់ពញ្ញាក់ស្មារតីនៅពេលប្រកាសអាសន្ន គឺនៅពេលមានការវាយជួងដោយយើងមិនបានដឹងជាមុន ប៉ុន្តែយើងត្រូវយកឲ្យបាននូវសម្ភារចាំបាច់រួមមាន កាំភ្លើង, គ្រាប់, ឆ្នាំងបាយ, ចប, ប៉ែល និង អង្រឹង។ យុទ្ធសាស្ត្រទី២) ហាត់រាវរកមីន, មីនជាន់, មីនកប់ក្នុងដី និង មីនខ្សែ។ យុទ្ធសាស្ត្រទី៣) ហាត់ដើរក្នុងទឹកពេលយប់កុំឲ្យឮសំឡេងក្ទួងៗ, យុទ្ធសាស្ត្រទី៤) លូនក្រាបសម្រុកចូលក្នុងបន្ទាយ ហើយគប់គ្រាប់បែក និង យុទ្ធសាស្ត្រទី៥) ក្លែងភេទបន្លំខ្លួនតាមគុម្ពស្មៅ។ ចំណែកអ្នកបង្ហាត់មានឈ្មោះ តាធិន គឺជាប្រធាន, តាលី គឺជាអនុប្រធាន និង តាឡើង គឺជាសមាជិក។ អ្នកទាំងបីធ្លាប់បានចូលវាយនៅក្នុងប្រតិបត្តិការសឹកចេនឡាទី២ នៅខេត្តកំពង់ធំ។ បន្ទាប់ពីហាត់យុទ្ធសាស្ត្រយោធា ខ្ញុំបានចូលរៀនពេទ្យផ្នែកសង្គ្រោះបឋម។

នៅឆ្នាំ១៩៧៣ កងទ័ពរបស់ខ្ញុំដើរពីអង្គរវត្តមកឈរជើងនៅខាងលិចផ្លូវជាតិលេខ៤ ដោយកងខ្ញុំដើរកាត់ខេត្តកំពង់ធំ កំពង់ចាម ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅខាងលិចទីក្រុងភ្នំពេញ។ នៅតាមផ្លូវកងទ័ពរបស់ខ្ញុំបានវាយជាមួយទាហាន លន់ នល់ ហើយពលទាហាន លន់ នល់ ក៏វាយសន្ទាប់មកលើកងរបស់ខ្ញុំដែរ។ កងខ្ញុំបានដើរកាត់ទឹក កាត់ព្រៃ ដើម្បីគេចចេញពីទាហាន លន់ នល់។ នៅពេលមិនឃើញទាហាន លន់ នល់ ទើបកងរបស់ខ្ញុំដើរតាមផ្លូវថ្នល់។ នៅក្នុងឆ្នាំ ១៩៧៤ សមរភូមិដែលកងរបស់ខ្ញុំឡើងទៅវាយខ្លាំងជាគេគឺនៅសមរភូមិក្នុងឃុំដូវាំង, ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ដែលខ្ញុំត្រូវវាយទាំងយប់ទាំងថ្ងៃ។ នៅក្នុងឆ្នាំ១៩៧៥ កងខ្ញុំវាយចូលភ្នំពេញ តាមទិសខាងជើងពោធិចិនតុង។ ខ្ញុំបានលូនចូលទៅរុំកងទ័ពដែលរងរបួសធ្ងន់នៅពេលវាយនៅសមរភូមិម្តងៗ បន្ទាប់មកបញ្ជូនអ្នកទាំងនោះទៅពេទ្យធំ មានទីស្នាក់ការនៅក្រាំងភ្ញៀ មានទីតាំងស្ថិតនៅឃុំពាមឬ ហៅថាពេទ្យយោធា ខេត្តកំពង់ឆ្នាំង។

បន្ទាប់ពីវាយរំដោះបានទីក្រុងភ្នំពេញហើយ ខ្ញុំបានដើរជម្លៀសប្រជាជនចេញ ដោយប្រាប់ថា ខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ បន្ទាប់ពីជ័យជម្នះ កងរបស់ខ្ញុំ ត្រូវបានរំសាយខ្លះទៅតាមព្រំដែន ខេត្តរតនគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែងវិញ។

## ខ្ញុំត្រូវបានជ្រើសរើសរៀនបើកយន្តហោះនៅប្រទេសចិន

កម្មាភិបាលខ្មែរក្រហម រើសយោធាខ្មែរក្រហមប្រមាណ ២០នាក់ឲ្យមកបម្រើការងារខាងប្រលានយន្តហោះពោធិចិនតុង។ ការងាររបស់ខ្ញុំគឺ បោសសម្អាត លុបជង្ហុក អូសយន្តហោះចាស់ដាក់ឃ្លាំង និងរៀបចំសម្ភារទាំងឡាយដែលនៅរាយរប៉ាត់រប៉ាយ។ ខ្ញុំនៅកងពល ៥០២ ដែលមានតាម៉ែត គឺជាប្រធាន និង តាផល គឺជាអនុប្រធាន។ ក្រោយមក ក៏មានជនជាតិចិន មកពិនិត្យសុខភាពរបស់ខ្ញុំ ដោយជ្រើសយកតែអ្នកដែលមានសុខភាពល្អឲ្យទៅរៀនបើកយន្តហោះនៅប្រទេសចិន។ ខ្ញុំមានសំណាងបានជាប់។ នៅខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំបានចេញដំណើរទៅប្រទេសចិនដោយមានគ្នាចំនួន៥០នាក់មកពីចម្រុះកងពល។ ខ្ញុំបានរៀនភាសាចិនខ្លះៗ ក្នុងការនិយាយប្រាស្រ័យទាក់ទងប្រចាំថ្ងៃ និងភាសាប្រើក្នុងការហោះហើរយន្តហោះ។ ពេលរៀន ខ្ញុំមានសៀវភៅចំនួន ២ក្បាលដើម្បីកត់ត្រា។ ដំបូងខ្ញុំទៅរៀននៅក្នុងស្រុកសឺចាងជួង ខាងបើកយន្តហោះ និងហ្វឹកហាត់បើករយៈពេល១ឆ្នាំ។ យើងទាំងអស់គ្នាត្រូវរៀនបើកសាកល្បង ចំណែកអ្នកដែលមិនជាប់ខាងបើកបរ ត្រូវបានបញ្ជូនឲ្យរៀនរៀបគ្រាប់, ថតរូប, ជួសជុលម៉ាស៊ីន និងខាងផ្នែកទាក់ទង។ ក្រោយមក ខ្ញុំបានទៅរៀននៅខេត្តហ៊ឺរប៉ិ។ បន្ទាប់ពីរៀនទ្រឹស្តីរួចហើយ គឺយើងអនុវត្តជាក់ស្តែងដោយមានគ្រូម្នាក់ សិស្សបីនាក់ និងអ្នកបកប្រែម្នាក់។ ខ្ញុំនៅចាំឈ្មោះគ្រូបង្រៀនបើកបរឈ្មោះ ឡូលី និងគ្រូឈ្មោះ ឡូឆាងមីន។ ខ្ញុំរៀននៅប្រទេសចិនរយៈពេល

៣ឆ្នាំ ត្រឡប់មកកម្ពុជាវិញ នៅខែកក្កដា ឆ្នាំ១៩៧៨ ដោយមានគ្រូចិនមកជាមួយ និងនិស្សិតខ្មែរផ្នែកបើកយន្តហោះ១៥នាក់ៗ បន្ទាប់ពីដល់ស្រុកខ្មែរ ខ្ញុំបានស្នាក់នៅម៉ុំផ្សារអូឡាំពិច ហើយពេលព្រឹកចេញទៅសាកល្បងបើកយន្តហោះ នៅប្រលានយន្តហោះពោធិ៍ចិនតុងៗ យន្តហោះមានប្រាំពីរគ្រឿងៗ ខ្ញុំបើកយន្តហោះចេញពីភ្នំពេញទៅកំពង់ចាម កំពង់ធំ អង្គរវត្ត បាត់ដំបង ជួរភ្នំទឹរ៉ាល់ រួចហើយត្រឡប់មកចុះចតនៅភ្នំពេញវិញៗ មុនបើកបរខ្ញុំត្រូវមើលផែនទីឲ្យដឹងពីភូមិសាស្ត្រៗ នៅឆ្នាំ ១៩៧៩ ខ្ញុំបានទទួលផែនការទៅទម្លាក់គ្រាប់នៅស្រុកមេមត់ ខេត្តកំពង់ចាម ព្រោះទទួលដំណឹងថាវៀតណាមវាយចូលមក ប៉ុន្តែផែនការនោះមិនបានជោគជ័យទេៗ

ក្រោយមកខ្មែរក្រហមឲ្យខ្ញុំត្រឡប់ទៅចិនវិញ ប៉ុន្តែដោយស្ថានការណ៍កាន់តែវឹកវរ ខ្ញុំក៏ធ្វើដំណើរទៅខេត្តបាត់ដំបងៗ ខ្មែរក្រហមប្រគល់កាំភ្លើងឲ្យយើងម្នាក់មួយដើមៗ ក្រោយមកដោយខ្មែរក្រហមដឹងថា ខ្ញុំធ្លាប់ធ្វើពេទ្យ ក៏បានចាត់តាំងខ្ញុំឲ្យធ្វើការនៅអង្គភាពពេទ្យវិញៗ

## ពិការជើងព្រោះជាន់មីន និងក្លាយជាគ្រូបង្រៀនជិតព្រំដែនថៃ

ថ្ងៃមួយនៅវេលាម៉ោងជាង៩ព្រឹក ក្នុងឆ្នាំ១៩៨៨ ខ្ញុំនិងកងរបស់ខ្ញុំដើរត្រួតពិនិត្យក្បែរបន្ទាយ នៅស្រុកសំឡូត ខេត្តបាត់ដំបង ក៏ជាន់មីនបណ្តាលឲ្យផ្ទុះៗ ខ្ញុំទទួលរងគ្រោះថ្នាក់ធ្វើឲ្យដាច់ជើងទាំងពីរ ប៉ុន្តែសំណាងល្អខ្ញុំមិនស្លាប់ៗ ខ្ញុំបានចងសរសៃឈាមខ្លួនឯង ដោយយកខ្សែក្រវ៉ាត់ចិនពណ៌ក្រហមពាក់លើចង្កេះមកចងរឹត ឃាត់ឈាមកុំឲ្យហូរៗ នៅវេលាម៉ោងប្រហែល១ ឬ ២ ក្រុមរបស់ខ្ញុំបានមកស្វែងសាកសពខ្ញុំ ដោយគិតថា ខ្ញុំបានស្លាប់បាត់ទៅហើយៗ ខ្ញុំឮក្រុមរបស់ខ្ញុំជជែកគ្នាថា ឯណាខ្មោច ពេលឮដូច្នេះខ្ញុំក៏លើកដៃជាសញ្ញាៗ ខ្ញុំស្រែកថា ខ្ញុំនៅរស់ ទើបអ្នកទាំងនោះរត់មកសែងខ្ញុំចេញទៅៗ រយៈពេលកន្លះឆ្នាំក្រោយមក ទើបខ្ញុំបានធូរស្បើយ ដោយមាន តាបុត្រ ជាអ្នកព្យាបាលខ្ញុំៗ បន្ទាប់ពីខ្ញុំពិការជើងទាំងពីរ ខ្ញុំត្រូវបានជ្រើសរើសធ្វើគ្រូបង្រៀនក្មេងៗ នៅតាមព្រំដែនៗ

នៅឆ្នាំ១៩៩៥ ខ្ញុំបានមករស់នៅស្រុកវាលវែង ខេត្តពោធិ៍សាត់ តាមការចាត់តាំងរបស់ គីម ពៅ ប្រធានវរសេនាតូចកងឯករាជ្យៗ នៅក្នុងឆ្នាំ ២០០០ ខ្ញុំបានផ្លាស់មករស់នៅតាំងយ៉ូ ហើយបានទៅរៀនផ្នែកគរុកោសល្យនៅទីរួមខេត្តពោធិ៍សាត់រយៈពេល ២ ខែ ៗ នៅឆ្នាំ ២០០១ ខ្ញុំបានបំពេញសាលាកប័ត្រ និងបានធ្វើជាគ្រូបង្រៀនពេញសិទ្ធិដោយទទួលបានប្រាក់បៀវត្សពីរាជរដ្ឋាភិបាលកម្ពុជាៗ នៅឆ្នាំ២០១៥ ខ្ញុំបានចូលនិវត្តន៍ ប៉ុន្តែខ្ញុំបានទៅបង្រៀនសិស្សម្តងម្កាលនៅពេលខ្វះគ្រូបង្រៀន ៗ



ចិន បឿន ថតជាមួយសិស្ស នៅពេលគាត់ធ្វើជាគ្រូបង្រៀននៅជំរំ ជាប់ព្រំដែនកម្ពុជា-ថៃៗ (ដារ៉ាវរដ្ឋ មេត្តា/មណ្ឌសារ មជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

**ជាវ៉ារដ្ឋ មេត្តា**

(តពីលេខមុន)



*កងចល័តមកហូបអាហារនៅរោងបាយរួមៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

**២០៩.** *ទោះបីជាបក្សពលករវៀតណាមចង់ឲ្យមានការផ្លាស់ប្តូរដោយសន្តិវិធីទៅជារបបសង្គមនិយមនៅក្នុងប្រទេសកម្ពុជាក្តី ប៉ុន្តែនៅក្នុង ខែកញ្ញា ឆ្នាំ១៩៦៦ បក្សពលករកម្ពុជាបានអនុម័តសេចក្តីសម្រេចមួយ ដែលបង្គាប់ឲ្យភូមិភាគនីមួយៗត្រៀមរៀបចំការប្រយុទ្ធតស៊ូប្រដាប់អាវុធៗ ជានិម្មិតរូប បក្សក៏បានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនទៅជា ប.ក.ក.ៗ ទាំងឈ្មោះរបស់បក្ស និងអត្តិភាពរបស់បក្ស មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ រហូតដល់ឆ្នាំ១៩៧៧ៗ*

**២១០.** *នៅក្នុងខែ មេសា ឆ្នាំ១៩៦៧ ការប៉ះទង្គិចរវាងកងទ័ព និងកសិករបានកើតឡើងនៅមូលដ្ឋានអតីតឥស្សរៈនៅភូមិសំឡូត ខេត្តបាត់ដំបង ដោយសារតែគោលនយោបាយលក់ស្រូវ/ កសិផលជាកាតព្វកិច្ចមិនអាចប្រកែកបានរបស់រដ្ឋាភិបាលសង្គមរាស្ត្រនិយមៗ ការបះបោរផើបឡើងភ្លាមៗបណ្តាលឲ្យកងទ័ពស្លាប់ និងមានការរឹបអូសអាវុធដោយកសិករដែលបះបោរ ទោះជាយ៉ាងនេះក្តីមេដឹកនាំ ប.ក.ក. យល់ថាបក្សមិនទាន់បានត្រៀមរៀបចំគម្រោង គ្រប់គ្រាន់ដើម្បីចាប់ផ្តើមបដិវត្តន៍ប្រដាប់អាវុធនៅឡើយទេៗ*

**២១១.** សម្តេច នរោត្តម សីហនុ បានស្ទើបន្ទោសទៅលើ «ក្រុមខ្មែរវៀតមិញ» ដែលនៅបន្តអត្ថិភាពក្រោយឆ្នាំ ១៩៥៤ ហើយបានប្រកាសជាសាធារណៈថា ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ គឺជាមេដឹកនាំក្រុមនេះ និងបានគំរាមប្រើតុលាការយោធាដើម្បីកាត់ទោសពួកគេ។ ស្ថានភាពគ្រោះថ្នាក់នេះបានធ្វើឲ្យ នួន ជា នាំពួកគេទាំងបីរូបចូលទៅព្រៃម៉ាគី ដែលធ្វើឲ្យមានពាក្យចចាមអារ៉ាមថាពួកឆ្វេងនិយមត្រូវបានសម្តេច នរោត្តម សីហនុ សម្លាប់ បុកឯកម្លាំងរបស់នាយករដ្ឋមន្ត្រី លន់ នល់ សម្លាប់។

**២១២.** ហេតុការណ៍នៅសំឡូត បានជំរុញឲ្យមានការបះបោរបន្ថែមទៀត ហើយនៅថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៦៨ មានការវាយប្រហារប្រដាប់អាវុធមួយនៅបាយតម្រាំ ខេត្តបាត់ដំបង ដែលបណ្តាលឲ្យក្រុមអ្នកតស៊ូរឹងដណ្តើមយកអាវុធបន្ថែមទៀតពីប៉ុស្តិ៍នគរបាល។ ទោះបីជាមិនមានភាពច្បាស់លាស់ថា តើ ប.ក.ក. បានដើរតួនាទីច្រើននៅក្នុងការបះបោរដែរឬទេក៏ដោយ ប៉ុន្តែនៅពេលក្រោយមក បក្សបានអនុម័តយកព្រឹត្តិការណ៍នេះជាការចាប់ផ្តើមការតស៊ូប្រដាប់អាវុធ និងជាកាលបរិច្ឆេទបង្កើតកងទ័ពបដិវត្តន៍កម្ពុជា។ ក្រុមដែលកើតឡើងមុនកងទ័ពបដិវត្តន៍កម្ពុជានានាពេលនោះ គឺជាកងការពារសម្ងាត់ដែលក្នុងនោះមានក្រុម សន្តិសុខជាអង្គការចាត់តាំងដោយស្ម័គ្រ ដែលមានកុមារៗជាអ្នកការពារកម្មាភិបាលមូលដ្ឋាន។

**២១៣.** នៅក្នុងរយៈពេលពីរឆ្នាំក្រោយមក ចលនា ប.ក.ក. បានបង្កើនសកម្មភាពខ្លាំងឡើងៗនៅតាមបណ្តាខេត្តនានា ហើយនៅឆ្នាំ១៩៧០ បានកាន់កាប់ឬត្រួតត្រាប្រហែលជាជិតមួយភាគប្រាំនៃដែនដីទាំងមូលរបស់កម្ពុជា។

**២១៤.** ចាប់ពីខែមីនា ឆ្នាំ១៩៦៩ ដោយមានការអនុញ្ញាតពីសម្តេច សីហនុ សហរដ្ឋអាមេរិកបានចាប់ផ្តើមយុទ្ធនាការទម្លាក់គ្រាប់បែកតាមយន្តហោះប្រឆាំងនឹងពួកកុម្មុយ-និស្តវៀតណាមខាងជើងនៅលើទឹកដីកម្ពុជា ដែលជំរុញប្រទេសកម្ពុជាចូលទៅក្នុងសង្គ្រាមវៀតណាម។ វត្តមានរបស់ទ័ពវៀតណាមខាងជើងពីម៉ឺននាក់ នៅក្នុងប្រទេសកម្ពុជា នៅត្រឹមចុងឆ្នាំនោះបានបង្ហាញជាសាធារណៈពីការបញ្ចប់គោលនយោបាយអព្យាក្រឹត្យមិនលម្អៀងរបស់សម្តេច នរោត្តម សីហនុ ដែលជាក់ស្តែងបានបញ្ចប់តាំងពីក្រោយពេលវៀតកុងបានចាប់ផ្តើមដឹកនាំដញ្ជូនអាវុធយុទ្ធភណ្ឌរបស់ចិនឆ្លងកាត់ប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៦៥ មកម្ល៉េះ។ នៅពេលដឹងថា ការរួមគ្នាក្នុងប្រទេសវៀតណាម ដែលដឹកនាំដោយពួកកុម្មុយនីស្ត បានបង្កហានិភ័យទៅលើប្រទេសជាតិនោះ សម្តេច នរោត្តម សីហនុ បានចាប់ផ្តើមភ្ជាប់ចំណងការទូតជាមួយសហរដ្ឋអាមេរិកឡើងវិញ ហើយបានបង្គាប់ឲ្យនាយករដ្ឋមន្ត្រី លន់ នល់ ដែលទើបតែងតាំងជាថ្មី និងគាំទ្រសហរដ្ឋអាមេរិកឲ្យចាត់វិធានការដើម្បីបញ្ចប់ការគំរាមកំហែងរបស់ពួកកុម្មុយនីស្តនៅក្នុងស្រុក។

**២១៥.** បន្ទាប់ពីបានកត់សម្គាល់ឃើញពីជម្លោះដោយសម្ងាត់រវាង សម្តេច នរោត្តម សីហនុ និងនាយករដ្ឋមន្ត្រីរបស់ព្រះអង្គ និងដឹងអំពីគ្រោះថ្នាក់របស់គោលនយោ-បាយរដ្ឋាភិបាលរបស់អ្នកស្តាំនិយមដែលគាំទ្រសហរដ្ឋអាមេរិកចំពោះចលនាបដិវត្តន៍កម្ពុជា នៅពាក់កណ្តាលឆ្នាំ១៩៦៩ គណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក. បានធ្វើការពិចារណាទៅលើគោលនយោបាយរបស់បក្សដែលមានគោលដៅប្រឆាំងនឹង សម្តេច នរោត្តម សីហនុ ហើយបានផ្លាស់ប្តូរគោលដៅទៅប្រឆាំងនឹង លន់ នល់ វិញ។

### ៣.១.២. ឆ្នាំ១៩៧០៖ ការផ្តួលរំលំសម្តេច នរោត្តម សីហនុ និងការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា

**២១៦.** ត្រឹមខែមីនា ឆ្នាំ១៩៧០ ការមិនពេញចិត្តផ្នែកនយោបាយ និងផ្នែកសង្គមកាន់តែមានការកើនឡើងចំពោះកងកម្លាំងកុម្មុយនីស្តវៀតណាមដែលនៅភាគខាងកើតប្រទេសកម្ពុជាដែលនាំឲ្យមានបាតុកម្មនៅខេត្តស្វាយរៀង និងការវាយកម្ទេចស្ថានបេសកម្មទូតរបស់វៀតណាមខាងជើង និងស្ថានបេសកម្មការទូតរបស់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូងនៅទីក្រុងភ្នំពេញ ដោយការវាយកម្ទេចនេះត្រូវបានធ្វើឡើងដោយបាតុករ មន្ត្រីរាជការ និងកងទ័ពដែលត្រូវបានកេណ្ឌប្រមូលតាមរាជបញ្ជារបស់សម្តេច នរោត្តម សីហនុ។

លន់ នល់ បានចេញសេចក្តីថ្លែងការណ៍មួយ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧០ ទាមទារឲ្យដកកងទ័ពកុម្មុយនីស្ត វៀតណាម ទាំងអស់ចេញពីទឹកដីប្រទេសកម្ពុជា ហើយបានទៅចរចាចងសម្ព័ន្ធភាពជាមួយនឹងរបបវៀតណាមខាងត្បូងដែលគាំទ្រដោយសហរដ្ឋអាមេរិក។

**២១៧.** សភាជាតិ និងរដ្ឋាភិបាលកាន់តែលែងមានភាពអត់ធ្មត់ជាមួយនឹងការគ្រប់គ្រងរបស់ សម្តេច នរោត្តម សីហនុ។ ដោយមានការជំរុញពីសំណាក់ឧបនាយករដ្ឋមន្ត្រីទ្រង់សិរីមតៈ លន់ នល់ បានចុះហត្ថលេខា លើក្រឹត្យមួយ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧០ គាំទ្រដល់ការទម្លាក់សម្តេច នរោត្តម សីហនុ ដែលកំពុងគង់នៅទីក្រុងម៉ូស្គូ នាពេលនោះ។ នៅថ្ងៃបន្ទាប់ សភាជាតិបានអនុម័តលើការបោះឆ្នោតសម្តែងការមិនទុកចិត្តដាក់លើ សម្តេច នរោត្តម សីហនុ ដោយបានទម្លាក់ព្រះអង្គចេញពីតំណែង ជាព្រះប្រមុខរដ្ឋ។

**២១៨.** នៅពេលត្រូវប្រឈមជាមួយហេតុការណ៍ទាំងអស់នេះ ទើបនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុបានប្រកាសតាមវិទ្យុដែលផ្សាយចេញពីទីក្រុងប៉េកាំង អំពីការបង្កើតចលនានយោបាយមួយគឺរណសិរ្សរួបរួមជាតិកម្ពុជា ហើយព្រះអង្គក៏បានអំពាវនាវឲ្យជនរួមជាតិរបស់ព្រះអង្គ ចូលរួមក្នុងការតស៊ូវាយប្រយុទ្ធទៅលើពួកដែលជំរុញឲ្យមានរដ្ឋប្រហារ ដោយព្រះអង្គបានសន្យាផ្តល់ការបណ្តុះបណ្តាលផ្នែកយោធា និងការផ្តល់ឲ្យនូវអាវុធយុទ្ធភណ្ឌ។ ការអំពាវនាវនេះមិនមែនជាស្នាមព្រហស្តរបស់សម្តេច ព្រះនរោត្តម សីហនុទាំងស្រុងឡើយ។ ព្រះអង្គពុំបានដឹងថា សំណើដំបូងរបស់ព្រះអង្គត្រូវបាននាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ប្រគល់ទៅឲ្យ ប៉ុល ពត នៅក្នុងកិច្ចពិភាក្សាជាមួយបក្សកុម្មុយនីស្តចិន នៅទីក្រុងប៉េកាំង ក្នុងនាមជាប្រមុខប្រតិភូ ប.ក.ក. នៅពេលនោះទេ ដោយ ប៉ុល ពត បានលុបចោលចំណុចមួយចំនួនដែលនិយាយទៅដល់សង្គមនិយម ប្រហែលជាក្នុងគោលបំណងដើម្បីឲ្យមានការគាំទ្រពីប្រជាជនឲ្យបានច្រើនចំពោះរណសិរ្សរួបរួមជាតិកម្ពុជា។

**២១៩.** សម្ព័ន្ធភាពរវាងសម្តេច នរោត្តម សីហនុ និងជនកុម្មុយនីស្តកម្ពុជា នៅពេលនោះ បានផ្តល់ប្រយោជន៍ដល់គ្នាទៅវិញមក។ ដោយមិនបានជួបជាមួយសម្តេច នរោត្តម សីហនុ នៅក្នុងទីក្រុងប៉េកាំង ប៉ុល ពត បានបញ្ជូនលិខិតមួយដែលគាំទ្រដល់រណសិរ្សរួបរួមជាតិកម្ពុជាក្នុងនាម ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ ។ តាមរយៈការអនុវត្តកិច្ចការមួយនេះ ប៉ុល ពត បានបង្ហាញមុខ «ខ្មោចទាំងបី» ដែលនៅលាក់ខ្លួនក្នុងព្រៃម៉ាគី ហើយជាទូទៅត្រូវបានគេជឿជាក់ថាបានស្លាប់ទៅ ហើយនោះ ឲ្យមកធ្វើជាមុខមាត់នៃក្រុមឆ្វេងនិយមកម្ពុជាដែលមកតាមរយៈនេះ បានទាញយកផលប្រយោជន៍ពីកេរ្តិ៍ឈ្មោះខាងនយោបាយរបស់ពួកគេ ហើយបន្តរក្សាការសម្ងាត់អំពីអត្តិភាពរបស់ ប.ក.ក. ។

**២២០.** នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុ បានបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយ គឺរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ សម្តេច នរោត្តមសីហនុ ត្រូវបានប្រកាសជាប្រមុខរដ្ឋ និងជាព្រះប្រធានរណសិរ្សរួបរួមកម្ពុជា។ ចំណែក ខៀវ សំផន ត្រូវបានតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ។ តាមពិតទៅ ខៀវ សំផន ត្រូវបាន ប៉ុល ពត តែងតាំងមុខតំណែងនេះទាំងគាត់មិនបានដឹងខ្លួននោះទេ។ នៅពេលក្រោយមក ខៀវ សំផន បានដើរតួនាទីជាអ្នកទំនាក់ទំនងរវាង សម្តេច សីហនុ និង ប៉ុល ពត បន្ទាប់ពីគាត់ត្រូវបានបញ្ចូលទៅជាសមាជិក ប.ក.ក. កាលពីឆ្នាំមុនដោយតាម៉ុក។ ហ៊ូ នឹម បានទទួលតំណែងជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការរបស់រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ចំណែក ហ៊ូ យន់ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីសួងមហាផ្ទៃ កំណែទម្រង់ឃុំ និងសហករណ៍ ហើយ អៀង ធីរិទ្ធ, ជូ ជេត និង កុយ ធួន ទទួលបានតំណែងជាអនុរដ្ឋមន្ត្រីក្នុងរដ្ឋាភិបាលនិរទេសនេះ។

**២២១.** គោលនយោបាយផ្លូវការរបស់រណសិរ្សរួបរួមជាតិកម្ពុជា គឺបង្រួបបង្រួម និងកៀងគរប្រមូលប្រជាជនគ្រប់ស្រទាប់វណ្ណៈសង្គម «ផ្តួលរំលំរបបផ្តាច់ការប្រកាន់ពូជសាសន៍ ហ្វា ស៊ីស អាយ៉ងចក្រពត្តិអាមេរិក ដែលដឹកនាំដោយ លន់ នល់ និង សិរិមតៈ។ រណសិរ្សរួបរួម

ជាតិកម្ពុជាបានសន្យាផ្តល់ដល់ប្រជាជនកម្ពុជាគ្រប់រូបនូវសេរីភាព ជំនឿសាសនា និងធានានូវសិទ្ធិកាន់កាប់និងបន្តបង្កើនផល ព្រមទាំងប្រកាន់យកគោលនយោបាយការបរទេសអព្យាក្រឹតនិងកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានា រួមទាំងវៀតណាមផងដែរ។ រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងជាពិសេស ខៀវ សំផន បានគាំទ្រជាផ្លូវការដល់ចក្ខុវិស័យនេះ។ រណសិរ្សរួបរួមជាតិកម្ពុជា បានបន្តបង្កើតស្ថានីយវិទ្យុនៅទីក្រុងហាណូយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ អៀង ធីរិទ្ធ ដោយស្ថានីយវិទ្យុនេះត្រូវបានប្រើប្រាស់សម្រាប់ជ្រើសរើសកម្មាភិបាល និងប្រមូលការគាំទ្រដល់រណសិរ្សរួបរួមកម្ពុជា ព្រមទាំងផ្សព្វផ្សាយឃោសនាទាំងក្នុងក្រៅប្រទេសកម្ពុជា។

**២២២.** ភ្លាមៗនោះ វៀតណាមខាងជើងនិងប្រទេសចិនបានទទួលស្គាល់រាជរដ្ឋាភិបាលនិរទេសនេះ គឺគ្រាន់តែជាខែលបិទបាំងប៉ុណ្ណោះ។ ជាដំបូងសម្តេច នរោត្តម សីហនុ បានដឹកនាំរដ្ឋាភិបាលនេះនៅទីក្រុងប៉េកាំង ក្នុងនាមជាតួអង្គសំខាន់មួយនៃការបង្រួបបង្រួមជាតិ និងភាពស្របច្បាប់ផ្នែកនយោបាយ។ ក្រៅពីទាក់ទាញការគាំទ្រកាន់តែច្រើនទៀតនៅក្នុងប្រទេសកម្ពុជាពីសំណាក់កសិករ ដែលមានស្មារតីភក្តីចំពោះអតីតព្រះមហាក្សត្រសម្តេច នរោត្តម សីហនុបានអំពាវនាវឲ្យប្រជាជនកម្ពុជាចូលរួមនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា (ពោលគឺដើម្បីបុព្វហេតុរបស់ ប.ក.ក.) ហើយបានស្វែងរកការគាំទ្រនិងទទួលស្គាល់ពីអន្តរជាតិ សម្រាប់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ ជាមួយនឹងការចេញសេចក្តីអំពាវនាវដោយព្រះអង្គឯង តាមរយៈវិទ្យុពីទីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុបានប្រកាសថា រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់ការលើកលែងទោសចំពោះអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរទាំងឡាយណា ដែលបានទទួលស្គាល់ «កំហុសធ្ងន់ធ្ងររបស់ខ្លួនចំពោះប្រទេស» ហើយយល់ព្រមចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា។ បន្ទាប់ពីមានការយល់ព្រមពី ប៉ុល ពត និង នួន ជា រួចមកសម្តេច សីហនុ បានធ្វើព្រះរាជទស្សនកិច្ចទៅតំបន់រំដោះរបស់ខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៣ ដើម្បីផ្តល់ការគាំទ្រដល់ការតស៊ូប្រដាប់អាវុធប្រឆាំងនឹងកងកម្លាំងរបស់ លន់ នល់។ យ៉ាងណាមិញ នៅក្នុងស្រុក សម្តេច នរោត្តម សីហនុ ត្រូវបានបក្សរារាំងសកម្មភាព ដោយព្រះអង្គបានមានព្រះបន្ទូលត្អូញត្អែរជាសាធារណៈថា «នៅថ្ងៃដែលខ្មែរក្រហមលែងត្រូវការខ្ញុំ ពួកគេនឹងខ្ជាក់ខ្ញុំចោលដូចជាគ្រាប់ឆឺរី» ។ តាមពិតទៅ ប.ក.ក. បានកាត់បន្ថយចូលរួមរបស់សម្តេច នរោត្តម សីហនុ និងបានជំរុញមិនឲ្យសមាជិកបក្សផ្តល់សារសំខាន់ជាដុំកំភួនចំពោះតួនាទីរបស់ព្រះអង្គ នៅក្នុងជោគជ័យរបស់រណសិរ្សនេះនោះឡើយ។

**២២៣.** ត្រឹមពាក់កណ្តាលឆ្នាំ១៩៧០ ប.ក.ក. បានពង្រឹងការគ្រប់គ្រងរបស់ខ្លួនទៅលើរណសិរ្សរួបរួមជាតិកម្ពុជា។

### ៣.១.៣. ឆ្នាំ១៩៧០ ដល់ទី១៧ មេសា ឆ្នាំ១៩៧៥ «បដិវត្តន៍ប្រជាជនប្រជាធិបតេយ្យ»

**២២៤.** ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧០ មកជម្លោះក្នុងរបបសាធារណរដ្ឋខ្មែរដែលទើបប្រកាសថ្មីៗ រួមជាមួយនឹង ប.ក.ក. គឺជាការផ្តួលរំលំរដ្ឋាភិបាល លន់ នល់ ហើយស្វែងរកជម្រកលាក់ខ្លួនរបស់ពួកគេនៅក្នុងប្រទេសកម្ពុជានិងបន្តផ្តល់អាវុធទៅឲ្យពួកវៀតកុងនោះដោយបានធានាផ្តល់អាវុធដល់ ប.ក.ក.។ នៅចុងខែមេសា ឆ្នាំ១៩៧០ កងទ័ពវៀតណាមខាងជើងនិងកងទ័ពវៀតកុងចំនួនប្រមាណពី៣៥.០០០នាក់ទៅ៤០.០០០នាក់ បានចាប់ផ្តើមការវាយប្រហារទៅលើកងកម្លាំងសាធារណរដ្ឋខ្មែរនៅភាគខាងកើតនៃប្រទេសកម្ពុជា ហើយភ្លាមៗនោះ បានប្រឈមមុខនឹងកងទ័ពជំនួយរបស់វៀតណាមខាងត្បូង និងសហរដ្ឋអាមេរិកដែលមានកម្លាំងប្រហាក់ប្រហែលគ្នា។ ក្នុងពេលដែលខ្លួនត្រួតត្រាទឹកដីកម្ពុជាបានមួយភាគធំ ពួកកុម្មុយនីស្តវៀតណាមបានអនុវត្ត «អំណាចរដ្ឋចំណុះ» ផ្នែករដ្ឋបាល មន្ទីរពេទ្យ សាលាបណ្តុះបណ្តាលនយោបាយ និងយោធានៅក្នុងប្រទេសនេះ ។

**២២៥.** សាធារណរដ្ឋខ្មែរបានអនុម័តជាសាធារណៈនូវមាគ៌ាប្រឆាំងនឹងចក្រពត្តិ ដែលសំដៅផ្តោះទៅរក

ប្រទេសជិតខាងភាគខាងកើត។ ដោយឈរលើមូលដ្ឋានទំនាស់បដិបក្ខខាងប្រវត្តិសាស្ត្រ និងវប្បធម៌ មាគ៌ាបែបហោរាសាស្ត្រនេះ ត្រូវបានប្រើប្រាស់ភាគច្រើនក្នុងទសវត្សរ៍ឆ្នាំ១៩៧០ (ហើយក្រោយមកត្រូវបាន ប.ក.ក. ប្រើបន្តទៀត) ដែលបណ្តាលឲ្យមានការកំណត់គោលដៅនិងការសម្លាប់ជនស៊ីវិលវៀតណាមក្នុងចំនួនដ៏ច្រើនដោយកងកម្លាំងរបស់រដ្ឋាភិបាល លន់ នល់។

**២២៦.** ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ១៩៧០ គណៈកម្មាធិការមជ្ឈិម ប.ក.ក បានប្រើមាគ៌ាដែលមានភាពបត់បែន ដោយសារមានទំនាក់ទំនងល្អជាមួយនឹងពួកកុម្មុយនីស្តវៀតណាម ពោលគឺដោយសារតែការសន្យារបស់ពួកកុម្មុយនីស្តវៀតណាមថា នឹងដកចេញពីតំបន់រំដោះ នៅពេលដែលកម្ពុជាអាចជំនួសពួកគេបាន។ មាគ៌ានេះត្រូវបានផ្លាស់ប្តូរបន្តិចក្រោយមក បន្ទាប់ពីមហាសន្និបាតលើកទីបីរបស់ ប.ក.ក. នៅខែកញ្ញា ឆ្នាំ១៩៧១ ដោយនៅក្នុងសន្និបាតនោះ មេដឹកនាំបានសម្រេចថា វៀតណាមគឺជា «សត្រូវស្រួចស្រាវ» យូរអង្វែងរបស់កម្ពុជា។ មហាសន្និបាតនេះ មានការចូលរួមលើកដំបូងពីរដ្ឋមន្ត្រីរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា គឺ ហ៊ូ នឹម, ហ៊ូ យន់ និង ខៀវ សំផន ព្រមទាំងជនកម្ពុជាមួយចំនួនដែលត្រូវបានគេអះអាងថាមានទំនាក់ទំនងជាមួយនឹងវៀតមិញ និងបានត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងពេលដែលវៀតណាមខាងជើងបានលុកលុយកាលពីមួយឆ្នាំមុនមកនោះ។ ខៀវ សំផន ត្រូវបានតែងតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិម ក្នុងនាមជាសមាជិកបម្រុងរួមជាមួយនឹង ជូ ជេត, កែវ ពក និង កុយ ធួន។ មហាសន្និបាតបានប្រកាសទទួលស្គាល់ឈ្មោះនៃ ប.ក.ក ដែលត្រូវបានអនុម័តកាលពីប្រាំមួយឆ្នាំមុនដោយគណៈកម្មាធិការមជ្ឈិម និងបានអនុម័តទៅលើលក្ខន្តិកៈបក្សដែលស្ទើរតែមិនអាចមានការផ្លាស់ប្តូរអ្វីទាល់តែសោះ ដែលបន្តដើរតាមមាគ៌ាបក្សលេនីន នៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ, ប្រជាធិបតេយ្យប្រមូលផ្តុំ និងការប្រឆាំងនឹងពួកចក្រពត្តិនិយម និងសក្តិភូមិនិយម។

**២២៧.** នៅពេលដែលគណៈកម្មាធិការមជ្ឈិម ប.ក.ក. បានកោះប្រជុំក្នុងខែឧសភា ឆ្នាំ១៩៧២ កងកម្លាំងរបស់ខ្មែរក្រហមដែលធ្វើការវាយប្រយុទ្ធក្រោមស្លាកកងទ័ពប្រជាជនកម្ពុជា គឺជាកងកម្លាំងសំខាន់ជាងគេនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅតែមិនអាចមានអាវុធគ្រប់គ្រាន់សម្រាប់តទល់ជាមួយវៀតណាម។ គណៈកម្មាធិការក៏បានចេញ «សេចក្តីណែនាំបន្ទាប់»មួយដែលអំពាវនាវឲ្យបក្សពង្រឹង «គោលជំហរអធន» របស់ខ្លួន និងការតស៊ូប្រឆាំងវណ្ណៈជិះជាន់ដែលព្យាយាមការពារសិទ្ធិរបស់ពួកគេនៅក្នុងរបបថ្មីនេះ។

**២២៨.** នៅក្នុងខែមករា ឆ្នាំ១៩៧៣ កិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានចរចារវាងរដ្ឋាភិបាលវៀតណាម និងរដ្ឋាភិបាលសហរដ្ឋអាមេរិក ដោយស្នើឲ្យសហរដ្ឋអាមេរិកដកខ្លួនចេញពីជម្លោះវៀតណាម ហើយតម្រូវឲ្យមានការដកកម្លាំងវៀតណាមខាងជើងចេញពីប្រទេសកម្ពុជា។ ក្នុងកិច្ចប្រឹងប្រែងដើម្បីទទួលបានកិច្ចព្រមព្រៀង វៀតណាមខាងជើងក៏បានបញ្ឈប់ការផ្តល់គ្រឿងសព្វាវុធយោធាមកឲ្យ ប.ក.ក. ដែលធ្វើឲ្យទំនាក់ទំនងដែលបានធ្លាក់ចុះរួចមកហើយតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៦០នោះ កាន់តែចុះដុនដាបខ្លាំង ដោយសារតែការបន្តប្រឆាំងរបស់ទីក្រុងហាណូយ ចំពោះការតស៊ូប្រដាប់អាវុធនៅក្នុងប្រទេសកម្ពុជា។ នៅត្រឹមខែឧសភា ឆ្នាំ១៩៧៣ ស្នាក់ស្នាមចុងក្រោយនៃការបញ្ជារបស់វៀតណាមមកលើកងវិរសេនាធំកុម្មុយនីស្តកម្ពុជា បានរលាយបាត់ទៅហើយ ប៉ុន្តែកងទ័ពវៀតណាមខាងជើងមួយចំនួនបានបន្តនៅជួយ និងការពារការហូរចូលនៃអាវុធរបស់ចិនតាមផ្លូវលំហូជីមិញ។ ទោះបីជា កិច្ចព្រមព្រៀងបាននាំទៅដល់ការលុបបំបាត់កងទ័ពវៀតណាមចេញពីទឹកដីកម្ពុជាក្តី តែខ្មែរក្រហមមានកំហឹងយ៉ាងខ្លាំងដែលវៀតណាមខាងជើង យល់ព្រមតាមកិច្ចព្រមព្រៀងសន្តិភាព ដោយសន្និដ្ឋានថា ការផ្តួចផ្តើមសន្តិភាពនៅក្នុងតំបន់នាពេលនោះតម្រូវឲ្យ ប.ក.ក ចាប់ផ្តើមចរចាជាមួយសាធារណរដ្ឋខ្មែរ ដែលអាចទទួលរងការអន្តរាគមន៍ផ្នែកយោធាពីសហរដ្ឋអាមេរិក។

**២២៩.** ការសង្ស័យរបស់ ប.ក.ក. ត្រូវបានចេញជាការពិតនៅចុងក្រោយ។ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាព

ទីក្រុងប៉ារីស កងទ័ពសហរដ្ឋអាមេរិកបានបង្វែរទិសដៅវាយប្រហារដោយការទម្លាក់គ្រាប់បែកមកលើទឹកដីកម្ពុជា នៅក្នុងយុទ្ធនាការប្រឆាំងនឹងកុម្មុយនីស្តមួយដែលការវាយប្រហារនេះបានបន្តធ្វើរហូតដល់ខែសីហា ឆ្នាំ១៩៧៣។ នៅអំឡុងពេលនោះ សហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែករាប់សែនតោន មកលើទឹកដីប្រទេសកម្ពុជា ដែលបណ្តាលឲ្យបាត់បង់ជីវិតប្រជាជនស៊ីវិលរាប់ម៉ឺននាក់ ហើយបានបំផ្លាញផលដំណាំ រួមទាំង ហេដ្ឋារចនាសម្ព័ន្ធកសិកម្ម សម្លាប់សត្វពាហនៈអស់ជាច្រើន និងបំផ្លិចបំផ្លាញសេដ្ឋកិច្ចជនបទរបស់ប្រទេសនេះផងដែរ។ យុទ្ធនាការទម្លាក់គ្រាប់បែកនោះ បានធ្វើឲ្យប្រជាជននៅតាមជនបទរត់ភៀសខ្លួនចូលទៅនៅទីក្រុង ជាពិសេសនៅទីក្រុងភ្នំពេញដើម្បីស្វែងរកស្បៀងអាហារ និងជម្រក ការវាយប្រហារលើកងទ័ព ប.ក.ក. នេះបានធ្វើឲ្យលទ្ធផលរបស់ខ្មែរក្រហមក្នុងការវាយដណ្តើមយករដ្ឋធានីពីការបំផ្លិចបំផ្លាញ និងស្ថានភាពទុក្ខលំបាកវេទនារបស់ប្រជាជន ដែលបង្កឡើងដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងបានធ្វើយុទ្ធនាការប្រមូលកម្លាំងដោយជោគជ័យ ដោយផ្អែកលើការតស៊ូវណ្ណៈនិងភាពភ័យខ្លាចពីការបំផ្លិចបំផ្លាញ ខ្ទេចខ្ទី មកលើប្រទេសកម្ពុជាពីសំណាក់របប លន់ នល់ និង សហរដ្ឋអាមេរិក។

**២៣០.** ដោយសារមិនមានវៀតណាមនៅរារាំងផ្លូវ ខ្មែរក្រហមបានបង្វែរទិសដៅរបស់ខ្លួនទៅលើការវាយដណ្តើមយកមូលដ្ឋានរឹងមាំមួយចំនួនរបស់សាធារណរដ្ឋខ្មែរដែលនៅសេសសល់។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៤ គណៈកម្មាធិការមជ្ឈិម ប.ក.ក. បានជួបប្រជុំនៅក្នុងភូមិមាយឃុំព្រែកកុក អស់រយៈពេលជាងពីរសប្តាហ៍ ដើម្បីពិភាក្សាពីផែនការវាយប្រយុទ្ធជាលើកចុងក្រោយ ដើម្បីរំដោះនិងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗទៀត។ នៅក្នុងកិច្ចប្រជុំដែលចូលរួមដោយ នួន ជា, ប៉ុល ពត, សោ ភឹម, កុយ ធួន, វន វ៉េត, រស់ ញឹម និង សុន សេន គណៈកម្មាធិការមជ្ឈិមបក្សបានស្រេចថា នឹងដណ្តើមយករដ្ឋធានីនៅក្នុងរដូវប្រាំង ឆ្នាំ១៩៧៤-១៩៧៥។ ស្របជាមួយនឹងការអធិប្បាយប្រវត្តិសាស្ត្រជាផ្លូវការរបស់ ប.ក.ក. នៅពេលក្រោយមក នួន ជា និង ខៀវ សំផនបានអះអាងថា ជាការចាំបាច់ដែលត្រូវរំដោះទីក្រុងភ្នំពេញឲ្យបានមុនពេលវៀតណាមខាងជើងដណ្តើមយកទីក្រុងសៃហ្គន ដើម្បីរារាំងប្រទេសជិតខាងមួយនេះមិនឲ្យគ្រប់គ្រងមកលើប្រទេសកម្ពុជាបាន ក្រោមលេសជំនួយខាងយោធានោះ។ នៅពេលនោះ ហ៊ូ យន់ បានចេញមុខជាចំហរិះគន់ទៅលើសេចក្តីសម្រេចរបស់ ប.ក.ក. រួមទាំងសេចក្តីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ទាំង ហ៊ូ យន់ និង ហ៊ូ នឹម ត្រូវបានបោសសម្អាតចេញពីក្នុងជួរថ្នាក់ដឹកនាំរបស់ ប.ក.ក. នៅប៉ុន្មានឆ្នាំក្រោយមកទៀត រួមជាមួយសមាជិកគណៈកម្មាធិការមជ្ឈិមផ្សេងៗទៀត ដូចជា វន វ៉េត, កែវ មាស និង លេខាភូមិភាគ ៦នាក់គឺ ញឹម រស់ (ភូមិភាគពាយ័ព្យ), សោ ភឹម (ភូមិភាគបូព៌ា ធ្វើអត្តឃាត), ណៃ សារ៉ាន់ (ភូមិភាគឦសាន), ជូ ជេត (ភូមិភាគ បស្ចិម), កុយ ធួន (ភូមិភាគឧត្តរចាស់) និង កង ចាប (ភូមិភាគឧត្តរថ្មី)។

**២៣១.** នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៤ បន្ទាប់ពីការប្រកាសតាមវិទ្យុដោយ ខៀវ សំផន ខ្មែរក្រហមបានរុលទៅមុខសំដៅទៅទីក្រុងភ្នំពេញនៅថ្ងៃបន្ទាប់ ដោយចាប់ផ្តើមការវាយប្រយុទ្ធដោយឥតស្រាកស្រាន្ត ដែលបន្តរហូតដល់ពាក់កណ្តាលខែមេសា។ កងទ័ពភូមិភាគបូព៌ា និងភូមិភាគពិសេស ដែលស្ថិតនៅក្រោមបញ្ជារួមរបស់នាយសេនាធិការ សុន សេន និងលេខាភូមិភាគឧត្តរ កុយ ធួន បានចាប់ផ្តើមការបាញ់ផ្លោងទៅលើក្រុងភ្នំពេញដោយប្រើគ្រាប់រ៉ុកកែត និងអាវុធយុទ្ធភណ្ឌផ្សេងៗទៀត។ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៥ រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា បានចេញសេចក្តីប្រកាសព័ត៌មានដោយ ខៀវ សំផន ប្រកាសថា លន់ នល់ គឺជាជនក្បត់ម្នាក់ក្នុងចំណោម «ជនក្បត់ទាំងប្រាំពីរ» នៃសាធារណរដ្ឋខ្មែរ «មេដឹកនាំរដ្ឋប្រហារក្បត់ជាតិ» ដោយបញ្ជាក់ថារដ្ឋបាលប្រកាសថា « ចាំបាច់បំផុតត្រូវតែសម្លាប់ជនក្បត់ទាំងប្រាំពីរនាក់ដោយសារតែអំពើក្បត់ប្រឆាំងនឹងជាតិខ្លួនឯង»។ វិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជា និងការិយាល័យព័ត៌មានរណសិរ្សរួបរួមជាតិកម្ពុជាបានអំពាវនាវម្តងហើយម្តងទៀតឲ្យសម្លាប់មេដឹកនាំសាធារណរដ្ឋខ្មែរនៅ

សប្តាហ៍ក្រោយៗមក ដោយ ខៀវ សំផន បានចេញសេចក្តីអំពាវនាវស្រដៀងគ្នានេះ ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។

**២៣២.** *នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥ លន់ នល់ បានលាលែងពីតំណែង និងបានរត់ភៀសខ្លួនបន្ទាប់ពីកងកម្លាំងរបស់គាត់ទទួលរងបរាជ័យយ៉ាងធ្ងន់ធ្ងរ ពីសំណាក់កងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ ពីរថ្ងៃក្រោយមក ខៀវ សំផន បានចេញសេចក្តីថ្លែងការណ៍មួយប្រកាសថា «ជនក្បត់ទាំងប្រាំពីរ» នៃរបប លន់ នល់ បានរត់ភៀសខ្លួន ខៀវ សំផន បានចាកចេញពីប្រទេស ហើយថា «ចក្រពត្តិអាមេរិក» មានចេតនាពន្យារសង្គ្រាមតាមរយៈការចរចា។*

**២៣៣.** *ផែនការវាយកាន់កាប់ទីក្រុងភ្នំពេញត្រូវបានបញ្ចប់ជាស្ថាពរ នៅក្នុងកិច្ចប្រជុំមួយដែលចូលរួមដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន, វន វ៉េត, កុយ ធួន, កែ ពក, សោ ភឹម និង តាម៉ុក នៅដើម ខែមេសា ឆ្នាំ១៩៧៥។ នៅពេលជាមួយគ្នានោះ បណ្តាលកងពលរបស់កងទ័ពប្រជាជនរំដោះជាតិកម្ពុជា រួមទាំង កងទ័ពកងពលមកពីភូមិភាគរបស់ វន វ៉េត និងភូមិភាគបូព៌ារបស់ សោ ភឹម បានរុលចូលឆ្ពោះទៅកាន់រដ្ឋធានីបន្តិចម្តងៗ។*

**២៣៤.** *នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំសាធារណរដ្ឋខ្មែរដែលនៅសេសសល់ បានបញ្ជូនសារថ្វាយសម្តេច នរោត្តម សីហនុ ដែលគង់នៅក្រុងប៉េកាំង ដោយថ្វាយជូនភ្លាមនូវអំណាចទៅឲ្យរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងស្នើសុំឲ្យមានការធានាថាមិនអាចមានការសងសឹកចំពោះសកម្មភាពរបស់រដ្ឋាភិបាល នៅក្នុងអំឡុងពេលមានអត្ថិភាព។ សម្តេច នរោត្តម សីហនុ ទ្រង់ច្រានចោលនូវការថ្វាយជូននេះភ្លាមៗ ដោយបញ្ជាក់ថា ព្រះអង្គទទួលយកបាន ត្រឹមតែការចុះចាញ់ដោយឥតលក្ខខណ្ឌប៉ុណ្ណោះ ហើយព្រះអង្គបានទទួលឲ្យ «ជនក្បត់លំដាប់លេខមួយ» រត់ភៀសខ្លួនចេញពីប្រទេសទៅ ព្រោះក្នុងនាមជាឧក្រិដ្ឋជនសង្គ្រាម ពួកគេ «មិនសមទទួលបានអ្វីក្រៅពីការព្យួរកឡើយ។*

**២៣៥.** *នៅពីរសប្តាហ៍ មុនពេលដែលវៀតណាមខាងជើងកាន់កាប់ទីក្រុងសៃហ្គុន កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានចូលដល់ទីក្រុងភ្នំពេញនៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។*

## ៣.២ ការបង្កើតសហករណ៍និងមន្ទីរសន្តិសុខនៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥

**២៣៦.** *បន្ទាប់ពីសម្តេច នរោត្តម សីហនុ ត្រូវបានផ្តួលរំលំនៅក្នុងឆ្នាំ១៩៧០ កងកម្លាំងប.ក.ក. បានចាប់ផ្តើមកាន់កាប់និងគ្រប់គ្រងតំបន់ដែលពួកគេបាន«រំដោះ» ពីការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែរ ដោយជ្រកក្រោមស្លាកកងទ័ពប្រជាជនរំដោះជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ ជាផ្នែកមួយនៃការគ្រប់គ្រងរបស់ពួកគេទៅលើតំបន់ទាំងអស់នេះ ខ្មែរក្រហមបានបង្កើតសហករណ៍កសិកម្ម និងមន្ទីរសន្តិសុខ ដោយសហករណ៍និងមន្ទីរសន្តិសុខមួយចំនួននៅបន្តសកម្មភាព នៅពេលរបបកម្ពុជាប្រជាធិបតេយ្យបានបង្កើតនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។*

### ៣.២.១. *ការបង្កើតសហករណ៍មុនឆ្នាំ១៩៧៥*

**២៣៧.** *នៅក្នុងឆ្នាំ១៩៧០ ខ្មែរក្រហមបានកាន់កាប់តំបន់មួយចំនួននៃស្រុកត្រាំកក់ ក្នុងខេត្តតាកែវហើយចាប់ផ្តើមរៀបចំអ្នកភូមិនៅតំបន់ «រំដោះ» ថ្មី ទៅជាក្រុមប្រវាស់ដៃ ឬជាក្រុម «សាមគ្គី» ដើម្បីបង្កបង្កើនផលស្រូវ និងបង្កើនផលិតភាពកសិកម្មដែលក្នុងខណៈពេលនោះបានអនុញ្ញាតឲ្យប្រជាជនមួយចំនួនអាចរក្សាទុកកម្មសិទ្ធិឯកជន និងក្រុមគ្រួសារ ហូបបាយរៀងៗខ្លួន។ សមូហភាវូបនីយកម្ម និងការហូបរួមត្រូវបានអនុវត្តនៅក្នុងស្រុកត្រាំកក់នៅពេលក្រោយមក ហើយបានពង្រីកជាបន្តបន្ទាប់ ដោយមានការប្តូរពីក្រុមសាមគ្គីទៅជាសហករណ៍វិញ។*

**២៣៨.** *ប្រហែលជានៅក្នុងខែឧសភា ឆ្នាំ១៩៧០ កងទ័ពប្រជាជនកម្ពុជា បានកាន់កាប់ទីរួមខេត្តក្រចេះ។ ខុសពីស្ថានភាពនៅក្នុងស្រុកត្រាំកក់ មិនមានភស្តុតាងបង្ហាញថា រដ្ឋបាលខ្មែរក្រហម បានអនុវត្តសហករណ៍កសិកម្មភ្លាមៗឡើយ សាក្សី យុន គីម បានផ្តល់សក្ខីកម្មថា*

«ដំណើរការរកស៊ីអ្នកណារកអីរកទៅ» ហើយ «ទីផ្សារនៅមានធម្មតា អត់មានបញ្ហាអ្វីទាំងអស់» នៅខេត្តក្រចេះ នៅពេលនោះ។ ដោយត្អូញត្អែរពីការរីកឡូតយឺតនៃបដិវត្តន៍ រហូតមកទល់ពេលនេះនៅក្នុងតំបន់«រំដោះ» និងភាពព្រងើយកន្តើយជាទូទៅរបស់ប្រជាជនចំពោះបុព្វហេតុបដិវត្តន៍ ប.ក.ក. បានកំណត់អំណាចសេដ្ឋកិច្ចដែលពួកមូលធននៅរក្សាបន្តពីសង្គមចាស់» ថាជាឧបសគ្គចម្បងរបស់បដិវត្តន៍។ ដោយយោងទៅផ្សារក្រចេះ ធ្វើជាឧទាហរណ៍បង្ហាញពីករណីនេះ ទស្សនាវដ្តីទង់បដិវត្ត នៅពេលក្រោយមកបានពន្យល់ថា « ពាណិជ្ជកម្មបែបនេះមិនអាចបម្រើជីវភាពរបស់ប្រជាជនឡើយ ហើយក៏មិនអាចបម្រើសង្គ្រាមរំដោះជាតិឡើយ» ដោយធ្វើការកត់សម្គាល់ថា ប.ក.ក. «មិនអាចប្រមូលផ្តុំប្រជាជនបានឡើយព្រោះ «ថៅកែនៅតែជាម្ចាស់»។

**២៣៩.** នៅក្នុងកិច្ចប្រជុំក្នុងខែឧសភា ឆ្នាំ១៩៧២ គណៈកម្មាធិការមជ្ឈិម ប.ក.ក. បានសម្រេចបិទផ្សារ និងរៀបចំសហករណ៍។ សេចក្តីសម្រេចបិទទីផ្សារត្រូវបានអនុវត្តភ្លាមៗ នៅក្នុងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមដូចគ្នានឹងការបញ្ចប់ការប្រើប្រាស់រូបិយប័ណ្ណផងដែរ។ បក្សបានលើកមូលហេតុថា ការតស៊ូវណ្ណៈតម្រូវឲ្យលុបបំបាត់ពាណិជ្ជកម្មឯកជន ហើយអនុវត្តការបង្កបង្កើនផលជាសមូហភាពវិញ។ នៅពេលបន្ទាប់មក សាររាចររបស់ ប.ក.ក. បានហៅការបង្កើតសហករណ៍កសិកម្មថា ជាការវាយប្រយុទ្ធដោយផ្ទាល់ទៅលើពួកសក្តិភូមិ និងជាវិធានការចាំបាច់ដើម្បី «បំពាក់កម្លាំងដល់ប្រជាជនមូលដ្ឋាន និងជំរុញសម្ព័ន្ធភាពរឹងមាំរវាងកម្មករ និងកសិករ។

តាមរយៈការបញ្ជាក់បំភ្លឺនៅក្នុងតុលាការអំពីទំនាស់បដិបក្ខរវាងបក្ស និង« ពួកសក្តិភូមិ» នួនជា បានពន្យល់ថា ប្រសិនជាគ្មានសហករណ៍ «ពួកអ្នកម្ចាស់ដីយោរយៅ[..] ឲ្យបុលលុយកាក់អីហ្នឹង វាយកការថ្លៃណាស់» ដែលអាចទទួលយកបានប្រយោជន៍ «ដូចជា ឧបមាស្រូវខ្ចីដប់ថាំងយកការមានតែប្រាំថាំងអីឯណោះ»។

**២៤០.** បន្ថែមពីលើមាគ៌ាបក្សជាផ្លូវការនោះ ជនជាប់ចោទបានផ្តល់ហេតុផលបន្ថែមទៀតដើម្បីគាំទ្រការអនុវត្ត។ នួន ជា បានលើកឡើងថា ប្រសិទ្ធផលសេដ្ឋកិច្ចតម្រូវឲ្យប្រមូលផ្តុំធនធានពលកម្មដើម្បីបង្កើនការផលិតស្រូវ។ ខៀវ សំផន បានផ្តល់យោបល់ថា ការគ្រប់គ្រងទៅលើការផលិតនិងការផ្គត់ផ្គង់ស្រូវអង្ករ នឹងរារាំងមិនឲ្យមានការប្រមូលផ្តុំការផលិតស្រូវអង្កររបស់កម្ពុជានៅក្នុងកណ្តាប់ដៃកងទ័ពវៀតណាម ដែលអាចបង្កការប៉ះពាល់ដល់ខ្មែរក្រហម លុះត្រាតែធ្វើដូច្នេះ ទើបអាចរក្សាឯករាជ្យភាពរបស់ប្រទេសបាន។

**២៤១.** ទាំង នួន ជា និង ខៀវ សំផន សុទ្ធតែបានអះអាងថា ការអនុវត្តកម្មវិធីសមូហភាពដោយបង្ខំតាមរយៈសហករណ៍ ដែលនឹងជួយលុបបំបាត់ជាបណ្តើរៗនូវកម្មសិទ្ធិឯកជន និងការគ្រប់គ្រងដោយឯកជនទៅលើសេដ្ឋកិច្ចនៅក្នុងតំបន់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម គឺជាការចាំបាច់ដើម្បីធានាបាននូវស្បៀងអាហារគ្រប់គ្រាន់និងដោះស្រាយការលំបាកនៃសង្គ្រាមប្រឆាំងនឹងសាធារណរដ្ឋខ្មែរ និងយុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកក្នុងពេលជាមួយគ្នានោះដែរ។ តាមពិតទៅសង្គ្រាមស៊ីវិលបានបណ្តាលឲ្យមានសម្ពាធអតិផរណា ដែលធ្វើឲ្យមានកង្វះទំនិញយ៉ាងខ្លាំង។ ផលស្រូវទូទាំងប្រទេសបានថយចុះប្រមាណ ៥០ទៅ៨០% នៅចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ឯទីភ្នាក់ងារផ្តល់ជំនួយបានព្យាយាមបង្កើនស្តុកស្រូវអង្ករដែលមានតិចនៅពេលនោះ ខណៈដែលស្រូវអង្ករនាំចូលមានចំនួនច្រើនជាងស្រូវអង្ករនាំចេញ។

**២៤២.** ទោះបីជាសេចក្តីសម្រេចបង្កើតសហករណ៍មិនត្រូវបានប្រកាសជាសាធារណៈរហូតដល់ ខែឧសភា ឆ្នាំ១៩៧៣ ក៏ដោយ ក៏ខ្មែរក្រហមបានចាប់ផ្តើមចាត់ចែងអ្នកភូមិនៅក្នុងតំបន់ «រំដោះ» តាំងពីឆ្នាំ១៩៧១ ឬ១៩៧២ ទៅជា «ក្រុមប្រវាស់ដៃ» ឬ «ក្រុមសាមគ្គី» ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងសហករណ៍ដែលបានរៀបចំនៅស្រុកត្រាំកក់ពីឆ្នាំ១៩៧០ ដោយក្រុមនីមួយៗមានគ្រួសារប្រមាណពី ៥ ទៅ ១០គ្រួសារ ធ្វើការនៅលើដីរបស់ពួកគេរៀងៗខ្លួន។ ប្រហែលជាចាប់តាំងពីឆ្នាំ១៩៧៣មក ក្រុមទាំងអស់នេះត្រូវបានពង្រីកជាបន្តបន្ទាប់នឹងប្តូរទៅជា «សហករណ៍» ពេញលេញ

*ដោយអ្នកភូមិត្រូវលះបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវធ្វើស្រែនៅលើដីសមូហភាព ហើយត្រូវគោរពតាមការចាត់ចែងឲ្យហូបនិងរស់នៅរួមគ្នា។*

**២៤៣.** *អង្គជំនុំជម្រះមានភ័ស្តុតាងនៅចំពោះមុខដែលថា ត្រឹមឆ្នាំ១៩៧៣ សហករណ៍ត្រូវបានបង្កើតឡើងនៅខេត្តតាកែវ កំពត ព្រះវិហារ សៀមរាប និងមណ្ឌលគិរី។ ការអនុវត្តសហករណ៍នៅមុនឆ្នាំ១៩៧៥ ភាគច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងផលិតផលកសិកម្ម ដូចជាទំនប់ ប្រឡាយ ស្ពាន និងផ្លូវថ្នល់ ព្រមទាំងការផ្លាស់ទីលំនៅប្រជាជននៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ដើម្បីកុំឲ្យពួកគេនៅក្បែរកងទ័ព លន់ នល់។*

### ៣.២.២. *ការបង្កើតមន្ទីរសន្តិសុខមុនឆ្នាំ១៩៧៥*

**២៤៤.** *ខ្មែរក្រហមក៏បានបង្កើតមន្ទីរសន្តិសុខជាច្រើនដែរនៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥។ ក្រាំងតាចាន់ជាមន្ទីរសន្តិសុខតែមួយគត់ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ដែលបានដំណើរការនៅមុនឆ្នាំ១៩៧៥ ដោយមន្ទីរនេះត្រូវបានបង្កើតឡើងនៅក្នុងស្រុកត្រាំកក់ ប្រហែលជានៅក្នុងឆ្នាំ១៩៧៣ឬ ១៩៧៤។ ភ័ស្តុតាងខ្លះៗដែលមាននៅចំពោះមុខអង្គជំនុំជម្រះស្តីពីប្រតិបត្តិការរបស់មន្ទីរសន្តិសុខមុនឆ្នាំ១៩៧៥ បានបង្ហាញថា ក្រាំងតាចាន់ត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំង និងជាកន្លែងអប់រំកែប្រែផងដែរ។*

**២៤៥.** *អង្គជំនុំជម្រះក៏មានភ័ស្តុតាងអំពីអត្ថិភាព និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ ម-១៣ ដែលបានដំណើរ-ការខែកក្កដា ឆ្នាំ១៩៧១ នៅពេលដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ត្រូវបានតែងតាំងជាប្រធានមន្ទីរនេះ។ មន្ទីរសន្តិសុខ ម-១៣ ដែលជាផ្លូវការ គឺជាមន្ទីរនគរបាលភូមិភាគពិសេស ត្រូវបានបែងចែកទៅជាប្រតិបត្តិការចំនួនពីរ។ ម-១៣ក ដែលពីដំបូងស្ថិតនៅភូមិថ្មគុប ឃុំអមលាំង ក្នុងខេត្តកំពង់ស្ពឺ ហើយចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៣ នៅត្រពាំងច្រាប ក្នុងឃុំអមលាំង ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ ឌុច ហើយទទួលខុសត្រូវលើការសួរចម្លើយ និងសម្គាល់បុគ្គលណាដែលគេសង្ស័យថាជាគិញ។ ម-១៣ខ នៅស្អកស្រោត ស្រុកអង្គស្នួល ស្ថិតក្រោមការគ្រប់គ្រងរបស់អនុប្រធានរបស់ ឌុច ហើយមានភារកិច្ចឃុំខ្លួនជាបណ្តោះអាសន្នអ្នកទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសតូចតាច។*

**២៤៦.** *ប្រតិបត្តិការរបស់មន្ទីរសន្តិសុខ ម-១៣ ត្រូវបានគ្រប់គ្រងដោយសមាជិកគណៈកម្មាធិការមជ្ឈិម ប.ក.ក. ដែលពីដំបូងគឺ វន វ៉ែត ពីខែកក្កដា ឆ្នាំ១៩៧១ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៣ និងបន្ទាប់មកគឺ សុន សេន ដែលបន្តរហូតដល់ខែមករា ឆ្នាំ១៩៧៥។ ការណែនាំត្រូវបានបញ្ជូនពីថ្នាក់ដឹកនាំកម្រិតនេះទៅដល់ ឌុច ដើម្បី «ដាក់សម្ពាធ» ទៅលើអ្នកជាប់ឃុំមួយចំនួន ដោយបន្ទាប់ពីមានការណែនាំនេះមក អ្នកជាប់ឃុំទាំងនោះត្រូវបានទទួលរងការប្រមាថ ការវាយដំ និងទម្រង់ផ្សេងៗទៀតនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តយោរយៅ។ ទោះបីជាអ្នកជាប់ឃុំមួយចំនួនត្រូវបានដោះលែងដោយសារការអន្តរាគមន៍របស់ ឌុច ក៏ដោយ ប៉ុន្តែអ្នកផ្សេងទៀត រួមមាន ទាំងកុមារផង បានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំឃាំង ជំងឺ និង «ស្ថានភាពរាងកាយទន់ខ្សោយ»។*

**២៤៧.** *អ្នកជាប់ឃុំនៅមន្ទីរ ម-១៣ក ត្រូវបានទុកឲ្យមានជីវិត ក្នុងគោលបំណងតែមួយគត់គឺដើម្បីសួរចម្លើយ។ ពួកគេទទួលបានរបបអាហារជាកន្ទក់ ដែលជារបបអាហារតិចជាងរបបអាហារដែលគេចែកដល់កម្មាភិបាលមន្ទីរសន្តិសុខ។ ទោះបីជាអ្នកជាប់ឃុំនៅមន្ទីរ ម-១៣ក ខ្លះបានស្លាប់ដោយសារតែអត់អាហារក៏ដោយ តែ ឌុច បានលើកឡើងថា «ជាទូទៅមិនទុកឲ្យដល់ថ្នាក់នុងទេ មើលតែសួរចប់ ជាគោលការណ៍គេឲ្យចេញទៅហើយ»។*

**២៤៨.** *ជាចុងក្រោយ ការកម្ទេច ឬ សម្លាប់ «ជាគោលការណ៍» សំខាន់នៅមន្ទីរ ម-១៣ក។ នៅពេលដែលឌុចយល់ថា ការសួរចម្លើយអ្នកជាប់ឃុំបានពេញលេញគ្រប់គ្រាន់ហើយ គាត់បញ្ជាឲ្យសម្លាប់ពួកគេចោល តាមការណែនាំរបស់ថ្នាក់លើរបស់គាត់។ អ្នកជាប់ឃុំត្រូវបាន*

សម្លាប់ដោយសម្ងាត់ នៅចម្ងាយប្រមាណ១០០ម៉ែត្រ ពីបរិវេណមន្ទីរ ម-១៣ក ជាទូទៅដោយវាយចំពីក្រោយគ្រង់កញ្ចឹងក ដោយដំបងឈើ ឬដំបងឬស្សី។ អ្នកជាប់ឃុំណាដែលព្យាយាមរត់គេចពីបរិវេណនោះនឹងត្រូវគេ «កម្ទេចភ្លាមៗ»។

**២៤៩.** *អ្នកប្រព្រឹត្តកំហុសតូចតាចនៅមន្ទីរ ម-១៣ខ ភាគច្រើនត្រូវបានឃុំឃាំងក្នុងរោងឈើ ដែលមានទទឹងប្រហែលជាពីរម៉ែត្រកន្លះ និងបណ្តោយដប់ម៉ែត្រ ហើយអ្នកខ្លះត្រូវបានគេដោះលែងនៅពេលថ្ងៃឲ្យទៅដាំបន្លែ។ អ្នកជាប់ឃុំបានដោះលែងបន្ទាប់ពីទទួលបានណែនាំពី «ថ្នាក់លើ»។*

**២៥០.** *មន្ទីរសន្តិសុខត្រូវបានបង្កើតឡើងជាបន្តបន្ទាប់នៅក្នុងតំបន់ដែលកាន់កាប់ដោយខ្មែរក្រហមដោយមានមន្ទីរសន្តិសុខម-១៥ នៅក្នុងតំបន់៣៧ នៃភូមិភាគនិរតី ដែលបានដំណើរការតាំងពីមុនមន្ទីរម-១៣ មកម្ល៉េះ។ អង្គជំនុំជម្រះមានភស្តុតាងនៅចំពោះមុខខ្លួនអំពីមន្ទីរសន្តិសុខ ឬមន្ទីរផ្សេងទៀត នៅកំពង់ស្ពឺ (មន្ទីរម-៩៩) គោកក្តួច និងពង្រ ដែលដាក់ឲ្យដំណើរការដោយខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៥ មកម្ល៉េះ។*

## ៣.៣ ជនជាតិចាមនៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥

**២៥១.** *ជនជាតិចាមនៅក្នុងប្រទេសកម្ពុជា មានប្រវត្តិតាំងពីប្រជាជនហិណ្ឌូដើមនៅលើទឹកដីអាណាចក្រចម្ប៉ាដែលស្ថិតនៅភាគកណ្តាល និងភាគខាងត្បូងនៃប្រទេសវៀតណាមបច្ចុប្បន្ននេះ។ នៅត្រឹមសតវត្សរ៍ទី១៦ ភាគច្រើននៃប្រជាជនទាំងនេះបានប្តូរសាសនា ទៅកាន់សាសនាឥស្លាម ដែលបានផ្សព្វផ្សាយមកចម្ប៉ាតាមផ្លូវសមុទ្រ តាមរយៈបណ្តាញពាណិជ្ជកម្មពីមជ្ឈិមបូព៌ា ទៅប្រជុំកោះឥណ្ឌូនេស៊ី និងម៉ាឡាយ៉ា។ សង្គ្រាមរាប់សតវត្សរ៍ជាមួយនឹងសន្តតិវង្សវៀតណាម បានធ្វើឡើងជាសំខាន់នៅពេលដែលរាជាណាចក្រចម្ប៉ាបានដួលរលំ ហើយបន្ទាប់ពីមានរលកនៃទេសន្តរប្រវេសន៍ជាច្រើនលើក មានការផ្លាស់ទីលំនៅប្រជាជនចម្ប៉ាទៅកាន់តំបន់ក្បែរនោះ រួមទាំង ប្រទេសកម្ពុជាផងដែរ។*

**២៥២.** *ជនជាតិចាមនៅតែរក្សាអត្តសញ្ញាណ សាសនា វប្បធម៌ និងជាតិពន្ធដោយឡែករបស់ពួកគេអស់រយៈពេលរាប់សតវត្សរ៍ ចាប់តាំងពីពេលដែលពួកគេមកតាំងទីតាំងនៅក្នុងប្រទេសកម្ពុជា។ នៅមុនឆ្នាំ១៩៧៥ ក្រុមនេះមានភាសានិងអក្សរផ្ទាល់ខ្លួន ប្រតិកម្មសាសនាឥស្លាម មិនបរិភោគសាច់ជ្រូក និងជ្រើសរើសឈ្មោះតាមគម្ពីរអាល់គួរអាន។ ចាម ស្លៀកសម្លៀកបំពាក់ប្រពៃណីដោយឡែករបស់ពួកគេដែរ មានលក្ខណៈខុសពីសម្លៀកបំពាក់របស់ប្រជាជនកម្ពុជា។ ស្ត្រី ប្រើក្រមារុំក្បាលពណ៌ស្រស់ៗ ហើយស្លៀកសំពត់វែង តាមទំនៀមទម្លាប់ បុរសពាក់មួកកាពាស ស្លៀកសារុង និងអាវហ្គុំរ៉ុង គ្របពីលើ។ ទម្លាប់ក្នុងការតុបតែងខ្លួនក៏ខុសគ្នាពីជនជាតិខ្មែរផងដែរ ដោយស្ត្រីចាមទុកសក់វែងគ្របដោយក្រមា ចំណែកឯបុរសទុកពុកចង្ការ។*

**២៥៣.** *ជនជាតិចាមប្រមូលផ្តុំគ្នានៅតាមច្រាំងទន្លេមេគង្គនៅក្នុងខេត្តកំពង់ចាម និងត្រូវបានគេស្គាល់តាមរយៈជំនាញនេសាទត្រីយ៉ាងពូកែរបស់ពួកគេ ហើយពួកគេរស់នៅជាមួយគ្នា នៅក្នុងភូមិពួកគេផ្ទាល់ ដោយកម្ររស់នៅលាយឡំជាមួយជនជាតិខ្មែរណាស់។ ទោះបីជាមិនសូវមានទំនាក់ទំនងសង្គមទៅវិញមកក៏ដោយ តែជនជាតិចាមមានទំនាក់ទំនងល្អជាមួយជនជាតិខ្មែរនៅមុនឆ្នាំ១៩៧៥ រួមទាំងនៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយពួកគេអាចនិយាយភាសាកំណើតរបស់ពួកគេ និងប្រតិបត្តិជំនឿសាសនារបស់ពួកគេដោយសេរី រហូតដល់ឆ្នាំ១៩៧២ ។*

**២៥៤.** *តាមរយៈការព្យាយាមលើកកម្ពស់អត្តសញ្ញាណខ្មែរ នៅដើមទសវត្សរ៍ ១៩៦០ សម្តេច នរោត្តម សីហនុ បានបង្កើតពាក្យ «ខ្មែរឥស្លាម» ដើម្បីសំដៅទៅលើជនជាតិភាគតិចចាម។ ដូចគ្នានឹងពាក្យបច្ចុប្បន្នដែលហៅថា «ចាម» ខ្មែរឥស្លាមសំដៅទៅលើជនជាតិភាគតិចចាម។ ដូចគ្នានឹងពាក្យបច្ចុប្បន្នដែលហៅថា «ចាម» ខ្មែរឥស្លាម សំដៅជារួមទៅលើអនុក្រុមជនកាន់សាសនា ឥស្លាម ទាំងអស់ដែលមានគំណពូជពង្សបុព្វការីជននៅចម្ប៉ា (ចាមនិង ជីហាដ) និងប្រជុំកោះឥណ្ឌូនេស៊ី (ជ្វា) ។*

***(តនៅលេខក្រោយ)***

# រូបថតឯកសារនិងការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម

ស្វូត វិចិត្រ




*ការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅទល់មុខបឹងតាម៉ុក ក្នុងទីរួមស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ស្វូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

កាលពីដើមខែកញ្ញា ឆ្នាំ២០២០ សិស្សានុសិស្សសរុបចំនួន៧នាក់ ក្នុងនោះមានសិស្សស្រីចំនួន៤នាក់ នៃវិទ្យាល័យអន្លង់វែង បានចូលរួមក្នុងវេទិកាថ្នាក់រៀនស្ដីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ វេទិកាថ្នាក់រៀននេះ បង្កើតឡើងក្នុងគោលបំណងជំរុញឲ្យមានការពិភាក្សាទៅលើប្រវត្តិសាស្ត្រ លើកកម្ពស់ការយល់ដឹងអំពីសន្តិភាព និងការផ្សះផ្សា។

សិស្សានុសិស្សនៅក្នុងក្រុមនេះ បានផ្ដោតការចាប់អារម្មណ៍លើបទបង្ហាញ ដែលប្រើប្រាស់កម្រងរូបថតប្រវត្តិសាស្ត្រប្រមាណជិត៤០សន្លឹក ដែលបង្ហាញពីការកកើតបក្សកុម្មុយនីស្តកម្ពុជា, ព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ការជម្លៀសប្រជាជនដោយបង្ខំ និងពលកម្មកុមារនៅតាមការដ្ឋាន។ ជាពិសេស ភាពយន្តឯកសារមួយចំនួនដែលរួមមានបួងគោលអភិវឌ្ឍន៍ស្រុកអន្លង់វែង ក៏ត្រូវបានចាក់បញ្ចាំងដែរ។

ដោយផ្តើមចេញពីបទបង្ហាញដំណាក់កាលដំបូងនេះ សិស្សានុសិស្សក៏បានផ្តោតការពិភាក្សាតាមក្រុមតូចៗ របស់ខ្លួនរយៈពេលប្រមាណជា១៥នាទី អំពីរូបថតទាំងនេះ។ បន្ទាប់មក ប្រធានក្រុមនីមួយៗបានបញ្ចេញទស្សនៈ យោបល់ និងការយល់ឃើញរបស់ក្រុមនីមួយៗ ដោយបានលើកឡើងថា ការដឹកនាំសង្គមមួយតាមលទ្ធិកុម្មុយនីស្ត និងការដាក់សង្គមមនុស្សឲ្យរស់នៅស្មើភាពគ្នាគ្មានវណ្ណៈក្នុងជំនាន់ខ្មែរក្រហម គឺជាស្ថានភាពមួយដែលពិបាកទទួលយកបំផុត ហើយថែមទាំងបានបំបិទសិទ្ធិសេរីភាពរបស់ប្រជាជនទាំងស្រុងដែរ។ ប្រជាជនបានទទួលរងទុក្ខវេទនា និងការរំលោភសិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងរ តាមរយៈការធ្វើការហួសកម្លាំង ការបង្អត់អាហារ និងការសម្លាប់រង្គាលជាដើម។ ផលវិបាកដ៏គួរឲ្យរន្ធត់បានបន្សល់ទុកនូវការស្លាប់ប្រជាជនអស់ជិតពីរលាននាក់។ ក្រុមនីមួយៗក៏បានសង្កត់ធ្ងន់ដែរថា ការមិនអនុញ្ញាតឲ្យមានប្រព័ន្ធអប់រំត្រឹមត្រូវ គឺមិនអាចបណ្តុះធនធានមនុស្ស និងបន្តបង្អាក់ដល់គំនិតបង្កើតថ្មីទៀតផង។ ការណ៍នេះហើយដែលសង្គមមិនអាចឲ្យជឿនលឿនទៅមុខបានទេ ប្រសិនបើកុមារតូចៗមិនទទួលបានការអប់រំយ៉ាងច្រើនសន្ធឹកសន្ធាប់បែបនេះ។

បន្ទាប់មក សិស្សានុសិស្សផ្តោតលើបទបង្ហាញបន្តដែលសុទ្ធសឹងតែជារូបភាពទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ឬគុកទួលស្លែង និងលលាដ៏ក្បាលជនរងគ្រោះ និងរណ្តៅសាកសពរួមនៅឯវាលពិឃាតជើងឯក។ អ្នកទោសប្រមាណ១ម៉ឺន៤ពាន់នាក់ត្រូវបានធ្វើទារុណកម្មសួរចម្លើយនៅគុកទួលស្លែង និងដឹកយកទៅសម្លាប់នៅវាលពិឃាតជើងឯក។ បទបង្ហាញក៏បានភ្ជាប់ទៅនឹងរូបភាពនៃការបង្កើតឲ្យមានតុលាការដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះប្រមាណជិត២លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរស-២១ ឬគុកទួលស្លែង ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលប្រព្រឹត្តទៅនឹងគុកទួលស្លែង។ ឌុចបានស្លាប់នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ កន្លងទៅនេះ។



សិស្សានុសិស្សនៃវិទ្យាល័យអន្លង់វែង ចូលរួមក្នុងវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីដើមខែកញ្ញា ឆ្នាំ២០២០។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្នែកចុងក្រោយនៃវេទិកាថ្នាក់រៀននេះ គឺផ្តោតសំខាន់ទៅលើដំណើរការវិវឌ្ឍន៍ និងការប្រែមុខមាត់ថ្មីនៃសហគមន៍អន្លង់វែង តាមរយៈ វីដេអូឬង់គោលស្រុកអន្លង់វែង ដែលបង្ហាញអំពីចក្ខុវិស័យវែងឆ្ងាយក្នុងដំណើរឆ្ពោះទៅកាន់អនាគតកាល។ ក្នុងនោះ រឿងរ៉ាវរបស់ប្រជាជននៅក្នុងមូលដ្ឋានក៏ត្រូវបានផ្សារភ្ជាប់ទៅនឹងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រទាំង១៤ កន្លែងដែរ ដែលបម្រើឲ្យការចងចាំ ការអប់រំ និងការផ្សះផ្សា។ សិស្សានុសិស្សក្នុងក្រុមបានមើលឃើញពីសក្តានុពលនៃសហគមន៍របស់ខ្លួន ដែលធ្លាប់ជាតំបន់ដ៏ជូរចត់មួយនៃសមរភូមិប្រយុទ្ធចុងក្រោយរបស់ខ្មែរក្រហមថាជាតំបន់ដ៏គួរឲ្យស្ញប់ស្ញែងមួយ និងបង្កប់ទៅដោយរឿងរ៉ាវជាច្រើនរាប់មិនអស់ដែលមនុស្សគ្រប់រូបគួរយល់ដឹង ។

បន្ទាប់ពីវេទិកាថ្នាក់រៀនបានបញ្ចប់ទៅ សិស្សានុសិស្សទាំង ៥នាក់ នៅក្នុងក្រុមក៏បានបញ្ចេញទស្សនយល់ឃើញរៀងៗខ្លួនជុំវិញការរៀនសូត្រតាមរយៈរូបថតនេះ និងទៅលើបញ្ហាផ្សេងៗទាក់ទងទៅនឹងសិទ្ធិកុមារ ការសម្លាប់រង្គាល ជាពិសេស គឺក្តីសង្ឃឹមយ៉ាងមុតមាំចំពោះសហគមន៍របស់ខ្លួនដូចខាងក្រោម៖

**សាន់ ធ្យាំងអេង** ភេទស្រី អាយុ១៧ឆ្នាំ ជាសិស្សនៃវិទ្យាល័យអន្លង់វែងបានយល់ឃើញថា៖ «ការប្រើប្រាស់រូបថតដើម្បីរំលេចរឿងរ៉ាវប្រវត្តិសាស្ត្រនេះ គឺជារបៀបសិក្សាមួយដ៏ល្អបំផុត ពីព្រោះយើងអាចចងចាំបានកាន់តែច្រើនក្នុងរយៈពេលដ៏យូរទៅមុខ។ ក្នុងវេទិកាថ្នាក់រៀននេះ ខ្ញុំចាប់អារម្មណ៍ទៅលើរូបថតមួយចំនួនទាក់ទង

នឹងពលកម្មកុមារក្នុងសហករណ៍។ ខ្ញុំយល់ថា កុមារមិនគួរត្រូវបានប្រើប្រាស់ឲ្យធ្វើការងារទាំងនេះទេ ពីព្រោះវាប៉ះពាល់ដល់ការគិត និងការលូតលាស់របស់កុមារទាំងនោះ។ ខ្ញុំគិតថា កុមារគួរតែទទួលបានការអប់រំជំនួសវិញ។ រាល់ពេលដែលខ្ញុំដាក់ខ្លួនទៅក្នុងស្ថានភាពទាំងនោះម្តងៗ ខ្ញុំមានអារម្មណ៍ថា ពិបាកទទួលយកខ្លាំងណាស់ ពីព្រោះវាមានភាពគ្រោតគ្រាតដល់ផ្លូវអារម្មណ៍។ ទៅថ្ងៃអនាគត ខ្ញុំចង់មើលឃើញពីភាពប្រសើរឡើងនៃសហគមន៍ (អន្លង់វែង) ហើយមិនចង់ឲ្យមានការវិលត្រឡប់ទៅរកស្ថានភាពទាំងនោះទៀតដែរ។ ខ្ញុំចង់ឲ្យមានការអភិវឌ្ឍន៍នូវធនធានដែលយើងមានស្រាប់ក្នុងតំបន់នេះ តាមរយៈទីតាំងប្រវត្តិសាស្ត្រទាំង១៤ចំណុច ដើម្បីបម្រើដល់វិស័យទេសចរណ៍ទាំងពេលបច្ចុប្បន្នផង និងអនាគតផង។»

**ទូច ស៊ាងឡាយ** ភេទស្រី អាយុ១៦ឆ្នាំ បានយល់ឃើញថា៖ «ខ្ញុំមានអារម្មណ៍ថាប្លែក ចំពោះការពិភាក្សាជាក្រុម និងពិពណ៌នាតាមរយៈរូបថតបែបនេះ។ ការប្រើប្រាស់រូបថតដើម្បីរំលេចរឿងរ៉ាវប្រវត្តិសាស្ត្រ គឺធ្វើឲ្យយើងចងចាំនូវខ្លឹមសារទាំងនោះបានកាន់តែច្រើន និងធ្វើឲ្យយើងស្រមើស្រមៃបានកាន់តែខ្ពស់។ ក្នុងចំណោមរូបថតជាច្រើនសន្លឹកដែលបង្ហាញជូនខាងលើនេះ ខ្ញុំចាប់អារម្មណ៍ទៅលើរូបថតមួយចំនួនដែលទាក់ទងទៅនឹងពលកម្មកុមារក្នុងសហ-ករណ៍។ ដំបូងឡើងខ្ញុំស្រមើស្រមៃរូបភាពទាំងនោះមិនចេញទេ ប៉ុន្តែក្រោយពីបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះរួចមក ខ្ញុំក៏ចាប់ផ្តើមយល់បានកាន់តែច្រើន។ ខ្ញុំបានឃើញកុមារតូចៗត្រូវបានខ្មែរក្រហមប្រើប្រាស់ឲ្យធ្វើការងារយ៉ាងមមាញឹក ដែលទាំងនោះគឺជាការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ។ ខ្ញុំមិនចង់ឃើញរូបភាពទាំងនេះនៅជំនាន់ក្រោយទៀតទេ។ ខ្ញុំចង់ឃើញនូវភាពភ្ញីស្វាងនៃសហគមន៍របស់ខ្លួននៅអន្លង់វែងឲ្យមានការទទួលស្គាល់កាន់តែទូលំទូលាយ តាមរយៈការចូលទស្សនាតំបន់ប្រវត្តិសាស្ត្រ និងការពិណាណ៌នានូវរឿងរ៉ាវផ្សេងៗក្នុងតំបន់នេះ។»

**ខេន សុវណ្ណា** ភេទប្រុស អាយុ១៨ឆ្នាំ បានយល់ឃើញថា៖ «ការរៀនសូត្រ តាមរយៈរូបថតនេះ បានផ្តល់ចំណេះដឹងជាច្រើនសម្រាប់ខ្ញុំ។ ខ្ញុំមើលឃើញថា ប្រជាជនកាលជំនាន់នោះ គឺរស់នៅយ៉ាងលំបាកវេទនាខ្លាំងណាស់។ ប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិត។ កុមារតូចៗត្រូវរស់នៅដោយខ្វះការអប់រំ និងភាពកក់ក្តៅពីឪពុកម្តាយ។ ខ្ញុំតូចចិត្តត្រង់ថា នៅពេលដែលរបបខ្មែរក្រហមដួលរលំទៅ ធនធានមនុស្សសង្គមរបស់ខ្លួនត្រូវធ្លាក់ដល់កម្រិតសូន្យ។»

**ណាត ធីរតនា** ភេទប្រុស អាយុ១៩ឆ្នាំ បានយល់ឃើញថា៖ «ខ្ញុំមើលឃើញពីស្ថានភាពដ៏លំបាកនៃភាពអត់ឃ្លានក្រោមរបបខ្មែរក្រហម។ ខ្ញុំធ្លាប់ឮជីដូនរបស់ខ្ញុំដំណាលថា គាត់ហូបបបរ។ ជំនាន់នោះមិនងាយបានបាយហូបទេ។ ខ្ញុំមិនចង់ឲ្យសង្គមរបស់ខ្លួនវិលត្រឡប់ទៅរកស្ថានភាពទាំងអស់នោះទៀតទេ។»

**ហាក់ ឈុនលី** ភេទប្រុស អាយុ១៨ឆ្នាំ បានយល់ឃើញថា៖ «ការរៀនសូត្រជាក្រុមបែបនេះ គឺផ្តល់គុណសម្បត្តិជាច្រើនសម្រាប់ការចងចាំជារួមលើផ្នែកប្រវត្តិសាស្ត្រ។ នៅក្នុងឱកាសនេះ យើងអាចពិភាក្សាគ្នា និងរៀនសូត្រពីគ្នាទៅវិញទៅមក ហើយវាក៏បង្ហាញពីសាមគ្គីភាពរបស់យើងដែរ។ ខ្ញុំចាប់អារម្មណ៍ទៅលើរូបថតមួយសន្លឹកដែលបង្ហាញពីគ្រោងឆ្អឹង និងលលាដ៍ក្បាលមនុស្សដែលបានតម្រៀបចេញជារូបផែនទីនៃប្រទេសកម្ពុជា។ ខ្ញុំនឹកស្រមៃថា ប្រទេសយើងមិនគួរធ្លាក់ទៅក្នុងភាពឃោរឃៅបែបនេះទេ។»



អ្នកនេសាទកំពុងបង់សំណាញ់នៅស្ពានអូរជីក ឬស្ពានតាម៉ុក ស្ថិតនៅទល់មុខការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ស្ទួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# តើឌុចនៅតែមានកំហុសដែរឬទេ?

អ៊ុន សុជាទី



*ឌុច នៅក្នុងសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

អតីតប្រធានមន្ទីរសន្តិសុខស-២១ ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬត្រូវបានហៅជាទូទៅថាសាលាក្តីខ្មែរក្រហមស្វែងរកឃើញថា មានកំហុស ក្រោមការចោទប្រកាន់ពីបទប្រព្រឹត្ត «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ»។ ឌុច ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែឧសភា ឆ្នាំ ១៩៩៩ ដោយអាជ្ញាធររដ្ឋាភិបាលកម្ពុជា និងត្រូវបានផ្ទេរមកឃុំខ្លួនក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

រហូតដល់នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសាលដីកាសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិត។ ឌុច ត្រូវ

បានឃុំឃាំងនៅក្នុងពន្ធនាគារខេត្តកណ្ដាលដើម្បីអនុវត្តទោសរហូតដល់ថ្ងៃ ឌុច ស្លាប់ ដោយបានជាប់ឃុំឃាំងអស់រយៈពេលជាង៧ឆ្នាំ។ នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ ឌុច បានស្លាប់នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតក្នុងអាយុ៧៨ឆ្នាំ ដោយសារជំងឺរលាកសួតធ្ងន់ធ្ងរ បន្ទាប់ពីគាត់មានជំងឺសួតរ៉ាំរ៉ៃពីមុនមក ដោយសារតែការជក់បារី និងជំងឺហឺត។

ឌុច មានតួនាទីជាអតីតប្រធានមន្ទីរសន្តិសុខស-២១ (ឬហៅជាទូទៅថាគុកទួលស្លែង) ក្នុងអំឡុងរបបកម្ពុជាកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ នៅក្នុងរបបខ្មែរក្រហម ជនរងគ្រោះជាង១ម៉ឺននាក់ត្រូវបានចាប់យកមកឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ហើយទទួលរងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ និងសម្លាប់។ ជនរងគ្រោះទាំងអស់ត្រូវបានខ្មែរក្រហមចោទថា ខ្មាំងប្រឆាំងនឹងអង្គការ។

ឪពុករបស់ ស៊្រុន សុទិដ្ឋ ឈ្មោះ ស៊្រុន សេងហ៊ត ត្រូវបានក្រុមខ្មែរក្រហមចាប់ខ្លួនមកពីខេត្តបាត់ដំបង និងបញ្ជូនមកឃុំឃាំងនៅក្នុងគុកទួលស្លែង។ កន្លងផុតអស់រយៈពេលជាង៤០ឆ្នាំ ទើបសុទិដ្ឋនិងក្រុមគ្រួសារ បានស្វែងរកឃើញថា ឪពុករបស់គាត់ត្រូវបានចាប់ខ្លួន និងជាប់ឃុំឃាំងនៅក្នុងគុកទួលស្លែង។ សុទិដ្ឋ បានរៀបរាប់ថា គាត់ធ្លាប់បានឮអំពីរឿងរ៉ាវរបស់ ឌុច និងដំណើរការនៃការកាត់ទោស ឌុច នៅសាលាក្ដីខ្មែរក្រហមតាមរយៈបណ្ដាញព័ត៌មានផ្សេងៗ។ សុទិដ្ឋ បានបន្ថែមទៀតថា ការដាក់គុក ឌុច អស់មួយជីវិត គឺជាផ្នែកមួយនៃការផ្ដល់យុត្តិធម៌ចំពោះការបាត់បង់ឪពុករបស់គាត់។ សុទិដ្ឋ យល់ឃើញថា វាពិតជាប្រសើរណាស់ នៅពេលដែលតុលាការខ្មែរក្រហមបានកាត់ក្ដី ឌុច និងអនុវត្តទោសរបស់ ឌុច បានមុនពេលដែល ឌុច ស្លាប់យ៉ាងដូច្នេះ ដែលផ្ទុយពីមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតដូចជា អៀង ធីរិទ្ធ និង អៀង សារី មិនបានទទួលទោសអ្វីទាល់តែសោះ។ សុទិដ្ឋ គ្មានកំហឹង និងគំនុំគំគួនអ្វីទៀតទេ ព្រោះរឿងរ៉ាវទាំងអស់បានកន្លងហួសយូរណាស់មកហើយ។ សុទិដ្ឋ អស់ចិត្ត ព្រោះ ឌុច បានអនុវត្តទោសទៅតាមច្បាប់ ហើយម្យ៉ាងទៀត សុទិដ្ឋ គិតថាទោះបីជា ឌុច ស្លាប់ឬនៅទីណា កំហុសរបស់ ឌុច នៅតែមានជាដរាប ព្រោះសាលាក្ដីខ្មែរក្រហមបានធ្វើការសម្រេចទោសរបស់គាត់រួចទៅហើយ។ សាលក្រមបានបញ្ជាក់ថា ឌុច ពិតជាបានប្រព្រឹត្តកំហុសទៅលើប្រជាជនខ្មែរនៅក្នុងរបបខ្មែរក្រហមពិតមែន។

ការប្រព្រឹត្តអំពើដ៏កាចសាហាវរបស់ ឌុច បានធ្វើឲ្យប្រជាជនចំនួន១៧៥០នាក់ បានដាក់ពាក្យបណ្ដឹងមកកាន់សាលាក្ដីខ្មែរក្រហមតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា។ គោលបំណងនៃការដាក់ពាក្យបណ្ដឹងមកកាន់សាលាក្ដីខ្មែរក្រហមរបស់ជនរងគ្រោះ គឺដើម្បីស្វែងរកយុត្តិធម៌ដល់សាច់ញាតិដែលបានស្លាប់ និងការឈឺចាប់ដែលខ្លួនបានទទួលរង។ ដោយសារតែមានការគាំទ្រទាំងប្រជាជន និងរាជរដ្ឋាភិបាលកម្ពុជា សាលាក្ដីខ្មែរក្រហម បានអនុវត្តកិច្ចការងាររបស់ខ្លួនរហូតឈានទៅចាប់ខ្លួនមេដឹកនាំខ្មែរក្រហមថ្នាក់លើជាច្រើននាក់មកកាត់ទោស។

ស៊ុំ ឡូន ភេទស្រី អាយុ៦៣ ឆ្នាំ រស់នៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ឡូន ធ្លាប់បានដាក់ពាក្យបណ្ដឹងមកកាន់សាលាក្ដីខ្មែរក្រហម តាមរយៈ មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ២០០៨។ ឡូនបានប្រាប់ថា ការដាក់ពាក្យបណ្ដឹងមកសាលាខ្មែរក្រហម ព្រោះគាត់មានការសោកស្ដាយឪពុក ដែលបានស្លាប់ដោយសារតែអត់អាហារ និងបងប្រុសដែលចូលបម្រើកងទ័ពខ្មែរក្រហមបានបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ។ ឡូន បញ្ជាក់ថា គាត់បានស្គាល់ ឌុច អតីតមេគុកទួលស្លែងតាមរយៈការចាក់ផ្សាយអំពីការកាត់ទោសគាត់នៅតាមប៉ុស្តិ៍ទូរទស្សន៍។ ឡូន ពិតជាមានការភ្ញាក់ផ្អើលណាស់ នៅពេលដែលទទួលដំណឹងថា ឌុច ស្លាប់។ សម្រាប់ ឡូន គាត់នៅតែទទួលបានយុត្តិធម៌ដដែល ទោះបីជា ឌុច ស្លាប់ក៏ដោយ ព្រោះការស្លាប់របស់ ឌុច មិនបាននាំយកកំហុសរបស់គាត់ដែលបានប្រព្រឹត្តទៅជាមួយនោះទេ។ ឡូន ក៏បាននិយាយថា «នៅក្នុងជាតិនេះ ឌុច បានទទួលទោសដែលគាត់

បានប្រព្រឹត្តហើយ ប៉ុន្តែ បើគិតទៅតាមកម្មផលវិញ ខ្ញុំគិតថា គាត់នៅតែមានកំហុស ហើយយមរាជនឹងកាត់ទោសគាត់ម្តងទៀតនៅទីឋានដែលគាត់កំពុងតែទៅ»។ ឡុន អស់ចិត្តនិងរំសាយកំហឹងចំពោះ ឌុច ព្រោះគាត់គិតថា នេះជាទង្វើមួយដែលអាចជួយឲ្យក្មេងៗជំនាន់ក្រោយលះបង់នូវគំនិតគុំគួនៗ ម្យ៉ាងវិញទៀត នេះគឺជាមេរៀនមួយនៃដំណើរជីវិតមនុស្សដែលសាងល្អ និងអាក្រក់ និងលទ្ធផលដែលទទួលបាន។

បន្ទាប់ពី ឌុច បានស្លាប់នៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀតនៅម៉ោង ០០៖៥១ រំលងអាធ្រាតឈានចូលថ្ងៃទី០២ ខែកញ្ញា សាកសពរបស់ ឌុច ត្រូវបានសាច់ញាតិដឹកចេញទៅកាន់វត្តចាក់អង្រែក្រោម ស្ថិតនៅទីក្រុងភ្នំពេញនៅពេលព្រឹក។ សាកសពរបស់ ឌុច ត្រូវបានបូជាភ្លាមៗ បន្ទាប់ពីបានបញ្ជូនទៅដល់វត្ត និងមិនមានការធ្វើបុណ្យតាមសាសនាព្រះពុទ្ធអ្វីឡើយ។ មិនមានហេតុផលណាមួយបញ្ជាក់ពីសាច់ញាតិរបស់ ឌុច ដែលសម្រេចចិត្តមិនធ្វើបុណ្យនោះទេ។ យោងទៅតាមរបាយការណ៍នៃការបញ្ចាំងសាលក្រម ឌុច នៅប៉ៃលិន និងសំឡូត របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសរសេរថា ឌុច បានគេចខ្លួនទៅរស់នៅតំបន់សំឡូតនៅក្នុងឆ្នាំ១៩៩៥ ហើយធ្វើការងារនៅក្នុងជំរំតាមព្រំដែនប្រទេសថៃជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ ក្រោយមក ឌុច បានទៅរស់នៅកសាងជីវិតថ្មីនៅក្នុងស្រុកសំឡូតនៅឆ្នាំ១៩៩៨។ រស់នៅក្នុងតំបន់សំឡូត ឌុច បានផ្លាស់ប្តូរទៅកាន់សាសនាគ្រិស្ត និងប្រតិបត្តិនៅក្នុងវិហារសាសនាគ្រិស្តមួយ។ ឌុច បានចូលកាន់សាសនាគ្រិស្តតាមរយៈជនជាតិអាមេរិកកាំងម្នាក់ឈ្មោះ គ្រីស្តូហ្វ័រ ឡាប៉ែល ដែលពេលនោះ ឌុច បានក្លែងឈ្មោះទៅជា ហង់ពិន។ ឌុច បានជឿទៅលើព្រះយេស៊ូ ហើយទទួលពិធីជ្រមុជទឹក និងក្រោយមកបានក្លាយទៅជាគ្រូគង្វាលជំនួយ។

លោក ទេព គី អាយុ ៦៥ឆ្នាំ សព្វថ្ងៃរស់នៅក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ។ គី គឺជាពុទ្ធសាសនិកបានថ្លែងថា «ខ្ញុំមិនដឹងថា ឌុច កាន់សាសនាយេស៊ូនោះទេ ប៉ុន្តែបើតាមជំនឿរបស់ព្រះពុទ្ធសាសនាវិញ អ្នកសាងអំពើបាប និងទទួលបានបាប ចំណែកអ្នកសាងល្អនឹងទទួលកុសលផលបុណ្យល្អ។ ឌុច គឺជាមនុស្សម្នាក់ដែលខ្ញុំធ្លាប់បានឃើញនៅក្នុងដំណើរការនៃការកាត់ទោសរបស់សាលាក្តីខ្មែរក្រហម។ គាត់ត្រូវបានសាលាក្តីខ្មែរក្រហមកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដោយសារតែគាត់មានទោសកំហុសពីការធ្វើបាបប្រជាជន។ ដូច្នេះហើយ ឌុច កំពុងតែទទួលកម្មពៀរដែលគាត់បានសាងពីអតីតកាល»។ គី បានបន្ថែមថា ទោះបីជា ឌុច កាន់សាសនាអ្វីក៏ដោយ ប៉ុន្តែ ឌុច មិនអាចកែប្រែ និងគេចផុតពីទណ្ឌកម្មរបស់ព្រះឡើយ។

គី គ្មានការសោកស្តាយអ្វីទេចំពោះការស្លាប់របស់ ឌុច។ គាត់ យល់ឃើញថា ការកាត់ទោស ឌុច គឺនៅធូរស្រាលណាស់ បើប្រៀបធៀបទៅនឹងទំហំនៃការបាត់បង់របស់ប្រជាជនកម្ពុជា។ គី និយាយ ថាទម្រាំគាត់ជាប្រជាជននៅក្រៅឃុំបានជួបប្រទះនឹងភាពលំបាកលំបិនយ៉ាងខ្លាំងដូច្នេះ ចុះតើប្រជាជនដែលជាប់ឃុំនៅក្នុងគុកទួលស្លែងដែលទទួលរងការធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃនោះ តើប្រជាជនទាំងនោះលំបាកយ៉ាងណាទៅ។ គី មិនទាន់អស់ចិត្តទេ ប៉ុន្តែទោះបីជាយ៉ាងណាគាត់គោរពទៅតាមច្បាប់ថែម។ គី ចាត់ទុកថាកំហុសរបស់ ឌុច និងការកាត់ក្តីរបស់តុលាការខ្មែរក្រហមចំពោះ ឌុច គឺជាមេរៀនមួយដល់ថ្នាក់ដឹកនាំជំនាន់ក្រោយជៀសវាងប្រព្រឹត្តអំពើដូច ឌុច ទៀត។

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ទេព គីមទ្រី៖ គិលានុបដ្ឋាយិកា

***ប្រពន្ធរបស់គាត់ ទេព ស៊ុយអៀង បាននិយាយរៀបរាប់ប្រាប់ថា៖***

*ខ្ញុំបានស្រឡាញ់ការរៀនសូត្រនៅពេលដែលខ្ញុំនៅវ័យក្មេង ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំចង់ឲ្យខ្ញុំរៀបការ។ ទោះជាខ្ញុំបានពរពោះ ខ្ញុំនៅតែបន្តរៀនសូត្រទាល់តែពោះខ្ញុំរីកធំ។ បន្ទាប់មកឪពុកម្តាយរបស់ខ្ញុំបានឲ្យខ្ញុំធ្វើជាអ្នកគ្រប់គ្រងអាជីវកម្មមួយដែលមានសុីក្លូឲ្យអ្នកជួល។ ប្តីរបស់ខ្ញុំឈ្មោះ ទេព គីមទ្រី ជាគិលានុបដ្ឋាយិកានៅមន្ទីរពេទ្យមួយនៅក្នុងទីក្រុងភ្នំពេញ។ យើងមិនដែលបានជួបគ្នារហូតដល់ថ្ងៃយើងភ្ជាប់ពាក្យ។ ខ្ញុំមិនបានសប្បាយចិត្តឡើយ ហើយបានព្យាយាមជៀសវាងជួបគាត់ ដែលបានធ្វើឲ្យ ទ្រី សង្ស័យថាខ្ញុំមានមិត្តប្រុស។ នៅពេលនោះខ្ញុំមិនទាន់បានដឹងអំពីអត្ថន័យនៃស្នេហា។ យើងបានរៀបការនៅឆ្នាំ១៩៧៣។ ពិធីជប់លៀងមង្គលការបានបញ្ចប់នៅម៉ោង ៨យប់។ នៅពេលដល់វេលាចូលគេង ទ្រី និងខ្ញុំបានសន្ទនាជាមួយគ្នាយ៉ាងយូរ។ នេះជាពេលដែលយើងត្រូវស្គាល់គ្នាយ៉ាងម៉េច។ នៅមុនថ្ងៃពិធីមង្គលការ ខ្ញុំបានហៅគាត់ថា "លោកគ្រូពេទ្យ" ប៉ុន្តែឆាប់ៗមក យើងបានចាប់ផ្តើមហៅគ្នាយ៉ាងផ្អែមល្ហែម "បងសម្លាញ់ អូនសម្លាញ់"។ មួយឆ្នាំក្រោយមក ខ្ញុំបង្កើតបានកូនប្រុសមួយដែលមានស្បែកស្អាតហើយដូចទៅនឹងឪពុករបស់*



*ទេព គីមទ្រី និង ទេព ស៊ុយអៀង មួយខែបន្ទាប់ពីពិធីមង្គលការរបស់គេ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*គេ។ វាបានស្លាប់ដោយសារជំងឺគ្រុនក្តៅ... *

*គេ។ វាបានស្លាប់ដោយសារជំងឺកញ្ជ្រឹល នៅពេលដែលវាមានអាយុបីខែ។ ទ្រី និងខ្ញុំបានគាំងបេះដូង វាជាពិភពរបស់យើង។*

*ឪពុករបស់ខ្ញុំឈ្មោះ ស៊ាម ស៊ុក (ខ្ញុំហៅគាត់ថាប៉េ)។ គាត់ស្រឡាញ់ខ្ញុំខ្លាំងណាស់ ប៉ុន្តែគាត់ក៏ស្រឡាញ់ប្រាក់ដែរ។ នៅពេលដែលយើងបានកំពុងជម្លៀសចេញពីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ គាត់មិនបានចេញទៅជាមួយគ្រួសាររបស់គាត់ទេ ប៉ុន្តែបានស្នាក់នៅក្រោយគេ មើលថែរក្សាប្រាក់របស់គាត់។ គាត់ក៏បានជឿខ្មែរក្រហម នៅពេលគេនិយាយថា អ្នករាល់គ្នាអាចត្រឡប់ចូលក្រុងវិញក្នុងពេលបីថ្ងៃ ដូច្នេះ គាត់បានពួននៅក្នុងផ្ទះទាល់តែយោធាខ្មែរក្រហមបង្ខំគាត់ឲ្យចេញ។ គាត់បានចាប់ផ្តើមរកយើងជាច្រើនថ្ងៃ*



ទេព គីមទ្រី និង ទេព ស៊ុយអៀង នៅថ្ងៃពិធីមង្គលការ ឆ្នាំ១៩៧៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីអ្នកទាំងអស់គ្នានៃគ្រួសារយើងបានចាកចេញពីទីក្រុង។ សាច់ញាតិរបស់យើងខ្លះបានយកថង់ប្រាក់ជាច្រើនមកតាមពួកគេ នៅពេលដែលគេបានចាកចេញពីភ្នំពេញ ប៉ុន្តែឪពុកខ្ញុំយកបានស៊ីក្លូមួយគ្រឿង។ មានរបស់របរជាច្រើនបានដាក់ចូលក្នុងស៊ីក្លូ ហើយបានដោះដូររបស់ទាំងនោះយកអង្ករ ដូច្នេះយើងមានអង្ករគ្រប់គ្រាន់សម្រាប់រយៈពេលខ្លី។

ប៉ោ មានជំងឺមួយយូរមកហើយដែលធ្វើឲ្យជើងគាត់ហើម ដូច្នេះគាត់មិនអាចដើរបានឆ្ងាយ។ បន្ទាប់ពីគាត់បានជួបជុំគ្រួសារយើង ជើងរបស់គាត់បានវិវឌ្ឍន៍ទៅជាដំបៅក្លាយ និងឈឺចាប់ជាខ្លាំង។ គាត់បានសុំខ្ញុំឲ្យកាត់វាចោល។ នៅលើកដំបូង ខ្ញុំបានរួញរាព្រោះអីខ្ញុំខ្លាចវានឹងនាំមកនូវសំណាងអាក្រក់។ ម្តាយរបស់ខ្ញុំឈ្មោះ វីល កាក់គីម ក៏បានបដិសេធដែរនូវការសុំរបស់គាត់ហើយបានប្រាប់គាត់ថា សំណាងរបស់ខ្ញុំនឹងអាក្រក់ប្រសិនជាគាត់ឲ្យខ្ញុំធ្វើរឿងនេះ។ ប៉ុន្តែ ប៉ោ បានអង្វរខ្ញុំឲ្យកាត់ជើងគាត់ គាត់និយាយថាវានឹងធ្វើឲ្យខ្ញុំទៅជាកូនស្រីរឹងមាំម្នាក់ ហើយខ្ញុំនឹងអាចធ្វើអ្វីបានទាំងអស់នៅអនាគត។ ខ្ញុំបានសម្រេចចិត្តជាចុងក្រោយ កាត់កជើងឪពុកខ្ញុំនៅកណ្តាលវាល។ ខ្ញុំបានពរពោះនៅពេលនោះ ហើយកូនរបស់ខ្ញុំបានកើតមកឃើត។

ឪពុករបស់ខ្ញុំបានស្លាប់នៅឆ្នាំ១៩៧៦ ដោយសារកង្វះខាតស្បៀងអាហារ។ ខ្ញុំបានកំពុងរស់នៅក្នុងភូមិមួយផ្សេងទៀត ហើយបានមកមើលគាត់នៅមុនពេលគាត់ស្លាប់។ យើងមិនមានបន្ទះក្តារគ្រប់គ្រាន់ធ្វើក្តារមឈូសសម្រាប់គាត់ទេ ហើយមិនអនុញ្ញាតឲ្យពូនដីនៅលើផ្នូររបស់គាត់ ព្រោះអីអង្គការត្រូវការដីសម្រាប់ដាំស្រូវ។ ប៉ុន្តែអង្គការបានអនុញ្ញាតឲ្យយើងកាប់ឫស្សី ក្រងត្បាញនិងរុំសាកសព ដែលយើងដាក់នៅក្នុងវាលស្រែ។

វានឹងកើតឡើង ខ្ញុំបានពរពោះម្តងទៀត។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅវាលស្រែ។ នៅពេលនោះហ្វូងកណ្តុរបានបំផ្លាញស្រូវអស់មួយភាគធំ ដូច្នេះខ្ញុំត្រូវបានប្រាប់ឲ្យចាប់ពួកវា។ ប្រធានកងរបស់ខ្ញុំបានខឹងខ្ញុំជាខ្លាំង ព្រោះអីខ្ញុំខ្លាចកណ្តុរនិងមិនអាចចាប់បានមួយឡើយ។ ប្តីខ្ញុំបានដឹងរឿងនេះ ដូច្នេះគាត់ដាក់អន្ទាក់បានកណ្តុរខ្លះ ហើយលាក់កណ្តុរនោះទុកនៅវាលស្រែ។ បន្ទាប់មកគាត់បានឲ្យសញ្ញាសម្គាល់ដល់ខ្ញុំ អញ្ចឹងខ្ញុំអាចរកកណ្តុរទាំងនោះឃើញ។ ខ្ញុំបានដើរជុំវិញជាមួយកណ្តុរ ហើយអ្នករាល់គ្នាគិតថាខ្ញុំចាប់បានកណ្តុរទាំងនោះ។ ខ្ញុំក៏ខ្លាចខ្មោចលងដែរ ប៉ុន្តែដោយសារយើងស្រេកឃ្លាន ខ្ញុំបានដើរទៅបឹងម្នាក់ឯងនៅពេលយប់ ទៅរាវខ្ចងចាប់ក្តាម និងដកព្រលឹត។

កូនទីបីរបស់ខ្ញុំ ឈ្មោះ ភីរម្យ បានកើតនៅពេលប្រទេសមិនមានថ្នាំពេទ្យគ្រប់គ្រាន់ ឬគិលានុបដ្ឋាយិកា ហើយវាបានឈឺជារឿយៗ។ ទោះជាវាមានអាយុដល់បីឆ្នាំ ភីរម្យនៅតែមិនអាចដើរបាន។

នៅពេលមួយ ខ្ញុំបានពុលដោយសារដំឡូងខ្ញុំហូបនៅពេលអាហារថ្ងៃត្រង់។ ខ្ញុំបានសុំមិត្តខ្ញុំម្នាក់កោសខ្យល់ឲ្យខ្ញុំ [ការព្យាបាលមួយនៅអាស៊ី ជាទីដែលគេប្រើកាក់ ត្រដោស កោស ជិតជាមនៅលើទ្រូងនិងខ្នង] ប៉ុន្តែវាមិនបានជួយខ្ញុំបានច្រើនឡើយ។ បន្ទាប់មកមិត្តខ្ញុំបានយកខ្ញុំទៅមន្ទីរពេទ្យជាទីដែលកម្មាភិបាល រិន ឲ្យខ្ញុំផឹកអ៊ីម៉្យាង។ បន្ទាប់ពីចូលក្នុងមាត់ភ្លាម ខ្ញុំស្រែកថា វាជាប្រេងកាត។ កម្មាភិបាល រិន បានស្រែកតបវិញថា វាជាថ្នាំពេទ្យ ប៉ុន្តែបន្ទាប់មក វាជាក្លិនប្រេងកាតហើយបានឆែកដបនោះមើល។ ជាចុងក្រោយនាងបានដឹងថាខ្ញុំមិនបាននិយាយកុហក ហើយនិយាយថាមាន

អ្នកណាម្នាក់បានដាក់ដបប្រេងកាតនៅជិតដៃនាង។

នៅអំឡុងចូលឆ្នាំខ្មែរនៅឆ្នាំ១៩៧៧ អង្គការបានឲ្យអ្នកភូមិទាំងអស់ឈប់សម្រាកបីថ្ងៃ ពីការងារនៅវាលស្រែ។ បងប្រុសរបស់ខ្ញុំឈ្មោះ កៀង គាត់ធ្លាប់ធ្វើជាគ្រូបង្រៀននៅក្រុងភ្នំពេញ គាត់បានត្រឡប់មកផ្ទះជាមួយប្តីខ្ញុំ ហើយបានលេងបាល់ទាត់។ កៀងបានលេងឈ្នះ ដែលធ្វើឲ្យគណៈភូមិចង់ដឹងច្រើនអំពីប្រវត្តិរូបរបស់គាត់។ វានឹងកើតឡើង អង្គការបានបញ្ជូនកៀង និងអតីតគ្រូបង្រៀនពីរនាក់ផ្សេងទៀតឲ្យទៅជញ្ជូនខ្សាច់នៅក្នុងភូមិមួយទៀត។ ការបាត់ខ្លួនបងប្រុស ខ្ញុំបានធ្វើឲ្យម្តាយខ្ញុំតវ៉ាំងបេះដូង។ ការបាត់ខ្លួនប្រជាជនមានបន្តបន្ទាប់ បានធ្វើឲ្យខ្ញុំបារម្ភអំពីប្តីរបស់ខ្ញុំ។ អ្នករាល់គ្នានៅក្នុងភូមិបានដឹងថាគាត់ធ្លាប់ធ្វើជាជាតិលានុបដ្ឋាយិកា។

យប់មួយនោះ នៅអំឡុងរដូវស្ទូង ប្តីខ្ញុំមិនបានមកផ្ទះ ទោះជាស្ទើរតែគ្រប់គ្នាបានមកវិញ។ នៅពេលដែលខ្ញុំមកដល់ខ្ទមរបស់យើង ម្តាយខ្ញុំបានយំនិយាយថា ប្តីខ្ញុំត្រូវបានចាប់ខ្លួន។ ខ្ញុំបានខ្យល់ចាប់នៅខណៈដែលខ្ញុំបានឮព័ត៌មាននោះ។ នៅពេលដែលខ្ញុំចូលទៅម្តាយខ្ញុំបាននិយាយថាកម្មាភិបាលម្នាក់ឈ្មោះ ផុន បានចងដៃទ្រីក្រពាត់ទៅក្រោយខ្នង ហើយនាំគាត់ចេញទៅតាមទូក។ បន្ទាប់មក ផុន បានមកផ្ទះយើង ដើម្បីរកនាឡិកាដៃរបស់ទ្រី។ ខ្ញុំបានកុហកហើយនិយាយថា ខ្ញុំមិនអាចរកឃើញនាឡិកានោះទេ។

បន្ទាប់ពីបាត់បង់ប្តីខ្ញុំ ខ្ញុំបានបាត់បង់ភាពក្លាហានរបស់ខ្ញុំ។ ម្តាយខ្ញុំបានខឹងនឹងខ្ញុំហើយរំឭកខ្ញុំ នូវពាក្យពេជន៍របស់ទ្រី: ខ្ញុំត្រូវតែតស៊ូនិងព្យាយាម ប្រសិនបើគាត់មិនបាននៅជាមួយខ្ញុំ។ ពាក្យទាំងនោះបានដាស់តឿនខ្ញុំឲ្យក្រោកឡើងចាប់ផ្តើមហូបនិងធ្វើការដូចធម្មតា។ បន្ទាប់មកខ្ញុំបានកោរសក់ក្បាល ដែលខ្ញុំអាចបន់ស្រន់ខទិសដល់គាត់។

នៅដើមឆ្នាំ១៩៧៨ ម្តាយខ្ញុំបានធ្លាក់ខ្លួនឈឺជាខ្លាំង ដូច្នេះខ្ញុំបានសុំការអនុញ្ញាតពីអង្គការទៅធ្វើការនៅជិតផ្ទះដើម្បីមើលថែទាំគាត់។ ម្តាយខ្ញុំមានជំងឺចម្លែក ដែលពោះរបស់គាត់បានហើមធំ ដូចស្ត្រីមានទម្ងន់។ គាត់តែងតែមានអារម្មណ៍ឃ្លានជាខ្លាំង។ មួយខែក្រោយមក គាត់បានស្លាប់គួរឲ្យរន្ធត់។

សម្លេងកាំភ្លើងបានឮនៅក្នុងភូមិរបស់យើងនៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចូលមកចូលមកជិតយ៉ាងលឿន។ ក្មេងដែលកំពុងធ្វើការនៅទីឆ្ងាយពីឪពុកម្តាយត្រូវបានបញ្ជូនត្រឡប់មកភូមិវិញ។ មន្ទីរពេទ្យបានបិទទ្វារ។ បន្ទាប់មកគណៈភូមិ និងប្រធានកងបានរត់ចេញ ដូច្នេះយុវជន យុវនារីបានត្រឡប់មកវិញ។ ប្រជាជនបានព្យាយាមដណ្តើមយកស្បៀងដែលអាចយកបានពីរោងកិនស្រូវ និងឃ្លាំងជាច្រើន។

បងស្រីបង្អស់របស់ខ្ញុំឈ្មោះ ឆន បានត្រឡប់មកផ្ទះវិញនៅឆ្នាំ១៩៧៩ ខ្ញុំមិនមានព័ត៌មានអ្វីអំពីគាត់ពីរ បីឆ្នាំមកហើយ។ ខ្ញុំស្ទើរតែមិនស្គាល់គាត់នៅពេលដែលយើងបានជួបគ្នា គាត់ស្គមណាស់។ គាត់បានរស់រានមានជីវិតដោយសារប្តូរឈ្មោះរបស់គាត់ និងធ្វើការនៅក្នុងកងចល័ត ជាទីដែលមិនមានអ្នកណាម្នាក់ស្គាល់គាត់។

សព្វថ្ងៃនេះខ្ញុំរស់នៅប្រទេសបារាំង ប៉ុន្តែបេះដូងរបស់ខ្ញុំដក់ជាប់នៅឡើយជាមួយប្តីរបស់ខ្ញុំនៅប្រទេសកម្ពុជា។ នៅពេលណា ដែលខ្ញុំញាំត្រយស្ពៅ លុះងខ្ញុំគិតអំពីគាត់។ គេបានរំឭកខ្ញុំនៅពេលដែលខ្ញុំពរពោះហើយចង់ញាំត្រយស្ពៅ។ ប្តីខ្ញុំបានឡើងដើមស្ពៅដើម្បីបេះត្រយស្ពៅ ពិតណាស់ខ្ញុំនឹងបានអ្វីដែលខ្ញុំចង់ញុាំ។

*រឿងនេះយោងតាមសំណេរជ័យលាភាមួយមានចំណងជើងថា "មិនអាចបំភ្លេចបាន" ដែល ទេព ស៊ុយអៀង បានផ្ញើរមកចូលរួមក្នុងវេទិកាប្រឡងមួយ នៃការថែរក្សាប្រវត្តិខ្មែរក្រហមដែលឧបត្ថម្ភដោយសមាគមអ្នកនិពន្ធខ្មែរ និងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០០៦។*

**ប៉ាង ពីច័ន្ទ និង ទេនី ខកហ្គៀល**




ទេព ស៊ុយអៀង ខាងស្តាំ ជាមួយបងស្រីនិងក្មួយ។
ថតនៅមជ្ឈមណ្ឌលតាំងទីលំនៅ ឈុនបុរី ប្រទេសថៃ ឆ្នាំ១៩៨០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ទន់ ឈុំ ៖ វេជ្ជបណ្ឌិត

ខ្ញុំបានចេញពីគ្រួសារក្រីក្រមួយនៅក្នុងខេត្តតាកែវ និងបានរៀនសូត្រជាមួយបងប្រុសច្បងបង្អស់របស់ខ្ញុំជាលោកសង្ឃមួយអង្គ។ នៅក្នុងតំបន់ខ្ញុំមិនមានសាលារៀនច្រើនទេដូច្នេះខ្ញុំបានរៀននៅវត្ត។ នៅឆ្នាំ១៩៥៩ ខ្ញុំបានចាប់ផ្តើមរៀននៅសាលារៀនមួយ ប៉ុន្តែវានៅឆ្ងាយពីផ្ទះរបស់ខ្ញុំ ដូច្នេះខ្ញុំបានជួលកន្លែងស្នាក់នៅមួយនៅក្នុងក្រុង។ មួយដងក្នុងមួយអាទិត្យខ្ញុំបានទៅផ្ទះ ហើយបានយកអង្ករ និងស្បៀងអាហារផ្សេងៗត្រឡប់មកវិញ។

នៅឆ្នាំ១៩៦២ ខ្ញុំបានប្រឡងជាប់សញ្ញាបត្រទុតិយភូមិ ហើយមួយឆ្នាំក្រោយមកខ្ញុំបានដាក់ពាក្យប្រឡងចូលរៀនសាលាវេជ្ជសាស្ត្រ។ ដំបូង ខ្ញុំបានដាក់ពាក្យប្រឡងច្រើនមុខជំនាញដែរ ប៉ុន្តែខ្ញុំបានប្រឡងជាប់វេជ្ជសាស្ត្រ។ រៀនផ្នែកវេជ្ជសាស្ត្រគឺពិបាករកការងារធ្វើ។ បន្ទាប់ពីខ្ញុំរៀនចប់ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្រសួងសុខាភិបាលសាធារណៈ នៅខេត្តកំពត។

នៅឆ្នាំ១៩៦៥ ខ្ញុំបានរៀបការជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ ហេង សាវ៉ាង។ យើងបានចំណាយពេលពីរឆ្នាំនៅកំពតបន្ទាប់មក ខ្ញុំត្រូវបានផ្ទេរទៅមន្ទីរពេទ្យមួយនៅក្រុងភ្នំពេញ។ នៅទីនោះខ្ញុំបានអប់រំប្រជាជនអំពីបញ្ហាសុខភាព និងចែកចាយស្បៀងអាហារដល់ក្មេងៗដែលខ្វះជីវជាតិ ប្រូតេអ៊ីន។



ទន់ ឈុំ និងគ្រួសាររបស់គាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទោះបីយ៉ាងណា ខ្ញុំរកបានប្រាក់ចំណូលច្រើននៅទីក្រុង គឺច្រើនជាងពេលដែលខ្ញុំនៅជនបទ។ តម្លៃប្រាក់រៀលបានធ្លាក់ចុះជោកជាខ្លាំងនៅប្រទេសកម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧០ ហើយតម្លៃមាសបានឡើងថ្លៃទ្វេជាពីរ។ ដូច្នេះយើងមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ទិញទំនិញ។ យើងបានរស់នៅជាមួយម្តាយក្មេករបស់ខ្ញុំនៅខេត្តកណ្តាល ហើយខ្ញុំបានបើករថយន្តទៅធ្វើការរាល់ថ្ងៃ។ ខ្ញុំបានរកប្រាក់ចំណូលបន្ថែមដោយដើរពិនិត្យ និងព្យាបាលអ្នកជំងឺនៅតាមផ្ទះ។

នៅពេលដែលយោធាខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុង ខ្ញុំមិនបានយករថយន្តរបស់ខ្ញុំទៅទេ។

យើងប្រញិបប្រញាប់ពេក ហើយបានវេចខ្ចប់យកតែរបស់របរសំខាន់ ដូចជា ខោអាវ អង្ករ និងម្ហូបក្រៀមប៉ុណ្ណោះ។ ពេលយើងទៅដល់ខេត្តកំពង់ស្ពឺ ប្រជាជនមូលដ្ឋានបានយករទេះគោមកទទួលប្រជាជនទីក្រុង។ អង្គការបានឲ្យយើងឈរជាជួរ សួរយើងអំពីអតីតភាព ហើយបានដកហូតយករបស់របរប្រើប្រាស់ផ្ទាល់ខ្លួនទាំងអស់ដែលយកមកពីទីក្រុង ហើយឲ្យរបស់ទាំងនោះទៅសហករណ៍។ បន្ទាប់មកខ្មែរក្រហមបានឲ្យខោអាវខ្មៅមកយើងសម្រាប់ស្លៀកពាក់។

កម្មាភិបាលបានសួរខ្ញុំថា "អ្នកឯងអាចធ្វើអ៊ីបាន?"។ ខ្ញុំបានឆ្លើយថា "ខ្ញុំអាចធ្វើការផ្សារប្រើកម្លាំងបានទាំងអស់"។ ខ្ញុំអាចខាត់ឈើឲ្យរលោងសម្រាប់ធ្វើកីតម្បាញ ព្រោះអីខ្ញុំបានធ្វើកិច្ចការនេះជាមួយឪពុកម្តាយរបស់ខ្ញុំនៅស្រុកជនបទ។ លើកដំបូងអង្គការបានស្នើខ្ញុំឲ្យធ្វើត្បាល់កិនតូចៗ សម្រាប់កិនស្រូវ បន្ទាប់មកខ្មែរក្រហមបានបញ្ជូលខ្ញុំទៅក្នុងសហករណ៍មួយដែលធ្វើកីតម្បាញ។ ក្រោយមកខ្មែរក្រហមបានសង្ស័យលើរូបខ្ញុំ ហើយបានសួរខ្ញុំម្តងទៀតអំពីជីវប្រវត្តិរបស់ខ្ញុំ។ ខ្ញុំបានប្រាប់ខ្មែរក្រហមនោះថា ខ្ញុំគឺជាជាងឈើនៅមន្ទីរពេទ្យមួយ។ ដូច្នេះ បន្ទាប់មកខ្មែរក្រហមបានឲ្យខ្ញុំសង់របាត់ទឹកកីតម្បាញ និងត្បួរស្រែ។

កូនទីមួយរបស់ខ្ញុំបានស្លាប់ដោយសារកង្វះអាហារ និងថ្នាំពេទ្យព្យាបាលនៅចុងឆ្នាំ១៩៧៥។ ខ្ញុំដឹងត្រូវព្យាបាលជំងឺរបស់វាយ៉ាងម៉េច ប៉ុន្តែមិនមានថ្នាំពេទ្យគ្រប់គ្រាន់។ កូនខ្ញុំត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ប៉ុន្តែគិលានុបដ្ឋាយិកាខ្មែរក្រហមមិនបានព្យាបាលវាល្អឡើយ ហើយវាក៏ស្លាប់នៅទីនោះ។

យើងដាំបន្លែបានច្រើននៅជុំវិញផ្ទះរបស់យើង។ នៅពេលដែលខ្ញុំមិននៅផ្ទះ ប្រពន្ធខ្ញុំបានលួចបេះផ្លែល្ពៅរបស់យើងមួយផ្លែ ដើម្បីធ្វើសម្លសម្រាប់កូនៗរបស់យើង។ កម្មាភិបាលបានឃើញនាងហើយ បានយកនាងនិងកូនៗទៅមន្ទីរឃុំជាទីកន្លែងដែលឈ្លបចោទនាងថាបានលួចស្បៀងអាហាររបស់សហករណ៍។ ខ្ញុំក៏បានធ្វើឲ្យមានកំហុសមួយដែរ នៅពេលខ្ញុំបានលួចដំឡូងខ្លះហូប។ ខ្ញុំកំពុងស្ងោរដំឡូងនៅពេលដែលកងឈ្លបមកដល់។ ឈ្លបម្នាក់នោះបានទាត់ធាក់ខ្ញុំ ហើយចងដៃខ្ញុំទាំងពីរក្រពាត់ទៅក្រោយខ្នង។ ឈ្លបបានឃុំខ្ញុំនៅក្នុងមន្ទីរឃុំ ប៉ុន្តែបានដោះលែងខ្ញុំមួយថ្ងៃក្រោយមក នៅពេលដែលប្រជាជនម្នាក់ដែលជាអ្នកជិតខាងរបស់យើងបានអង្វរឈ្លបឲ្យលើកលែងទោសដល់ខ្ញុំ។ ប្រពន្ធខ្ញុំ និងកូនៗត្រូវបានដោះលែងដែរ។

នៅខែតុលា ឆ្នាំ១៩៧៥ អង្គការបានផ្លាស់ទីលំនៅប្រជាជនជាច្រើននៅក្នុងភូមិរបស់ខ្ញុំឲ្យទៅខេត្តពោធិ៍សាត់។ យើងជិះរថយន្តច្រើនគ្រឿង ដែលបើកយ៉ាងលឿននៅតាមផ្លូវ។ រាល់ពេលដែលអ្នកបើកបរម្នាក់ក្នុងចំណោមអ្នកបើកបរច្រើននាក់ ជាន់ហ្វ្រាំង ប្រជាជនបានធ្លាក់ចេញពីរថយន្ត ហើយបានស្លាប់។ ឪពុករបស់ខ្ញុំនិងប្អូនប្រុសឈ្មោះ ឆាន់ បានជម្លៀសទៅពោធិ៍សាត់ដែរ។ យើងបានជួបគ្នានៅទីនោះ ហើយបន្ទាប់មកយើងបានទៅខេត្តបាត់ដំបងជាមួយគ្នា។

នៅពេលដែលយើងទៅដល់ ត្រាក់ទ័រច្រើនគ្រឿងបានរង់ចាំយើង។ លក្ខខណ្ឌរស់នៅរបស់យើងបានប្រសើរនៅខេត្តបាត់ដំបង ព្រោះអីយើងអាចរកបន្លែផ្ទាល់ខ្លួនសម្រាប់ហូប ហើយអង្គការនៅទីនោះមិនតឹងរ៉ឹងឡើយ។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅកាប់ដើមឈើនៅក្នុងព្រៃស្រោង។ ក្មួយរបស់ខ្ញុំបានទៅជាមួយខ្ញុំដែរ។ ថ្ងៃមួយវាមិនបានទៅធ្វើការ ព្រោះអីវាមានជំងឺគ្រុនចាញ់។ អង្គការបានយកវាទៅសម្លាប់។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានបញ្ជាខ្ញុំឲ្យធ្វើការជាគ្រូផ្សំថ្នាំបុរាណ និងដុតសាកសពប្រជាជន។ ខ្ញុំបានទៅព្រៃជ្រៅដើម្បីរករុក្ខជាតិសម្រាប់យកទៅផ្សំធ្វើថ្នាំ ហើយបានឃើញសាកសពជាច្រើននៅទីនោះ។ ខ្ញុំបានដុតសាកសពបីដងក្នុងមួយថ្ងៃ ប៉ុន្តែពេលខ្លះខ្ញុំមិនអាចរកអុសដុតគ្រប់គ្រាន់ ហើយបានកប់សាកសពទាំងនោះជំនួសវិញ។

ថ្ងៃមួយ ខ្មែរក្រហមបានហៅខ្ញុំនិងប្អូនថ្លៃប្រុសរបស់ខ្ញុំទៅកប់សាកសពប្រជាជន២១នាក់។ ប៉ុន្តែប្រជាជនទាំងនោះមិនទាន់ត្រូវបានសម្លាប់នៅឡើយ។ ប្រជាជនទាំងនោះកំពុងតែកាប់រំលំដើមឈើនៅក្នុងព្រៃស្រោង។ នៅពេលដែលយើងទៅដល់ ខ្ញុំបានឮអ្នកទាំងនោះខ្សឹបខ្សៀវថា ឆាប់ៗនេះនឹងមានទាហានវៀតណាមជាច្រើនមករំដោះយើង។ ប្រជាជន២១នាក់នោះបានរកឃើញវិទ្យុមួយនៅក្នុងព្រៃ ហើយបានបើកស្តាប់វា។ មួយស្របក់ក្រោយមកយោធាបានកាត់ក្បាលប្រជាជនទាំងនោះ ហើយប្អូនខ្ញុំ និងខ្ញុំបានកប់សាកសពគេនៅក្នុងរណ្តៅសពរាក់មួយ។

**ប៊ាង ពីច័ន្ទ និង ខេនី ខករហ្គៀល**

### «ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ម៉ុង មួន ៖ គិលានុបដ្ឋាយិកា

**ម្តាយរបស់គាត់ ឌុច ខៀម បាននិយាយរៀបរាប់ប្រាប់ថា៖**

*នៅក្នុងចំណោមកូនៗ១០នាក់របស់ខ្ញុំ កូន៥នាក់ បានស្លាប់នៅក្នុងអំឡុងរបបខ្មែរក្រហម។ កូនប្រុសបងគេពីរនាក់ ឈ្មោះមួន និងមុត ត្រូវបានសម្លាប់។ កូនទីបីរបស់ខ្ញុំឈ្មោះ ទី បានអត់ឃ្លានទាល់តែស្លាប់ ដូចប្អូនរបស់វាឈ្មោះ ច្រឹប និងកូនប្រុសពៅគេឈ្មោះ អូន បានស្លាប់នៅពេលដែលវាអាយុបានមួយឆ្នាំ។ ខ្ញុំមិនបានដឹងថាតើទៅរកអាហារសម្រាប់កូនៗរបស់ខ្ញុំនៅពេលនោះ អ្វីដែលខ្ញុំអាចរកបានមានត្នោត និងទំពាំងឫស្សី។*

*ខ្ញុំបានធំឡើងនៅស្រុកដង្កោ ភ្នំពេញ។ គ្រួសារយើងក្រីក្រ ប៉ុន្តែប្តីរបស់ខ្ញុំក្រីក្រមែនទែន។ គាត់បានមកធ្វើការនៅផ្ទះរបស់យើង ជួយធ្វើស្រែ។ គ្រួសាររបស់ខ្ញុំបានសម្គាល់ថា គាត់បានខំប្រឹងប្រែងធ្វើការជាខ្លាំង ដូច្នេះខ្ញុំបានយល់ព្រមរៀបការ គេបានរៀបចំឲ្យយើង។*

*គាត់តែងតែបានក្រវាត់ក្រម៉ារបស់គាត់លើចង្កេះ មិនដែលបង់កក្រម៉ាទេ ដែលចាត់ថាវាមិនគួរសមឡើយសម្រាប់មនុស្សចាស់។ ដើម្បីរៀបការជាមួយខ្ញុំគ្រួសារ ខ្ញុំបានសុំខាងកូនកម្លោះសង់ផ្ទះឲ្យមួយសម្រាប់យើងជាចំណងដៃ។ វាថ្លៃ ៣០០០រៀល គ្រួសារ ទាំងសងខាងបានបែងចែកតម្លៃស្មើគ្នា។*



*ម៉ុង មួន (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ប្តីខ្ញុំជាជនកំព្រា ដូច្នេះអ្នកជិតខាងបានអាណិតអាសូរដល់គាត់ ហើយបានផ្តល់វត្ថុអនុស្សាវរីយ៍មង្គលការច្រើនទៅគាត់ ជាងខ្ញុំ។ យើងបានទទួលភ្ញៀវការរបស់យើងនៅលើកន្ទេល ព្រោះមិនអាចជួលតុ ប៉ុន្តែយើងមានភ្លេងប្រពៃណី និងចង្កៀងម៉ាំងសុង។ បន្ទាប់ពីរៀបការរួច ប្តីខ្ញុំគាត់បានធ្វើការជាជាងដែក និងធ្វើស្រែ។ ខ្ញុំនៅផ្ទះមើលថែទាំកូនៗ។*

*កូនរបស់យើងឈ្មោះ មួន វាសង្ហាមានសម្បុរស្រឯមស្អាត។ វាខ្ពស់ជាងឪពុករបស់វា។ នៅពេលណាខ្ញុំឲ្យលុយវាចាយ វាបានឲ្យលុយនោះទៅអ្នកក្រ។ ដំបូងឡើយវាជាក្មេងស្អាតប្រចាំភូមិ ប៉ុន្តែបន្ទាប់មកវាបានខំរៀនយ៉ាងខ្លាំង ហើយបានក្លាយជាគិលា-នុបដ្ឋាយិកា។*

*មួន បានរៀបការជាមួយកសិករម្នាក់ឈ្មោះ យិន សុខឿន។ ខ្ញុំជាម្តាយរបស់វា ខ្ញុំបានរៀបការឲ្យគេ។ បន្ទាប់ពីមង្គលការ គេបានរស់នៅទាំងខាងគ្រួសាររបស់យើង និងគ្រួសាររបស់នាង។ គេមានជីវភាពសមរម្យព្រោះអី មួន វាបានធ្វើការនៅមន្ទីរពេទ្យ។*

*នៅពេលដែលខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ គេចងទង់ជ័យក្រហមនៅលើកាំភ្លើងរបស់គេ ហើយបង់កក្រមា។ យើងទាំងអស់គ្នាបានភ័យខ្លាចអង្គការ ហើយដឹងថាយើងត្រូវតែចាកចេញដូចគេបានប្រាប់យើង។ មួន ប្រពន្ធរបស់វានិងគ្រួសាររបស់នាងបាននៅជាមួយយើង។ នៅពេលនោះគេមានកូនស្រីតូចមួយ ហើយប្រពន្ធរបស់មួនបានពរពោះ។*

*នៅតាមផ្លូវយោធាខ្មែរក្រហមបាននិយាយថា គេយកយើងទៅជួបអង្គការ។ យើងបានបន្តសួរ គេ អង្គការនៅឯណា? គេនិយាយថា យើងនឹងជួបអង្គការនៅថ្ងៃមួយយើងទៅដល់ទិសដៅរបស់យើង។ ទោះបីយ៉ាងណាយើងបានធ្វើដំណើរយ៉ាងឆ្ងាយយើងនៅតែមិនអាចរកអង្គការឃើញ។*

*នៅពេលដែលយើងទៅដល់វត្តប្រធាតុយើងបានសង់ខ្ទមមួយសម្រាប់*

រស់នៅ។ បន្ទាប់មកកម្មាភិបាលបានប្រកាសរកជាងដែកម្នាក់ ដូច្នេះប្តីខ្ញុំត្រូវបានជ្រើសយក។ បន្ទាប់ពីនេះបន្តិច ខ្ញុំបានឆ្លងទន្លេ។ នៅទីនោះមានតែប្រជាជន ជាអ្នកជិតខាងដែលគាត់ជាអ្នកជម្លៀសមកជាមួយយើងបានជួយខ្ញុំ។ មួយឆ្នាំក្រោយមក កូនប្រុសតូចរបស់ខ្ញុំបានស្លាប់ដោយអត់ឃ្លាន ព្រោះអីខ្ញុំមិនមានទឹកដោះគ្រប់គ្រាន់សម្រាប់បំបៅវា។

ខ្ញុំបាននឹករឭកកូនៗខ្ញុំផ្សេងទៀតដែលកំពុងធ្វើការនៅក្នុងកងចល័ត ដូចនេះខ្ញុំបានទៅលេងគេ។ ប៉ុន្តែនៅពេលដែលកូនខ្ញុំបានឃើញខ្ញុំ គេបានយំនិងដើរចេញ។ ខ្ញុំមិនបានយល់ឡើយ។ ក្រោយមក ប្រធានកងរបស់គេបានបញ្ជូនខ្ញុំទៅរៀនសូត្រសារឡើងវិញ។ កម្មាភិបាលបាននិយាយថា "ហេ្ន យាយ" "អ្នកដឹងទេថា អង្គការមានប្រជុំជាច្រើនសម្រាប់ម៉ែៗ ដែលចង់ឃើញកូនៗ ហើយត្អូញត្អែរ អំពីរឿងនេះ?"

នៅចុងឆ្នាំ១៩៧៥ កម្មាភិបាលបានសួរអំពីអតីតភាពគ្រួសាររបស់យើង។ ខ្ញុំជាអ្នកទៀងត្រង់ និងបានប្រាប់គេថា ប្តីខ្ញុំជាជាងដែក ហើយកូនប្រុសខ្ញុំជាគិលានុបដ្ឋាយិកានៅមន្ទីរពេទ្យទីក្រុងភ្នំពេញ។ ពីរអាទិត្យបន្ទាប់មក អង្គការបានបញ្ជូន មួន ឲ្យទៅកាប់ដើមឫស្សី។ វាបានជិះរទេះគោចេញទៅ ហើយបានបាត់ខ្លួន។ ប្រពន្ធរបស់វាបានរង់ចាំ ប៉ុន្តែវាមិនបានត្រឡប់មកផ្ទះវិញឡើយ។ បន្ទាប់មកកូនរបស់នាងបានឈឺហើយបានស្លាប់នៅមន្ទីរពេទ្យដោយសារអត់ឃ្លាន។

អង្គការបានមកបន្តសួរនាំខ្ញុំ ប្រសិនបើខ្ញុំនឹកកូនខ្ញុំ។ ខ្ញុំបានប្រាប់គេថា ខ្ញុំមិនបាននឹករឭកវាទេ ព្រោះអង្គការនឹងផ្គត់ផ្គង់កូនខ្ញុំបានល្អ នៅទីណាក៏ដោយដែលវាបានរស់នៅ។ ប្រសិនបើខ្ញុំបាននិយាយថាខ្ញុំនឹកវា ខ្ញុំនឹងត្រូវបានសម្លាប់។

ខ្ញុំនៅតែនឹករឭក មួន ហើយអារម្មណ៍របស់ខ្ញុំវាមិននឹងនរ ព្រោះអីខ្ញុំមិនអាចយំនៅពេលដែលវាត្រូវបានយកចេញទៅ។ កូនប្រុសខ្ញុំបានខំប្រឹងប្រែងដើម្បីជីវិត ប៉ុន្តែអង្គការបានសម្លាប់វា។ រៀងរាល់ពេលមានការប្រតិបត្តិតាមបែបបទព្រះពុទ្ធសាសនា ខ្ញុំខិតខំឧទ្ទិសការបន់ស្រន់របស់ខ្ញុំដល់ មួន។

**ប៊ុន ពីច័ន្ទ និង ខេនី ខកហ្កៀល**



# ដំណឹងស្វែងរកឪពុក និងបង

នាងខ្ញុំឈ្មោះ **ឡាត់ កញ្ញា** ឈ្មោះហៅក្រៅ ចក់។ ខ្ញុំមានបងប្អូន ៥នាក់ ខ្ញុំជាកូនពៅក្នុងគ្រួសារ។ ខ្ញុំកំពុងរកក្រុមគ្រួសារដែលបានបាត់ច្រើនឆ្នាំមកហើយ។ ប៉ារបស់ខ្ញុំឈ្មោះ សាមឿន ហៅ ឯម បែកគ្នានៅឆ្នាំ១៩៧៥ ។ បងស្រី វន្នី បានបែកគ្នានៅឆ្នាំ១៩៧៦។ ចំណែកបងប្រុសឈ្មោះ អាយបានបែកគ្នានៅឆ្នាំ១៩៧៩។ កាលឆ្នាំ១៩៧៩ ម៉ាក់របស់ខ្ញុំឈ្មោះ សេង លាង បងប្រុស និងខ្ញុំរស់នៅជាមួយគ្នា។ ក្រោយមកម៉ាក់ក៏បានស្លាប់នៅស៊ីសុផុន នៅក្នុងអំឡុងឆ្នាំ ១៩៧៩។ ខ្ញុំនិងបងប្រុសក៏បែកគ្នា ព្រោះបងប្រុសរបស់ខ្ញុំចង់ទៅភ្នំពេញ ដើម្បីតាមរកបងស្រី វន្នី សិន រីឯខ្ញុំក៏ទៅស្រុកថៃជួបជុំបងប្អូនជីដូនមួយរបស់ម៉ាក់។ សព្វថ្ងៃខ្ញុំរស់នៅសហរដ្ឋអាមេរិក។ រូបនេះ ថតនៅហ្វីលីពីន ក្នុងអំឡុងឆ្នាំ១៩៨០។ ខ្ញុំមានស្រុកកំណើតនៅសៃរ៉ា ខេត្តតាកែវ។ ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះខាងលើ សូមទំនាក់ទំនងមកនាងខ្ញុំតាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬអ៊ីម៉ែល truthbunthorn.s@dccam.org និងលេខទូរសព្ទ ០១២ ៩៩៦ ៧៥០។ សូមអរគុណ!

គេហទំព័រ៖ www.dccam.org

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# ឡាំ សុំ ៖ អធិការកិច្ច សាលារៀន

**កូនស្រីរបស់គាត់ ឡាំ តារាឫទ្ធិ បានរៀបរាប់ប្រាប់ថា ៖**



ឡាំ សុំ ជាមួយកូន៧នាក់ ក្នុងចំណោមកូន១៣នាក់ នៅភ្នំពេញ ឆ្នាំ១៩៧១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*នៅពេលយើងនៅតូច ឪពុករបស់យើងបានចូលចិត្តលេងជាមួយយើង គាត់បានតែងខ្លួនធ្វើជាដំរីមួយ។ គាត់បានយកពូកធំមួយបត់វាពាក់កណ្តាល ហើយដាក់ពូកបត់នោះនៅលើក្បាលរបស់គាត់។ បន្ទាប់មក គាត់បានសន្ទឹងដៃរបស់គាត់យោលទៅយោលមក និងដើរតាមយើង។ គាត់បានដេញតាមគ្រប់គ្នានៅក្នុងផ្ទះ។*

*គាត់បានធ្វើការងារអធិការកិច្ចសាលារៀនជាច្រើន ដើម្បីឲ្យមានចំណូលជីវភាពរស់នៅ វាមិនមានបញ្ហាអ្វីឡើយ ចំពោះសាលារៀនទាំងនោះ រួមមាន ៖ សាលារៀនឯកជន ចិន ឬបារាំង។ គាត់ធ្លាប់បានធ្វើជាគ្រូបង្រៀនម្នាក់នៅមុនពេលជាអធិការកិច្ច។ ខ្ញុំចាំបាន នៅថ្ងៃមួយគាត់បានទៅហាវ៉ៃ ហើយបានត្រឡប់មកវិញដោយមានខោច្រើនសម្រាប់យើងទាំងអស់គ្នា ខោទាំងនោះមានឆ្នូតច្រើន និងពណ៌ឆើតឆាយ។*

*យើងទាំងអស់គ្នាបានទៅរៀនសាលាបារាំង ដែលនៅទីនោះមានគ្រូបង្រៀនពីរនាក់នៅក្នុងថ្នាក់រៀនតែមួយ ម្នាក់ជាជនជាតិខ្មែរ និងម្នាក់ទៀតជាជនជាតិបារាំង។ បងប្អូនប្រុសៗខ្ញុំទាំង*



ម៉េង គីមសុន ប្រពន្ធរបស់ ឡាំ សុំ ឆ្នាំ១៩៦៥។ គាត់បានពាក់នាឡិកាដៃ អូម៉េហ្គា ១៨ការ៉ាត ហើយបានដូរយក ស្ករពាគីឡក្រាម និងទឹកដោះគោខាប់ ៥កំប៉ុង នៅអំឡុងរបបកម្ពុជា ប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឡាំ សុំ ជាមួយកូនស្រីៗ គីម, អណ្តែត, ម៉ុល និង តារារិទ្ធិ នៅភ្នំពេញ ឆ្នាំ១៩៧១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អស់បានចាកចេញពីប្រទេសកម្ពុជានៅមុនឆ្នាំ១៩៧០ ព្រោះពួកគេបាននិយាយភាសាបារាំងយ៉ាងស្ទាត់។ ឪពុករបស់ខ្ញុំបានសរសេរសំបុត្រជាច្រើនទៅកូនៗជាភាសាបារាំង។ គាត់ក៏ចេះនិយាយភាសាអង់គ្លេស វៀតណាម ចិន (ម៉ានដារីន និងកានទុន) ដែរ។ នៅពេលដែលខ្ញុំទៅផ្សារ ឪពុកខ្ញុំអាចនិយាយទៅកាន់អ្នកលក់នៅទីនោះជាភាសាចិន និងវៀតណាម។

នៅថ្ងៃយោធារបស់ ប៉ុល ពត បានចូលទីក្រុងភ្នំពេញ ឪពុកម្តាយរបស់ខ្ញុំបានហោះទៅក្រុងព្រះសីហនុ ជាទីកន្លែងដែលគាត់ទិញបានដីមួយឡូតិ៍។ គាត់ចង់រស់នៅក្បែរឆ្នេរសមុទ្រនៅពេលដែលគាត់ចាស់ទៅ។ ឪពុកខ្ញុំស្រឡាញ់ដីធ្លី គាត់បានទិញដីនៅក្នុងក្រុងកែប ស្រែអំបិល និងក្រុងព្រះសីហនុ។ គាត់ក៏បានស្រឡាញ់ការដាំដុះ រួមមាន ផ្កា រុក្ខជាតិ និងដើមឈើហូបផ្លែដែរ។ វាជាចំណង់ចំណូលចិត្តរបស់គាត់ ហើយខ្ញុំក៏មានចំណូលចិត្តដូចគាត់ដែរ។ ហេតុដូច្នេះម្តាយខ្ញុំនិយាយថា ខ្ញុំកាត់ទៅរកឪពុកខ្ញុំ។

ឪពុកមាររបស់ម្តាយខ្ញុំបានរស់នៅទីក្រុងព្រះសីហនុ។ គាត់ជាមេបញ្ជាការទាហាន លន់ នល់ ហើយបានសុំអ្នកបើកបររបស់គាត់ឲ្យជូនឪពុកម្តាយខ្ញុំទៅកំពង់ផែ ហើយចុះក្នុងទូកមួយទៅប្រទេសថៃ។ ឪពុកខ្ញុំចង់ទៅ ប៉ុន្តែម្តាយខ្ញុំបានបដិសេធ ព្រោះអីកូនរបស់គាត់ទាំងអស់នៅភ្នំពេញនៅឡើយ។ ឪពុកមាររបស់ម្តាយខ្ញុំបានចាកចេញទៅ គាត់កំពុងរស់នៅប្រទេសបារាំងសព្វថ្ងៃនេះ។

ខ្មែរក្រហមបាននិយាយថា "សូមមេត្តា ចាកចេញជាប្រញាប់" បន្ទាប់មកបានបាញ់រះទៅលើមេឃ។ ដូច្នេះ បងប្រុសខ្ញុំ ប្អូនស្រីៗ និងខ្ញុំបានវេចខ្ចប់យ៉ាងប្រញាប់យកបានអាហារសម្រាប់ហូបគ្រប់គ្រាន់តែពីរបីថ្ងៃប៉ុណ្ណោះ ដូចជា អង្ករ ឆ្នាំងមួយ និងចានជាច្រើន។ យើងបានចាកចេញពីផ្ទះនៅថ្ងៃទី១៨ ខែមេសា។ ប្អូនស្រីខ្ញុំបានខ្ចប់គ្រឿងអលង្ការរបស់ម្តាយខ្ញុំដាក់ក្នុងវ៉ាលីសមួយ ជាមួយនឹងរបស់មានតម្លៃផ្សេងទៀត ហើយបានដាក់វ៉ាលីសនោះចូលទៅក្នុងប្រឡោះមួយនៅខាងលើបន្ទប់របស់យើង។ នៅពេលយើងបានត្រឡប់មកវិញបន្ទាប់ពីរបបខ្មែរក្រហមមិនមានអ៊ីនៅក្នុងប្រឡោះនោះឡើយ។

ប្តីរបស់បងស្រីខ្ញុំឈ្មោះ សុភី បានសម្រេចចិត្តថាយើងត្រូវទៅស្រុកកំណើតរបស់គាត់នៅខេត្តព្រៃវែង។ យើងមានគ្នា១១នាក់ បានដើរចេញទៅ

ជាមួយគ្នា។ ប៉ុន្តែ យើងប្អូននាក់បាន ចាកចេញពីព្រៃវែងទៅកំពត ពីរបីថ្ងៃ បន្ទាប់ពីយើងទៅដល់ព្រៃវែង ព្រោះអី យើងចង់ទៅរកឪពុកម្តាយរបស់យើង ហើយយើងក៏មិនដឹងថាត្រូវរស់យ៉ាង ម៉េចនៅព្រៃវែងដែរ។ វាទទេស្អាត នៅទីនោះគឺមានតែវាលស្រែប៉ុណ្ណោះ មិនមានដើមឈើហូបផ្លែឡើយ។

បងប្រុសខ្ញុំឈ្មោះ ថូវ៉ានី បាននាំ យើងចេញទៅ។ យើងចំណាយពេល ជិតពីរខែបានទៅដល់ស្រុកកំណើត ម្តាយរបស់ខ្ញុំ ដោយយើងដើរដោយ ថ្មើរជើងត្រឡប់ទៅក្រោយវិញ។ ខ្មែរក្រហមបានបន្តចាប់យើង ហើយ បង្ខំឲ្យយើងធ្វើការ ប៉ុន្តែយើងបានបន្ត រត់គេចខ្លួន។

នៅពេលយើងបានទៅដល់ អ្នក ដំបូងគេដែលខ្ញុំបានឃើញគឺជាឪពុកខ្ញុំ កាន់ចបកាប់មួយ។ មុននោះ គាត់មាន ក្បាលពោះ ប៉ុន្តែឥឡូវនេះគាត់ស្គម ខ្លាំងណាស់។ គាត់បានចាប់ផ្តើមយំ នៅ ពេលដែលគាត់បានឃើញយើង ហើយ និយាយថា "ប៉ាបានរង់ចាំកូនទាំងអស់ គ្នានៅទីនេះរាល់ថ្ងៃ។ ប៉ា បានបន់ស្រន់ សម្រាប់កូនទាំងអស់គ្នា ហើយ បានរង់ចាំ"។ ភ្លាមៗនោះយើងទាំង អស់គ្នាបានយំ។

គាត់បានរស់នៅជាងពីរឆ្នាំ ឃុំវាល ក្របី វែកដី និងធ្វើការងារផ្សេងច្រើន ទៀត។ គាត់បានជញ្ជូនដីនៅទីវត្ត ជាទី ដែលខ្មែរក្រហមបានប្រាប់គាត់ថា គាត់មិនអាចត្រឡប់ទៅភ្នំពេញបានទេ ហើយក៏មិនមានមុខងារជាបុគ្គលដែល មានការអប់រំទៀតដែរ។ ខ្មែរក្រហម បាននិយាយថា "អ្នកឯងត្រូវធ្វើការ ឥឡូវនេះ"។

នៅឆ្នាំ១៩៧៦ បងប្រុសខ្ញុំ ប្អូនស្រី និងខ្ញុំត្រូវបានបញ្ជូលទៅក្នុង កងចល័ត។ ដំបូងឡើយខ្មែរក្រហម បានឲ្យយើងមកផ្ទះនៅពេលយប់ ប៉ុន្តែ បន្ទាប់មកខ្មែរក្រហមបានបញ្ជូនយើង កាន់តែឆ្ងាយទៅៗ។ ខ្ញុំបានរៀនធ្វើម្ហូប ស្លឹកត្នោត ខណៈដែលខ្ញុំនៅក្នុងកង ចល័ត។ ម្ហូបនីមួយៗត្រូវប្រើពេលបួន ទៅប្រាំម៉ោងដើម្បីធ្វើ ប៉ុន្តែខ្ញុំអាចធ្វើ ម្ហូបបាននៅតែពេលយប់ ដូច្នេះខ្ញុំត្រូវ ការពេលប្រាំបុប្រាំមួយយប់សម្រាប់ ម្ហូបនីមួយៗ។ ខ្ញុំធ្វើម្ហូបបានច្រើនដើម្បី ដូរយកក្តាម ឬអាហារផ្សេងៗនៅ ពេលខ្ញុំត្រូវការ។ នៅពេលដែលខ្ញុំបាន ដឹងថា ខ្ញុំនឹងត្រូវបានអនុញ្ញាតឲ្យទៅផ្ទះ ខ្ញុំបានធ្វើម្ហូបទុកជាច្រើន ដូច្នេះខ្ញុំអាច យកម្ហូបទៅដូរយកថ្នាំជក់ឲ្យឪពុករបស់ ខ្ញុំ។ ឪពុកខ្ញុំចូលចិត្តថ្នាំជក់ ជាងចំណី អាហារ។

យើងមិនបាននៅទីនោះទេនៅពេល ដែលខ្មែរក្រហមបានចាប់ឪពុកខ្ញុំទៅ។ អ្នកជិតខាងរបស់យើងបាននិយាយថា ឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួន ហើយគាត់ ត្រូវបានយកទៅដាក់នៅវត្តមួយ។ ខ្មែរក្រហមបានចោទប្រកាន់គាត់អំពី ចំណង់រត់ភៀសខ្លួនចេញពីភូមិ ដើម្បីទៅ ជួបបងប្រុសរបស់ខ្ញុំពីរនាក់ដែលបាន រស់នៅបរទេស។ ខ្មែរក្រហមក៏បាន និយាយ ដែរថា គ្មាននរណាម្នាក់ត្រូវ ធ្វើតាមឪពុកខ្ញុំ ឬធ្វើរឿងដូចដែលឪពុក ខ្ញុំបានធ្វើឡើយ។

ខ្មែរក្រហមបានយកឪពុកខ្ញុំទៅ មន្ទីរសន្តិសុខទូកមាស។ នៅតាមផ្លូវ ខ្មែរក្រហមបានវាយគាត់នឹងដើមអំពៅ រឹង មិនមែនអំពៅទន់ដែលយើងហូប ទេ។ ដើមអំពៅធំ និងរឹង។ បន្ទាប់ពី របប ប៉ុល ពត ខ្ញុំបានឃើញសៀវភៅ មួយរបស់ក្រសួងអប់រំ បានសរសេរ អំពីឪពុករបស់ខ្ញុំ។ សៀវភៅនោះបាន សរសេរថា ខ្មែរក្រហមបានបញ្ជូនឪពុក ខ្ញុំចេញពីទូកមាសទៅមន្ទីរសន្តិសុខ ល្បាងនៅក្នុងខេត្តកំពត ហើយបាន សម្លាប់គាត់នៅទីនោះ។

ម្តាយខ្ញុំបានស្នាក់នៅផ្ទះរយៈពេល ១០ថ្ងៃ បន្ទាប់យកឪពុកខ្ញុំទៅ។ គាត់ បាននិយាយទៅកាន់អង្គការថា "ប្រសិន បើអង្គការត្រូវការ នៅទីនេះមានកូន ទាំងប្អូននាក់របស់ខ្ញុំ និងខ្ញុំ។ អ្នកអាច សម្លាប់យើងទាំងអស់គ្នា"។ ម្តាយខ្ញុំ បានខូចចិត្តយ៉ាងខ្លាំង។ បន្ទាប់មកខ្មែរ ក្រហមបានយកគាត់ចេញទៅ រួមទាំង ប្រជាជនមកពីភ្នំពេញស្ទើរតែទាំងអស់។ ខ្ញុំបានរង់ចាំការហៅឈ្មោះម្តាយរបស់ ខ្ញុំ ប៉ុន្តែពេលនោះមិនបានហៅទេ។

ម្តាយមីងម្នាក់នៅក្នុងចំណោម ម្តាយមីងរបស់ខ្ញុំច្រើននាក់ ដែលបាន រស់នៅខាងក្រោមផ្ទះដែលយើងបាន ស្នាក់នៅរួមគ្នា។ គាត់ជាប្រធាននារី នៅក្នុងភូមិ។ គាត់កាចខ្លាំងណាស់ ហើយខ្ញុំក៏ស្អប់គាត់ខ្លាំងណាស់ដែរ។ គាត់តែងតែប្រាប់កូនរបស់គាត់ឲ្យ តាមដានយើង ៖ តើយើងបានធ្វើអ្វីខ្លះ? យើងហូបអ្វីខ្លះ? និងមានរបស់របរអ្វី? នៅពេលខ្លះពូរបស់ខ្ញុំបានសុំមីងមេត្តា ឲ្យយើងនូវចំណីអាហារ ប្រសិនជាមីង

មានច្រើន ប៉ុន្តែ គាត់បានធ្វើជាមិនចង់ស្តាប់។ ទោះយ៉ាងណាគាត់បានទុកចំណីអាហារនោះទាល់តែរលួយខូចជាជាងឲ្យមកយើង។ គាត់បានដឹងថាជីដូនរបស់ខ្ញុំបានរក្សាទុកនូវដ្តិលទឹកធំមួយដែលធ្វើអំពីប្រាក់។ គាត់បានរាយការណ៍អំពីជីដូនខ្ញុំប្រាប់អង្គការដោយនិយាយថា ជីដូនខ្ញុំមិនស្មោះត្រង់។ បន្ទាប់មកកម្មាភិបាលបានទៅផ្ទះគាត់ ហើយប្រមូលយករបស់របរទាំងអស់។

បន្ទាប់ពីរបប ប៉ុល ពត នៅទីនោះមិនមានអ៊ីហូបឡើយ ហើយក៏មិនមានអ៊ីសម្រាប់មីងខ្ញុំដែរ។ ប្រសិនបើមីងខ្ញុំឲ្យជីដូនខ្ញុំរក្សាទុកដ្តិលទឹកធំនោះ គាត់នឹងបានលក់វា ដើម្បីយកប្រាក់ទិញស្បៀងអាហារសម្រាប់ហូប។ ជីដូនខ្ញុំតែងតែថែរក្សាបីបាច់គ្រួសាររបស់គាត់។

នៅថ្ងៃដែលឪពុករបស់ខ្ញុំត្រូវបានចាប់យកទៅមន្ទីរសន្តិសុខ មីងបាននិយាយថា វាត្រូវតែដូច្នេះ ព្រោះអីឪពុករបស់ខ្ញុំសក្តិសមនឹងទទួលកំហុស។ បន្ទាប់ពីរបប ប៉ុល ពត ខ្ញុំបានទៅលេងស្រុកកំណើតរបស់ម្តាយខ្ញុំ ហើយខ្ញុំបានឃើញមីងខ្ញុំ។ គាត់និយាយថា "អ្នកឯងល្អណាស់ ហើយនិយាយពិរោះ" ដូចជាមិនមានរឿងអ៊ីបានកើតឡើង។ គាត់បានភ្លេចនូវអ៊ី ដែលគាត់បានធ្វើនៅក្នុងសម័យ ប៉ុល ពត។

នៅពេលខ្លះ ខ្ញុំគិតអំពីមីងខ្ញុំ និងអ្នកខ្លះផ្សេងទៀតនៅក្នុងភូមិរបស់យើង ខ្ញុំខឹងជាខ្លាំង។ ប៉ុន្តែ ខ្ញុំមិនចង់សងសឹក ព្រោះអីឥឡូវនេះយើងរស់នៅក្នុងសន្តិភាព។ ប្រជាជនទាំងអស់នៅក្នុងភូមិជីដូនជីតារបស់ខ្ញុំនៅតែក្រនៅឡើយ។ អ្នកទាំងនោះបានប្រមូលអ៊ីៗទាំងអស់ពីយើងនៅអំឡុងសម័យ ប៉ុល ពត ប៉ុន្តែពួកគេនៅតែក្រ។ ពួកគេមិនមានអ៊ីធ្វើ មិនមានការអប់រំ ដូច្នេះនៅតែក្រីក្រ។

**ប៉ាង ពីច័ន្ទ និង វេនី ខកហ្គៀល**



នៅកណ្តាល ៖ ឡាំ ស៊ុំ និង ម៉េង គឹមសុន ជាមួយកូនៗឈ្មោះ គឹម និង ប៉ារ៉ាម នៅក្នុងពិធីមួយធ្វើនៅក្នុងស្តាតអូឡាំពិក ឆ្នាំ១៩៦០។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គសព្វព្រះរាជហឫទ័យស្តេចយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីសម្ពោធបណ្ណាល័យសម្តេចម៉ែ នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានារាជធានីភ្នំពេញ វេលាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

(សន ប៊ុនស៊ីម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

បណ្ណាល័យសម្តេចម៉ែ មើលពីខាងក្រៅ។

(សោម ប៊ុនថន/មជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 249, September 2020 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.